## រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការ កែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុង វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ ប្រចាំឆមាសទី១ ឆ្នាំ២០២៤

«រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកវិស័យឯកជនជាដៃគូដ៏សំខាន់
និងជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិ»



បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃសុក្រ ៤រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
ត្រូវនឹងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤

# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការ កែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុង វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ ប្រចាំឆមាសទី១ ឆ្នាំ២០២៤

« រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកវិស័យឯកជនជាដៃគូដ៏សំខាន់
និងជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិ »

# មាតិកា


ខ្លឹមសារសង្ខេបប្រតិបត្តិ ....................................................................................... i

I. សេចក្តីផ្តើម ....................................................................................... ១

II. វិធីសាស្ត្រក្នុងការរៀបចំរបាយការណ៍ ....................................................................................... ៣

III. វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ....................................................................................... ៥

១-វឌ្ឍនភាពជារួម ....................................................................................... ៥

២-វឌ្ឍនភាពតាមក្រសួង ស្ថាប័នទទួលបន្ទុក ....................................................................................... ៧

៣-វឌ្ឍនភាពតាមក្រុមវិធានការ ....................................................................................... ៩

IV. យន្តការស្ថាប័ន ....................................................................................... ១១

១-ដំណើរការរៀបចំយន្តការស្ថាប័នសម្រាប់វេទិកា G-PSF ....................................................................................... ១១

២-យន្តការការងារសម្រាប់តាមដាននិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកា G-PSF លើកទី១៩ ....................................................................................... ១២

V. បញ្ហាប្រឈមនិងអនុសាសន៍ ....................................................................................... ១៣

១-បញ្ហាប្រឈម ....................................................................................... ១៣

២-អនុសាសន៍ ....................................................................................... ១៦

VI. សេចក្តីសន្និដ្ឋាននិងទិសដៅការងារបន្ត ....................................................................................... ១៩

បញ្ជីពាក្យកាត់ ....................................................................................... ២១

បរិសិដ្ឋ ....................................................................................... ២២

## ខ្លឹមសារសង្ខេបប្រតិបត្តិ

១-វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) គឺជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបើកទូលាយ ដែលត្រូវបានបង្កើតឡើងដំបូងក្នុងឆ្នាំ១៩៩៩ ក្រោមគំនិតផ្តួចផ្តើមប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាពេលនោះ និងជាប្រធានព្រឹទ្ធសភានាពេលបច្ចុប្បន្ន។ យន្តការនេះបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអនុញ្ញាតឱ្យផ្នែកឯកជនលើកឡើងនូវសំណូមពរនិងបញ្ហាប្រឈម ដើម្បីស្នើសុំដំណោះស្រាយនិងអន្តរាគមន៍ពីផ្នែករាជរដ្ឋាភិបាល។

២-ដោយយល់ឃើញពីសារៈសំខាន់នៃការបន្តនិរន្តរភាពវេទិកា G-PSF ក្នុងការចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនិងវិនិយោគនៅកម្ពុជា នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំវេទិកា G-PSF លើកទី១៩ ដែលជាវេទិកា G-PSF លើកទី១ ក្នុងនីតិកាលទី៧ នៃរដ្ឋសភា។ វេទិកាលើកទី១៩ នេះបានដាក់ចេញវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ចម្បងៗចំនួន១១ចំណុច រួមមានៈ(១) ការកែសម្រួលបរិយាកាសធុរកិច្ចនិងការវិនិយោគ (២) ការសម្រាលបន្ទុកលើអនុលោមភាព (៣) ការសម្រួលដល់ធុរកិច្ចក្រោមដែនសមត្ថកិច្ចពន្ធដារ (៤) កិច្ចសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចគយ (៥) ការលើកកម្ពស់ការដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ (៦) ការស្តារនិងការលើកស្ទួយការអភិវឌ្ឍវិស័យទេសចរណ៍ (៧) ការអភិវឌ្ឍវិស័យកសិកម្មនិងកសិឧស្សាហកម្ម (៨) វិស័យធនាគារនិងហិរញ្ញវត្ថុ (៩) វិស័យរ៉ែនិងថាមពល (១០) វិស័យសំណង់និងអចលនទ្រព្យ និង (១១) បញ្ហាផ្សេងៗ។

៣-ស្របតាមការប្រគល់ភារកិច្ចរបស់រាជរដ្ឋាភិបាល ក្នុងការតាមដាននិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការខាងលើ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) បានរៀបចំរបាយការណ៍នេះឡើងដើម្បីរាយការណ៍អំពីវឌ្ឍនភាពជូនរាជរដ្ឋាភិបាល សម្រាប់ឆមាសទី១ ឆ្នាំ២០២៤។ របាយការណ៍វឌ្ឍនភាពនេះ ត្រូវបានរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យ ផ្អែកលើលទ្ធផលប្រព័ន្ធតាមដានការអនុវត្តវិធានការ G-PSF លើកទី១៩ (G-PSF Tracking System) ដែលមានឧបករណ៍សំខាន់ៗចំនួន២ រួមមានៈ ផ្ទាំងវិភាគទិន្នន័យ (Dashboard) និងតារាងបណ្តុំទិន្នន័យ (Dataset)។ ការតាមដានវឌ្ឍនភាពត្រូវបានកំណត់ជា៣កម្រិត គឺសម្រេចបានពេញលេញ កំពុងត្រូវបានអនុវត្ត និង មិនទាន់ត្រូវបានអនុវត្ត។

៤-លទ្ធផលសង្ខេបនៃការតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ទាំង១១ ហើយដែលត្រូវបានយកមកបំបែកជាវិធានការលម្អិតចំនួន១៨៨ ដើម្បីងាយស្រួលក្នុងការពិនិត្យនិងវាយតម្លៃ មានដូចខាងក្រោម÷

**ក-វឌ្ឍនភាពជារួម:** វិធានការដែលសម្រេចបានពេញលេញ មានប្រមាណ៥៧% (ស្មើនឹង ១០៨វិធានការ)។ ជាមួយគ្នានេះ វិធានការដែលកំពុងត្រូវបានអនុវត្ត មានប្រមាណ៤៣% (ស្មើនឹង ៨០ វិធានការ) ដែលភាគច្រើនជាវិធានការដែលមានលក្ខណៈជាចរន្ត តម្រូវឱ្យមានការអនុវត្តជាបន្តបន្ទាប់ រីឯវិធានការខ្លះទៀតគឺពុំទាន់ដល់ពេលវេលាកំណត់ត្រូវបញ្ចប់ការអនុវត្ត។ ជារួមវិធានការជាងពាក់កណ្តាលត្រូវបានសម្រេចពេញលេញ ត្រឹមរយៈពេល៦ខែ ដើមឆ្នាំ២០២៤ ដែលតួលេខនេះបង្ហាញថា ការអនុវត្តវិធានការមានវឌ្ឍនភាពល្អប្រសើរគួរឱ្យកត់សម្គាល់។

**ខ-វឌ្ឍនភាពតាមក្រសួង ស្ថាប័នទទួលបន្ទុក:** វិធានការទាំងអស់សុទ្ធតែត្រូវបានចាប់ផ្តើមអនុវត្ត ដែលក្នុងនោះ មានវិធានការយ៉ាងតិចមួយ ត្រូវបានសម្រេចពេញលេញដោយក្រសួង ស្ថាប័នភាគច្រើន។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជា (៥វិធានការ) និងក្រសួងរ៉ែនិងថាមពល (២វិធានការ) សម្រេចបានការអនុវត្តវិធានការពេញលេញ១០០%។ ជាមួយគ្នានេះ ក្រសួង ស្ថាប័នដែលទទួលបន្ទុកដឹកនាំអនុវត្តវិធានការច្រើនជាងគេ គឺអគ្គនាយកដ្ឋានពន្ធដារ (៥៦វិធានការ) ដែលបានសម្រេចការអនុវត្តវិធានការពេញលេញ ចំនួន៤៨វិធានការ ស្មើនឹងប្រមាណ៨៦%។ ដោយឡែក ក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋបាលខេត្តព្រះសីហនុ ទទួលបន្ទុកអនុវត្តវិធានការតិចជាងគេ ចំនួន១ ដូចគ្នា ហើយវិធានការទាំងនោះ កំពុងត្រូវបានអនុវត្តនៅឡើយ។

**គ-វឌ្ឍនភាពតាមក្រុមវិធានការ:** បើសង្កេតពីវឌ្ឍនភាពតាមក្រុមវិធានការ ឃើញថាក្រុមវិធានការទី៨ «វិស័យធនាគារនិងហិរញ្ញវត្ថុ» (៨វិធានការ) មានវឌ្ឍនភាពល្អប្រសើរ ដែលបានសម្រេចពេញលេញ១០០%។ ទន្ទឹមនេះ ក្រុមវិធានការដែលមានវិធានការច្រើនជាងគេគឺ ក្រុមវិធានការទី៣ «ការសម្រួលដល់ធុរកិច្ចក្រោមដែនសមត្ថកិច្ចពន្ធដារ» (៥២វិធានការ) ដែលបានសម្រេចការអនុវត្តពេញលេញ ចំនួន៤២វិធានការ ស្មើនឹងប្រមាណ៨១%។ រីឯក្រុមវិធានការទី៥ «ការលើកកម្ពស់ការដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ» មានវិធានការតិចជាងគេ (១វិធានការ) ដែលវិធានការនោះកំពុងត្រូវបានអនុវត្តនៅឡើយ។

**៥-យន្តការស្ថាប័ន:** ដើម្បីពង្រឹងប្រសិទ្ធភាពនៃតួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជន (គ.អ.វ.) ក្នុងការសម្របសម្រួលយន្តការវេទិកា G-PSF រាជរដ្ឋាភិបាលបានសម្រេចកែសម្រួលវិសាលភាព និងបានផ្លាស់ប្តូរឈ្មោះ គ.អ.វ. ទៅជា «គណៈកម្មាធិការសម្របសម្រួលការងារសម្រាប់យន្តការវេទិកា G-PSF» (គ.ស.រ.ជ.) វិញ។ យន្តការវេទិកានេះ បានពង្រីកវិសាលភាពរបស់ខ្លួនកាន់តែធំឡើងៗ ជាបន្តបន្ទាប់ រហូតដល់១៤ក្រុមការងារតាមវិស័យ គិតត្រឹមវេទិកាលើកទី១៩ និងបង្កើតក្រុមការងារថ្មីចំនួន២បន្ថែមទៀតគឺ ក្រុមការងារផ្នែកសេដ្ឋកិច្ច សង្គមឌីជីថល និងទូរគមនាគមន៍

(ក្រុមការងារ « ណ») និងក្រុមការងារផ្នែករដ្ឋបាលដែនដី សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ (ក្រុមការងារ « ត») ដើម្បីធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន។ ជាមួយគ្នានេះ ក.អ.ក. បានបង្កើតក្រុមការងារមួយដើម្បីជំរុញការងារតាមដាននិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលមានភារកិច្ចក្នុងការរៀបចំប្រព័ន្ធតាមដាននិងវាយតម្លៃ ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងការបូកសរុបជារបាយការណ៍វឌ្ឍនភាពជូនរាជរដ្ឋាភិបាលរៀងរាល់៦ខែម្តង។

**៦-បញ្ហាប្រឈមៈ** ក្នុងការអនុវត្តវិធានការ ក៏ដូចជាការសម្របសម្រួលវេទិកាG-PSF និងការរៀបចំរបាយការណ៍នេះ មានបញ្ហាប្រឈម៣ប្រភេទលេចឡើង ដូចខាងក្រោម÷

- ការអនុវត្តវិធានការៈ បញ្ហាប្រឈមនិងសំណូមពរមួយចំនួនត្រូវបានលើកឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន ជាពិសេសពាក់ព័ន្ធនឹងកង្វះធនធាននិងឧបករណ៍បច្ចេកទេស កិច្ចសហប្រតិបត្តិការជាមួយឬការចូលរួមពីវិស័យឯកជន ការផ្សព្វផ្សាយអំពីកិច្ចការងារសម្រេចបាន និងបញ្ហាដែលមានលក្ខណៈបច្ចេកទេសមួយចំនួន។
- យន្តការស្ថាប័នៈ បញ្ហាប្រឈមពាក់ព័ន្ធដែលបានលេចឡើង គឺកង្វះយន្តការស្ថាប័នគាំទ្រជាក់លាក់ដែលមានមុខងារពេញលេញនិងសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើជាសេនាធិការដល់ គ.ស.រ.ជ. និងកង្វះការកំណត់ជាក់លាក់ ពីការរៀបចំនិងការប្រព្រឹត្តទៅនៃយន្តការនេះ។
- ការរៀបចំនិងអនុវត្តប្រព័ន្ធតាមដាននិងវាយតម្លៃៈ បញ្ហាប្រឈមដែលបានជួបប្រទះក្នុងផ្នែកនេះមានដូចជាភាពមានកម្រិតនៃក្របខ័ណ្ឌពេលវេលានិងធនធានមនុស្សរបស់ ក.អ.ក. ភាពមានកម្រិតនៃវិសាលភាពនិងសមត្ថភាពរបស់ប្រព័ន្ធក្នុងការរួមបញ្ចូលការវាយតម្លៃនិងមតិរបស់ផ្នែកឯកជន និងកង្វះការរៀបចំជាទម្រង់ឌីជីថលរួមមួយសម្រាប់ឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើការស្វ័យបញ្ចូលទិន្នន័យ។

**៧-អនុសាសន៍ៈ** អនុសាសន៍មួយចំនួន ដើម្បីពង្រឹងការអនុវត្តវិធានការ ក៏ដូចជាធ្វើឱ្យប្រសើរឡើងនូវយន្តការស្ថាប័ន និងប្រព័ន្ធតាមដាននិងវាយតម្លៃ មានដូចជា÷

- ការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តវិធានការ គួរផ្តោតលើ (១) ការបញ្ចូលវិធានការដែលក្រសួង ស្ថាប័នសាមីទទួលបន្ទុកទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំរបស់ខ្លួន និងការបង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍ ដើម្បីអនុវត្តវិធានការ (២) ការរៀបចំផែនការសកម្មភាពក្នុងការអនុវត្តវិធានការដោយធ្វើអាទិភាវូបនីយកម្ម ព្រមទាំងកំណត់ក្របខ័ណ្ឌពេលវេលានិងសូចនាករឱ្យបានច្បាស់លាស់លើវិធានការដែលត្រូវអនុវត្ត (៣) ការបញ្ជ្រាបនិងផ្សព្វផ្សាយឱ្យបានទូលំទូលាយពីលទ្ធផលនៃកិច្ចប្រជុំកម្រិតក្រុមការងារតាមវិស័យនិងលទ្ធផលនៃវេទិកា និង (៤) ការលើកទឹកចិត្តឱ្យវិស័យឯកជនប្រើប្រាស់យន្តការវេទិកា G-PSF ជាច្រកអាទិភាពក្នុងការលើកបញ្ហាប្រឈម ក្តីកង្វល់ និងសំណូមពរនានា។
- ការធ្វើឱ្យប្រសើរឡើងនូវយន្តការស្ថាប័ន គួរផ្តោតលើ (១) ការដំឡើងកម្រិតមុខងារនៃក្រុមការងារតាមដាននិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់របស់ក.អ.ក. ទៅជាលេខាធិការដ្ឋាន (២) ការរៀបចំនិងដាក់ឱ្យប្រើប្រាស់នូវសៀវភៅណែនាំស្តីពីស្តង់ដានីតិវិធី

ប្រតិបត្តិ និង (៣) ការបង្កើតលេខាធិការដ្ឋានក្រុមការងារតាមវិស័យនីមួយៗ ដែលមានសមាសភាពចាត់តាំងដោយសហប្រធាននៃក្រុមការងារតាមវិស័យ។

- ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតាមដាននិងវាយតម្លៃ គួរផ្តោតលើ (១) ការរៀបចំប្រព័ន្ធតាមដាននិងវាយតម្លៃឱ្យមានលក្ខណៈពេញលេញ ដែលអាចតាមដានវឌ្ឍនភាពនិងវាយតម្លៃលើផលជះ (២) ការបញ្ចូលមតិយោបល់និងការវាយតម្លៃរបស់ផ្នែកឯកជនលើប្រសិទ្ធភាពយន្តការនិងការអនុវត្តវិធានការ (៣) ការរៀបចំថ្នាលបច្ចេកវិទ្យានិងក្រុមការងារអន្តរក្រសួង ស្ថាប័នកម្រិតបច្ចេកទេសដើម្បីបញ្ចូលទិន្នន័យ ព្រមទាំងសៀវភៅណែនាំនិងសិក្ខាសាលាបណ្តុះបណ្តាលដល់ភាគីពាក់ព័ន្ធស្តីពីការបញ្ចូលទិន្នន័យ(៤) ការពង្រីកវិសាលភាពតាមដាននិងវាយតម្លៃ លើបញ្ហាដែលបានលើកឡើងនៅតាមក្រុមការងារតាមវិស័យ និង (៥) ការបោះពុម្ពផ្សាយនិងផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញនូវលទ្ធផលតាមដានវឌ្ឍនភាពនិងវាយតម្លៃ ក៏ដូចជាឯកសារនិងព័ត៌មានពាក់ព័ន្ធជូនសាធារណជន។

## I. សេចក្តីផ្តើម

ជាសាវតារ វេទិកា G-PSF គឺជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបើកទូលាយ ដែលត្រូវបានបង្កើតឡើងដំបូងក្នុងឆ្នាំ១៩៩៩ ក្រោមគំនិតផ្តួចផ្តើមប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានាពេលនោះ** និងជា **ប្រធានព្រឹទ្ធសភានាពេលបច្ចុប្បន្ន** ដែលជាស្ថាបនិកនិងជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើម បានដឹកនាំរាល់វេទិកានេះកន្លងមក ដោយទទួលបាននូវលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់សម្រាប់សង្គម សេដ្ឋកិច្ចជាតិ។ វេទិកានេះ ត្រូវបានចាត់ទុកជារបៀបវារៈចម្បងនិងមានសារៈសំខាន់ក្នុងអាណត្តិដឹកនាំនីមួយៗរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការស្អិតល្មួតនិងវប្បធម៌សន្ទនារវាងរាជរដ្ឋាភិបាល ជាមួយផ្នែកឯកជន និងរួមគ្នាដោះស្រាយបញ្ហាប្រឈមនិងកង្វល់របស់ធុរជននិងវិនិយោគិន ក្នុងគោលដៅជំរុញការអភិវឌ្ឍវិស័យឯកជននៅកម្ពុជា ដែលរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនិងវិនិយោគ តាមរយៈការផ្តល់កិច្ចសម្រួលនានា កាត់បន្ថយថ្លៃធ្វើធុរកិច្ច លើកកម្ពស់ភាពប្រកួតប្រជែង បង្កើនប្រសិទ្ធភាពទីផ្សារ ផលិតភាពការងារ និងជំរុញកំណើនសេដ្ឋកិច្ច។ វេទិកានេះ បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលដែលជាអ្នកតាក់តែងគោលនយោបាយ និងដាក់ចេញនូវបទប្បញ្ញត្តិនានា បានស្តាប់នូវក្តីកង្វល់ សំណូមពរ និងមតិឆ្លុះបញ្ចាំងពីផ្នែកឯកជន ដើម្បីយកទៅជុះខាត់ កែលម្អ និងតម្រង់ទិសការអនុវត្តជាយុទ្ធសាស្ត្រសម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យឯកជន ឱ្យក្លាយជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិយ៉ាងពិតប្រាកដ ហើយរាល់សេចក្តីសម្រេចនានារបស់អង្គវេទិកានេះ មានអានុភាពស្មើនឹងសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី។

លទ្ធផលនៃវេទិកា ត្រូវបានលើកសរសើរក្នុងរបាយការណ៍វាយតម្លៃរបស់ធនាគារពិភពលោក កាលពីឆ្នាំ២០០៩ ដោយទទួលស្គាល់ថាជាយន្តការកិច្ចសន្ទនារវាងរាជរដ្ឋាភិបាលនិងផ្នែកឯកជន ដែលមានប្រសិទ្ធភាពខ្ពស់ និងទទួលបានពិន្ទុវាយតម្លៃសមិទ្ធកម្មខ្ពស់ជាងគេ ក្នុងចំណោមប្រទេសជាង២០ផ្សេងទៀត។ យន្តការនេះបានដើរតួនាទីដ៏មានសារៈសំខាន់ក្នុងការអនុញ្ញាតឱ្យផ្នែកឯកជនលើកឡើងនូវក្តីកង្វល់ សំណូមពរ និងបញ្ហាប្រឈម ដើម្បីស្នើសុំដំណោះស្រាយនិងអន្តរាគមន៍ ពីភាគីរាជរដ្ឋាភិបាល។ វេទិកាG-PSF ត្រូវបានអាក់ខានក្នុងការរៀបចំអស់រយៈពេលប្រមាណជាង៣ឆ្នាំ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។ ស្លាកស្នាមនៃវិបត្តិជំងឺនេះ គួបផ្សំនឹងការលេចឡើងនូវបញ្ហាប្រឈមសកលថ្មីៗដែលមានចរិតលក្ខណៈជាប្រព័ន្ធនិងរចនាសម្ព័ន្ធ និងក្នុងគ្រាដែលសេដ្ឋកិច្ចកម្ពុជា បានបន្តងើបឡើងវិញជាបណ្តើរៗ វេទិកានេះត្រូវបានរៀបចំក្នុងរយៈពេលត្រឹមតែ៨៣ថ្ងៃប៉ុណ្ណោះ បន្ទាប់ពីរាជរដ្ឋាភិបាលអាណត្តិថ្មីត្រូវបានបង្កើតឡើងក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីជំរុញការស្តារកំណើនសេដ្ឋកិច្ចជាតិ និងបន្តនូវ

ប្រពៃណីដ៏ល្អពីរាជរដ្ឋាភិបាលនីតិកាលមុន សម្រាប់ការគាំទ្រ ជំរុញ និងលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជននៅកម្ពុជា។ ទាំងនេះ សុទ្ធសឹងជាសក្ខីកម្មដែលបង្ហាញអំពីសារៈសំខាន់នៃការបន្តនិរន្តរភាពការរៀបចំយន្តការវេទិកាដ៏មានសារៈសំខាន់នេះ ក្នុងគ្រប់អាណត្តិនៃរាជរដ្ឋាភិបាល រហូតដល់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដូចដែលបានកំណត់ផងដែរនៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់ការកសាងនិងការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១។ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ផ្តល់អាទិភាពដល់ការធ្វើពិពិធកម្មនិងការប្រកួតប្រជែងសេដ្ឋកិច្ច[1] តាមរយៈការបន្តអនុវត្តនិងធ្វើបច្ចុប្បន្នកម្មគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា[2] ឆ្នាំ២០១៥-២០២៥(IDP)។ គោលនយោបាយ IDP បានលើកឡើងអំពីការបន្តពង្រឹងយន្តការពិគ្រោះយោបល់ជាមួយវិស័យឯកជន តាមរយៈវេទិកា G-PSF ដើម្បីពង្រឹងការអនុវត្តគោលនយោបាយនេះផង និងប្រែក្លាយវេទិកានេះទៅជាយន្តការដ៏មានប្រសិទ្ធភាពមួយសម្រាប់ជាធាតុចូលនិងមតិយោបល់ សំដៅធ្វើឱ្យបរិយាកាសធុរកិច្ចនិងវិនិយោគ កាន់តែមានភាពប្រកួតប្រជែងដោយស្មោះត្រង់និងស្មើភាព ព្រមទាំងអាចទាក់ទាញវិនិយោគដែលផ្តល់អត្ថប្រយោជន៍ដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់[3]។ ដូចនេះ កិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អ និងពង្រឹងក្របខ័ណ្ឌស្ថាប័ននៃយន្តការវេទិកានេះ ចាប់តាំងពីដើមអាណត្តិនៃរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ រហូតមកដល់បច្ចុប្បន្ន បាននិងកំពុងរួមចំណែកយ៉ាងសំខាន់ដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងគោលនយោបាយ IDP ផងដែរ។

មុននឹងឈានដល់វេទិកា G-PSF លើកទី១៩នេះ សហប្រធានផ្នែករាជរដ្ឋាភិបាលនិងសហ-ប្រធានផ្នែកឯកជន បានដឹកនាំកិច្ចប្រជុំក្រុមការងារតាមវិស័យទាំង១៤ សរុបចំនួន១៤លើក គិតចាប់ពីខែឧសភា ឆ្នាំ២០២៣ ដល់មុនថ្ងៃរៀបចំវេទិកា ដែលមានអ្នកចូលរួមសរុបប្រមាណជិត១ ៣០០រូប ក្នុងនោះស្ត្រីមានប្រមាណ២៤%។ ក្រុមការងារតាមវិស័យទាំងអស់ បានពិភាក្សាលើបញ្ហាប្រឈមនិងសំណូមពរសរុបប្រមាណជិត២០០ ក្នុងនោះ បញ្ហាចំនួន២៣ ត្រូវបានបង្វែរទៅក្រុមការងារផ្នែកផ្សេងៗដែលមានសមត្ថកិច្ចដោះស្រាយសមស្របជាង។ ទន្ទឹមនេះ បញ្ហាដែលមានលក្ខណៈអន្តរវិស័យនិងអន្តរស្ថាប័ន ចំនួនប្រមាណ១៤ ត្រូវបានបញ្ជូនបន្តទៅគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (គ.ស.ហ.)។ ជាលទ្ធផល ក្រុមការងារតាមវិស័យនិង គ.ស.ហ. បានខិតខំដោះស្រាយបញ្ហាប្រឈមនិងសំណូមពរនានារបស់វិស័យឯកជន ប្រកបដោយភាពម្ចាស់ការ និងប្រសិទ្ធភាពខ្ពស់។ ដោយឡែក បញ្ហាប្រឈមនិងសំណូមពរមួយចំនួនដែលនៅសេសសល់របស់វិស័យឯកជន ត្រូវបានបញ្ជូនទៅដោះស្រាយក្នុងកម្រិតវេទិកា។

---

[1] យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ខែសីហា ឆ្នាំ២០២៣

[2] យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា (RGC) បញ្ចកោណទី២ មុំទី១ ខែសីហា ឆ្នាំ២០២៣

[3] គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥

កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅវិមានសន្តិភាព **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំវេទិកា G-PSF លើកទី១៩ ដោយមានអ្នកចូលរួមចំនួនប្រមាណ ១.២០០រូប ក្នុងនោះស្ត្រីមានប្រមាណ៣១% ដើម្បីពិនិត្យនិងដោះស្រាយបញ្ហាប្រឈមសំណូមពរ និងក្តីកង្វល់របស់ផ្នែកឯកជន ដែលពុំទាន់ទទួលបាននូវដំណោះស្រាយឬការឆ្លើយតបពេញលេញ។ អង្គវេទិកាបានដាក់ចេញវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ចម្បងៗចំនួន១១ចំណុច រួមមាន (១) ការកែសម្រួលបរិយាកាសធុរកិច្ចនិងការវិនិយោគ (២) ការសម្រាលបន្ទុកលើអនុលោមភាព (៣) ការសម្រួលដល់ធុរកិច្ចក្រោមដែនសមត្ថកិច្ចពន្ធដារ (៤) កិច្ចសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចគយ (៥) ការលើកកម្ពស់ការដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ (៦) ការស្តារនិងការលើកស្ទួយការអភិវឌ្ឍវិស័យទេសចរណ៍ (៧) ការអភិវឌ្ឍវិស័យកសិកម្មនិងកសិឧស្សាហកម្ម (៨) វិស័យធនាគារនិងហិរញ្ញវត្ថុ (៩) វិស័យរ៉ែនិងថាមពល (១០) វិស័យសំណង់និងអចលនទ្រព្យ និង (១១) បញ្ហាផ្សេងៗ។

ស្របតាមការប្រគល់ភារកិច្ចរបស់រាជរដ្ឋាភិបាល ក្នុងការតាមដាននិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការខាងលើ ក.អ.ក. បានរៀបចំរបាយការណ៍នេះឡើង ដើម្បីរាយការណ៍អំពីវឌ្ឍនភាពជូនរាជរដ្ឋាភិបាល ប្រចាំឆមាសទី១ ឆ្នាំ២០២៤។

បន្ទាប់ពីសេចក្តីផ្តើម របាយការណ៍វឌ្ឍនភាពនេះ មានរចនាសម្ព័ន្ធដូចខាងក្រោម÷

- ផ្នែកទី II: វិធីសាស្ត្រក្នុងការរៀបចំរបាយការណ៍
- ផ្នែកទី III: វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់
- ផ្នែកទី IV: យន្តការស្ថាប័ន
- ផ្នែកទី V: បញ្ហាប្រឈមនិងអនុសាសន៍
- ផ្នែកទី VI: សេចក្តីសន្និដ្ឋាននិងទិសដៅការងារបន្ត។

## II. វិធីសាស្ត្រក្នុងការរៀបចំរបាយការណ៍

របាយការណ៍វឌ្ឍនភាពនេះ ត្រូវបានរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យផ្អែកលើលទ្ធផលប្រព័ន្ធតាមដានការអនុវត្តវិធានការវេទិកា G-PSF លើកទី១៩ (G-PSF Tracking System) ដែលជាកិច្ចសហការរៀបចំរវាង ក.អ.ក. និងកម្មវិធីភាពជាដៃគូកម្ពុជាអូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED)។ ប្រព័ន្ធតាមដាននេះ មានឧបករណ៍សំខាន់ៗចំនួន២ រួមមានផ្ទាំងវិភាគទិន្នន័យ (Dashboard) និងតារាងបណ្តុំទិន្នន័យ (Dataset)។

**ផ្ទាំងវិភាគទិន្នន័យ** (Dashboard) គឺជាឧបករណ៍ដែលបង្ហាញពីវឌ្ឍនភាពបែបបរិមាណវិស័យនៃការអនុវត្តវិធានការដែលបានដាក់ចេញក្នុងវេទិកា G-PSF លើកទី១៩ ក្នុងរូបភាពជាក្រាហ្វិកព័ត៌មាន

(Infographics)។ វឌ្ឍនភាពទាំងនេះ ត្រូវបានកំណត់ដោយកម្រិតចំនួន៣: សម្រេចបានពេញលេញ (ពណ៌បៃតង) កំពុងត្រូវបានអនុវត្ត (ពណ៌ទឹកក្រូច) និងមិនទាន់ត្រូវបានអនុវត្ត (ពណ៌ក្រហម)។

**តារាងបណ្ដុំទិន្នន័យ (Dataset)** គឺជាឧបករណ៍ផ្ទុកទិន្នន័យនិងព័ត៌មានយ៉ាងសំខាន់ ក្នុងទម្រង់ជាតារាងម៉ាទ្រីស ប្រមូលផ្ដុំទៅដោយវិធានការ ដែលត្រូវបានបែងចែកយ៉ាងច្បាស់លាស់ទៅតាមក្រុមវិធានការ (ដូចមានចែងក្នុងសេចក្ដីជូនដំណឹងលេខ១១២៧២ សជណ.អកទ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីលទ្ធផលនៃវេទិកា G-PSF លើកទី១៩) ក្រុមការងារតាមវិស័យនៃវេទិកាលើកទី១៩ ក្រសួង ស្ថាប័នទទួលបន្ទុកដឹកនាំអនុវត្ត និងក្រសួង ស្ថាប័នគាំទ្រ កាលបរិច្ឆេទសម្រាប់ការអនុវត្ត វឌ្ឍនភាព (ជារួមនិងតាមត្រីមាស) កាលបរិច្ឆេទដែលវិធានការត្រូវបានសម្រេចពេញលេញ លទ្ធផលនៃការអនុវត្ត បញ្ហាប្រឈម សំណូមពរ និងឯកសារយោង ជាដើម។ វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ឬក្រុមវិធានការដែលបានដាក់ចេញក្នុងវេទិកាលើកទី១៩ សរុបមានចំនួន១១ និងត្រូវបានបំបែកជាវិធានការលម្អិតតូចៗចំនួន១៨៥។ សនិទានភាពនៃការបំបែកវិធានការទាំងអស់ជាវិធានការលម្អិតតូចៗ ដោយសារវិធានការមួយចំនួន មានវិសាលភាពធំទូលាយនិងមានចរិតលក្ខណៈពហុបំណង ពោលគឺមានគោលបំណង២ឬ៣ ក្នុងវិធានការតែមួយ ដែលធ្វើឱ្យមានការលំបាកក្នុងការវាស់វែងវឌ្ឍនភាព និងអាចធ្វើឱ្យការតាមដានពុំសូវមានសុក្រឹតភាព។

ដើម្បីឱ្យតារាងបណ្ដុំទិន្នន័យ ក្លាយជាឧបករណ៍មួយដ៏ពេញលេញ សម្រាប់ការរៀបចំរបាយការណ៍វឌ្ឍនភាពនេះ ការប្រមូលទិន្នន័យគឺជាជំហានសំខាន់បន្ទាប់មួយ ដែលត្រូវបានធ្វើឡើងតាមរយៈទម្រង់គំរូរបាយការណ៍ ដែលក្រសួង ស្ថាប័នទទួលបន្ទុកដឹកនាំអនុវត្ត បានបំពេញអំពីវឌ្ឍនភាពនៃការអនុវត្តវិធានការដែលបានដាក់ចេញដោយវេទិកាលើកទី១៩ រួចផ្ញើត្រឡប់មកក.អ.ក.វិញ ដើម្បីបូកសរុប សំយោគ វិភាគ និងចងក្រងជារបាយការណ៍វឌ្ឍនភាពនេះឡើង។

យ៉ាងណាមិញ ប្រព័ន្ធនេះ មានសមត្ថភាពត្រឹមតែការតាមដានវឌ្ឍនភាពនៃវិធានការដែលបានដាក់ចេញក្នុងវេទិកាលើកទី១៩ប៉ុណ្ណោះ ដោយពុំទាន់មានសមត្ថភាពតាមដាននិងវាយតម្លៃផ្នែកផ្សេងៗ នៃយន្តការវេទិកា (G-PSF) (ឧទាហរណ៍: ចំនួនកិច្ចប្រជុំនិងចំនួនបញ្ហាដែលបានលើកឡើងក្នុងក្រុមការងារតាមវិស័យទាំងមុននិងក្រោយវេទិកាលើកទី១៩)។ ទោះជាយ៉ាងនេះក្ដី ក.អ.ក. បាននិងកំពុងសហការជាមួយCAPRED ដើម្បីពង្រឹងសមត្ថភាពរបស់ប្រព័ន្ធនេះ ឱ្យក្លាយជាប្រព័ន្ធតាមដាននិងវាយតម្លៃមួយដ៏ពេញលេញ គ្រប់ជ្រុងជ្រោយ ដែលមានភាពបត់បែនខ្ពស់ និងអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ។

## III. វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់

វឌ្ឍនភាពនៃការអនុវត្តវិធានការទាំង១៨៨ នឹងត្រូវតាមដានដោយធ្វើការបែងចែកជាពាក់ម្រិតគឺ បានសម្រេចពេញលេញ (ពណ៌បៃតង) កំពុងត្រូវបានអនុវត្ត (ពណ៌ទឹកក្រូច) និងមិនទាន់ត្រូវបានអនុវត្ត (ពណ៌ក្រហម)។ ផ្នែកនេះនឹងពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តវិធានការជារួម វឌ្ឍនភាពតាមក្រសួង ស្ថាប័នដឹកនាំទទួលបន្ទុកអនុវត្តវិធានការ និងវឌ្ឍនភាពតាមក្រុមវិធានការ។

### ១-វឌ្ឍនភាពជារួម

រូបភាពទី១: វឌ្ឍនភាពរួមនៃការអនុវត្តវិធានការ




ក្រាបក្នុងរូបភាពទី១ បង្ហាញអំពីវឌ្ឍនភាពជារួមនៃការអនុវត្តវិធានការ ដែលក្នុងនោះ វិធានការដែលសម្រេចបានពេញលេញគឺប្រមាណ៥៧%(ស្មើនឹង១០៨វិធានការ) និងកំពុងត្រូវបានអនុវត្ត គឺប្រមាណ៤៣%(ស្មើនឹង៨០វិធានការ)។ ដោយឡែក មិនមានវិធានការណាមួយដែលមិនទាន់ត្រូវបានអនុវត្តឡើយ។

ជារួម វិធានការជាងពាក់កណ្តាល ត្រូវបានសម្រេចពេញលេញត្រឹមរយៈពេល៦ខែដើមឆ្នាំ២០២៤ ដែលតួលេខនេះបង្ហាញថា ការអនុវត្តវិធានការមានវឌ្ឍនភាពល្អប្រសើរគួរឱ្យកត់សម្គាល់។ ដោយឡែក វិធានការជិតពាក់កណ្តាលទៀត គឺកំពុងត្រូវបានអនុវត្ត ព្រោះវិធានការខ្លះ គឺជាវិធានការដែលមានលក្ខណៈជាចរន្ត តម្រូវឱ្យមានការអនុវត្តជាបន្តបន្ទាប់ រីឯវិធានការខ្លះទៀត គឺពុំទាន់ដល់ពេលវេលាកំណត់ត្រូវបញ្ចប់ការអនុវត្ត។ ជាក់ស្តែង វិធានការមួយចំនួន មានកាលបរិច្ឆេទអនុវត្តនៅដំណាច់ឆ្នាំ២០២៤ ឬឆ្នាំបន្តបន្ទាប់ និងមួយចំនួនទៀត មានកាលបរិច្ឆេទកំណត់រយៈពេលមួយអាណត្តិតែម្តង។

យោងតាមសេចក្តីជូនដំណឹងលេខ១២៧២ សជណ.អកទ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីលទ្ធផលនៃវេទិកា G-PSF លើកទី១៩ ក្នុងចំណោមវិធានការដែលបានដាក់ចេញ វិធានការដែលមានក្របខ័ណ្ឌពេលវេលាជាក់លាក់គឺមានប្រមាណត្រឹម៨%  នៃវិធានការសរុប(ស្មើនឹង១៨វិធានការ) ខណៈដែលវិធានការដែលពុំមានក្របខ័ណ្ឌពេលវេលាជាក់លាក់គឺប្រមាណ៩២% នៃវិធានការសរុប(ស្មើនឹង ១៧៨វិធានការ)។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានចង្អុលបង្ហាញឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំសូចនាករគន្លឹះ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត (ដូចមានចែងក្នុងចំណុចលេខ ១១.១)។

## ២-វឌ្ឍនភាពតាមក្រសួង ស្ថាប័នទទួលបន្ទុក

**រូបភាពទី២: វឌ្ឍនភាពតាមក្រសួង ស្ថាប័នទទួលបន្ទុក**




**សម្គាល់÷**

| | |
|---|---|
| ក.ក.ប. | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ក.ដ.ន.ស. | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ក.ទ.ច. | ក្រសួងទេសចរណ៍ |
| ក.ម.ផ. | ក្រសួងមហាផ្ទៃ |
| ក.រ.ថ. | ក្រសួងរ៉ែនិងថាមពល |
| ក.ស.ក. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ក.ស.ក.ដ. | ក្រសួងសាធារណការនិងដឹកជញ្ជូន |
| ក.ស.ហ.វ. | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ក.អ.ក. | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ក.ឧ.វ.ប.ន. | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ធ.ក. | ធនាគារជាតិនៃកម្ពុជា |
| រ.ខ.ព. | រដ្ឋបាលខេត្តព្រះសីហនុ |
| អ.គ.រ. | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា |
| អ.ព.ដ. | អគ្គនាយកដ្ឋានពន្ធដារ |

រូបភាពទី២ បង្ហាញពីបំណែងចែកនិងវឌ្ឍនភាពនៃការអនុវត្តវិធានការតាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល[4] ដែលក្នុងនោះ អគ្គនាយកដ្ឋានពន្ធដារ (៥៦វិធានការ) ទទួលបន្ទុកអនុវត្តវិធានការ

[4] ដើម្បីគាំទ្រដល់ការអនុវត្តវិធានការកែទម្រង់មុតស្រួច ក្រសួង ស្ថាប័នទទួលបន្ទុកបានដាក់ចេញនូវ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានា (ដូចមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី១)

ច្រើនជាងគេលំដាប់ទី១ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៥០វិធានការ) ទទួលបន្ទុកអនុវត្តវិធានការច្រើនជាងគេលំដាប់ទី២។ ដោយឡែក ក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋបាលខេត្តព្រះសីហនុទទួលបន្ទុកអនុវត្តវិធានការតិចជាងគេ (ចំនួន១វិធានការប៉ុណ្ណោះ)។

ចំពោះវឌ្ឍនភាពនៃការអនុវត្តវិធានការ ធនាគារជាតិនៃកម្ពុជា (៥វិធានការ) និងក្រសួងរ៉ែនិងថាមពល (២វិធានការ) សម្រេចបានការអនុវត្តវិធានការពេញលេញ១០០% ដូចគ្នា។ ទន្ទឹមនឹងនោះ អគ្គនាយកដ្ឋានពន្ធដារ (៥៦វិធានការ) និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (២៩វិធានការ) សម្រេចបានការអនុវត្តវិធានការពេញលេញចំនួន៤៨វិធានការ និង២៥វិធានការរៀងគ្នា ស្មើនឹងប្រមាណ៨៦%។

ដោយឡែក ក្រសួង ស្ថាប័នដែលមិនមានវិធានការដែលត្រូវបានសម្រេចពេញលេញសោះ គឺក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋបាលខេត្តព្រះសីហនុ ដែលទទួលបន្ទុកអនុវត្តវិធានការចំនួន១ដូចគ្នា ហើយកំពុងត្រូវបានអនុវត្ត។ រីឯក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(៥០វិធានការ) មានវិធានការដែលកំពុងត្រូវបានអនុវត្តច្រើនជាងគេ គឺចំនួន៣៥វិធានការ ស្មើនឹងប្រមាណ៧០%។

## ៣-វឌ្ឍនភាពតាមក្រុមវិធានការ

រូបភាពទី៣: វឌ្ឍនភាពតាមក្រុមវិធានការ



រូបភាពទី៣ បង្ហាញអំពីវឌ្ឍនភាពនៃការអនុវត្តវិធានការ តាមក្រុមវិធានការដែលមានចែងក្នុងសេចក្តីជូនដំណឹងលេខ១២៧២ សជណ.អកទ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីលទ្ធផលនៃវេទិកាG-PSF លើកទី១៩ ដែលក្នុងនោះមានក្រុមវិធានការចំនួន១១ រួមមាន (១) ការកែសម្រួលបរិយាកាសធុរកិច្ចនិងការវិនិយោគ (១៨វិធានការ) (២) ការសម្រាលបន្ទុកលើអនុលោមភាព (៨វិធានការ) (៣) ការសម្រួលដល់ធុរកិច្ចក្រោមដែនសមត្ថកិច្ចពន្ធដារ (៥២វិធានការ) (៤) កិច្ចសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចគយ (២៩វិធានការ) (៥) ការលើកកម្ពស់ការដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ (១វិធានការ) (៦) ការស្តារនិងការលើកស្ទួយការអភិវឌ្ឍវិស័យទេសចរណ៍ (២២វិធានការ) (៧) ការអភិវឌ្ឍវិស័យកសិកម្មនិងកសិឧស្សាហកម្ម (៧វិធានការ) (៨) វិស័យធនាគារនិងហិរញ្ញវត្ថុ (៤វិធានការ) (៩) វិស័យរ៉ែនិងថាមពល (១៥វិធានការ) (១០) វិស័យសំណង់និងអចលនទ្រព្យ (១៨ វិធានការ) និង (១១) បញ្ហាផ្សេងៗ (១៨វិធានការ)។ ជាការកត់សម្គាល់ក្រុមវិធានការដែលមានវិធានការច្រើនជាងគេគឺក្រុមវិធានការទី៣ «ការសម្រួលដល់ធុរកិច្ចក្រោមដែនសមត្ថកិច្ចពន្ធដារ» និងក្រុមវិធានការដែលមានវិធានការតិចជាងគេគឺក្រុមវិធានការទី៥ «ការលើកកម្ពស់ការដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ»។ ក្រាបខាងលើត្រូវបានរៀបចំតាមលំដាប់នៃក្រុមវិធានការដែលមានវិធានការច្រើនជាងគេ។

បើក្រឡេកមើលពីវឌ្ឍនភាព ក្រុមវិធានការទី៨ ដែលមានវិធានការសរុបចំនួន៤ មានវឌ្ឍនភាពល្អប្រសើរ ព្រោះវិធានការដែលសម្រេចបានពេញលេញគឺ ១០០%។ ជាមួយគ្នានេះ ការអនុវត្តវិធានការដែលស្ថិតនៅក្រុមវិធានការទី៣ (៥២វិធានការ) ដែលមានវិធានការច្រើនជាងគេ សម្រេចបានពេញលេញចំនួន៤២វិធានការ ស្មើនឹងប្រមាណ៨១% ខណៈដែលក្រុមវិធានការទី៤ (២៩វិធានការ) មានវិធានការដែលសម្រេចបានពេញលេញចំនួន២៥វិធានការ ស្មើនឹងប្រមាណ៨៦%។

ដោយឡែក ក្រុមវិធានការដែលមិនមានវិធានការដែលត្រូវបានសម្រេចពេញលេញសោះ គឺក្រុមវិធានការទី៥ ដែលមានវិធានការចំនួន១ ហើយកំពុងត្រូវបានអនុវត្ត។ ជាមួយគ្នានេះ ក្រុមវិធានការដែលមានវិធានការកំពុងត្រូវបានអនុវត្តច្រើនជាងគេ គឺក្រុមវិធានការទី១០ (១៨វិធានការ) ដែលក្នុងនោះវិធានការដែលកំពុងត្រូវបានអនុវត្តមានចំនួន១៦វិធានការ ស្មើនឹងប្រមាណ៨៩%។

## IV. **យន្តការស្ថាប័ន**

### ១- ដំណើរការរៀបចំយន្តការស្ថាប័នសម្រាប់វេទិកា G-PSF

ការរៀបចំយន្តការស្ថាប័ន គឺជាកិច្ចការចាំបាច់បំផុតមួយ ដើម្បីធានានិរន្តរភាពនៃការប្រព្រឹត្តទៅរបស់វេទិកា G-PSF។ ការរៀបចំវេទិកានេះ នាពេលកន្លងមក គឺស្ថិតក្រោមការសម្របសម្រួលដោយ **គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជន** (គ.អ.វ.) ព្រមទាំងមានយន្តការក្រុមការងារតាមវិស័យ ដែលជាវេទិកាកម្រិតបច្ចេកទេសជាន់ខ្ពស់មួយដ៏មានសារៈសំខាន់។ យន្តការក្រុមការងារទាំងនេះ ក៏ផ្តល់លទ្ធភាពសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការស្វែងយល់កាន់តែស៊ីជម្រៅ លើបញ្ហាប្រឈមជាក់លាក់តាមវិស័យដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។ ការណ៍នេះ បានអនុញ្ញាតឱ្យក្រសួង ស្ថាប័ន មានលទ្ធភាពកាន់តែខ្ពស់ ក្នុងការដាក់ចេញនូវវិធានការបន្ថែមចំគោលដៅ មានប្រសិទ្ធភាពខ្ពស់ និងផ្តល់ភាពទន់ភ្លន់ក្នុងការអនុវត្តវិធានការមានស្រាប់មួយចំនួន ដើម្បីដោះស្រាយក្តីកង្វល់ និងបញ្ហាប្រឈមនានារបស់វិស័យឯកជន។

រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី៧ នៃរដ្ឋសភា បានសម្រេចកែសម្រួលវិសាលភាពនៃ គ.អ.វ. ពីការអភិវឌ្ឍវិស័យឯកជនទាំងមូល មកជាការសម្របសម្រួលយន្តការវេទិកា G-PSF ដើម្បីពង្រឹងប្រសិទ្ធភាពនៃការរៀបចំនិងដំណើរការនៃវេទិកានេះ ព្រមទាំងបានផ្លាស់ប្តូរឈ្មោះ គ.អ.វ. ទៅជា «**គណៈកម្មាធិការសម្របសម្រួលការងារសម្រាប់យន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន**» (គ.ស.រ.ជ.) វិញ តាមរយៈអនុក្រឹត្យលេខ៣០៧ អនក្រ.បក. ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣។ គ.ស.រ.ជ. មាន **ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក.អ.ក.** ជាប្រធាន ដោយមានតំណាងក្រសួង ស្ថាប័ន ចំនួន៥ ជាអនុប្រធាន ព្រមទាំងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន២០ទៀត ជាសមាជិក និងមានអគ្គលេខាធិការ-រងគណៈកម្មាធិការវិនិយោគកម្ពុជា (គ.វ.ក.) មួយរូប ជាលេខាធិការ។ គ.ស.រ.ជ. មានតួនាទីនិងភារកិច្ចចម្បងៗដូចជា÷

- ទទួលបន្ទុកកិច្ចការសម្របសម្រួលនិងរៀបចំវេទិកា G-PSF
- រៀបចំបង្កើតក្រុមការងារតាមវិស័យសម្រាប់ពិភាក្សាការងារជាមួយវិស័យឯកជនតាមសេចក្តីត្រូវការចាំបាច់
- ពិនិត្យនិងបែងចែកនូវបញ្ហាប្រឈមនិងសំណូមពរនានាពីវិស័យឯកជន នៅក្រោមយន្តការវេទិកា G-PSF ទៅឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យនិងដោះស្រាយ។ ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវស្ថិតក្រោមសមត្ថកិច្ចដោះស្រាយរបស់ ក.អ.ក./គ.វ.ក.។ ក្នុងករណីបញ្ហាមានចរិតលក្ខណៈជាប្រព័ន្ធ និងជារចនាសម្ព័ន្ធនៃការកែទម្រង់ពាក់ព័ន្ធនឹងគោលនយោបាយឬអន្តរវិស័យ បញ្ហាទាំងនោះត្រូវក្លាយជាកម្មវត្ថុនៃការដោះស្រាយដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.)។ ក្នុងករណី គណៈកម្មាធិការទាំងពីរខាងលើ ពុំអាច

ដោះស្រាយបញ្ហាទាំងនោះបាន ត្រូវគោរពរាយការណ៍ជូននាយករដ្ឋមន្ត្រី ដើម្បីផ្តល់អនុសាសន៍ និងដំណោះស្រាយនៅក្នុងវេទិកា G-PSF

- ទទួលបន្ទុកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានការនានាដែលបានដាក់ចេញនៅក្រោមយន្តការវេទិកា G-PSF។

ជាក់ស្តែង នៅមុនការរៀបចំវេទិកា G-PSF លើកទី១៩ គ.ស.រ.ជ. បានសម្របសម្រួលធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារតាមវិស័យទាំង១៤ ទាំងផ្នែករាជរដ្ឋាភិបាល និងទាំងផ្នែកឯកជន ដើម្បីឱ្យស្របតាមសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងតាមសំណើរបស់សភាពាណិជ្ជកម្មកម្ពុជា។ ជាលទ្ធផល រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចចំនួន២ គឺ ១)- សេចក្តីសម្រេចលេខ១៣១ សសរ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ស្តីពីការតែងតាំងសមាសភាពក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន និង ២)- សេចក្តីសម្រេចលេខ១៣០ សសរ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ស្តីពីការទទួលស្គាល់ជាផ្លូវការនូវសមាសភាពក្រុមការងារទាំង១៤ ផ្នែកឯកជននៃវេទិកា G-PSF។ យន្តការវេទិកានេះ បានពង្រីកវិសាលភាពរបស់ខ្លួនកាន់តែធំឡើងៗ ជាបន្តបន្ទាប់ ពីចំនួន៧ រហូតដល់១៤ក្រុមការងារតាមវិស័យ គិតត្រឹមវេទិកាលើកទី១៩។ បន្ទាប់ពីវេទិកាលើកទី១៩នេះ ក្រុមការងារថ្មីចំនួន២បន្ថែមទៀត ត្រូវបានបង្កើតឡើង គឺក្រុមការងារផ្នែកសេដ្ឋកិច្ច សង្គមឌីជីថល និងទូរគមនាគមន៍ (ក្រុមការងារ «ណ») និងក្រុមការងារផ្នែករដ្ឋបាលដែនដី សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ (ក្រុមការងារ «ត») តាមរយៈសេចក្តីសម្រេចលេខ២៤២ សសរ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានចេញសេចក្តីសម្រេចលេខ៩៦ សសរ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ តែងតាំងសមាសភាពក្រុមការងារតាមវិស័យទាំង២ខាងលើ ដើម្បីធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន និងសេចក្តីសម្រេចលេខ៩៧ សសរ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ ទទួលស្គាល់សមាសភាពក្រុមការងារទាំង១៦ របស់ផ្នែកឯកជន ផងដែរ។

## ២- យន្តការការងារសម្រាប់តាមដាននិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកា G-PSF លើកទី១៩

ដើម្បីជំរុញការងារតាមដាននិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់របស់រាជរដ្ឋាភិបាលដែលបានដាក់ចេញក្នុងវេទិកា G-PSF លើកទី១៩ ក.អ.ក. បានចេញសេចក្តីសម្រេចបង្កើតក្រុមការងារមួយ ទទួលបន្ទុកជាសេនាធិការ ដោយមានការបែងចែកភារកិច្ចច្បាស់លាស់។ ក្រុមការងារនេះ មានភារកិច្ចសំខាន់ៗ ដូចជា ១)- ការរៀបចំប្រព័ន្ធតាមដាន និងវាយតម្លៃមួយដ៏ពេញលេញនិងគ្រប់ជ្រុងជ្រោយ ២)- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីទទួលបានព័ត៌មានអំពីវឌ្ឍនភាព និង ៣)- ប្រមូលសរុបជារបាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់របស់រាជរដ្ឋាភិបាលដែលបានដាក់ចេញក្នុងវេទិកា G-PSF សម្រាប់រាយការណ៍ប្រចាំឆមាសជូនរាជរដ្ឋាភិបាល។

ជាមួយគ្នានេះ សភាពាណិជ្ជកម្មកម្ពុជា ដែលមានតួនាទីជាលេខាធិការដ្ឋានរបស់ផ្នែកឯកជន នៃយន្តការវេទិកានេះ ក៏បានបង្កើតក្រុមការងារកម្រិតខ្ពស់មួយ ដើម្បីពង្រឹងនិងធានាបាននូវប្រសិទ្ធភាពខ្ពស់នៃការសម្របសម្រួល និងការធ្វើការងារកាន់តែជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល។ ក្រុមការងារកម្រិតខ្ពស់នេះ ក៏មានតួនាទីជំរុញការចូលរួមឱ្យបានយ៉ាងផុលផុសពីសមាគមធុរកិច្ចនានា សំដៅពង្រឹងតួនាទីរបស់វិស័យឯកជនក្នុងនាមជាសមភាគីរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច និងវិនិយោគនៅកម្ពុជា។

## V. បញ្ហាប្រឈមនិងអនុសាសន៍

### ១-បញ្ហាប្រឈម

#### ក-ការអនុវត្តវិធានការ

ក្នុងការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់នេះ ក្រសួង ស្ថាប័នពាក់ព័ន្ធបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន និងបានលើកឡើងជាសំណូមពរខាងក្រោម÷

| ក្រសួង ស្ថាប័ន | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|
| ១-ក្រសួងមហាផ្ទៃ | (១) -អ្នកដំណើរនៅពុំទាន់បានយល់ដឹងអំពីការប្រើប្រាស់និងអត្ថប្រយោជន៍របស់ប្រព័ន្ធសលាកបត្រអេឡិចត្រូនិក (Cambodia e-Arrival Card)។<br>-ការចូលរួមសហការផ្សព្វផ្សាយពីការប្រើប្រាស់ និងអត្ថប្រយោជន៍របស់ប្រព័ន្ធខាងលើ ដោយក្រសួង ស្ថាប័នរដ្ឋ ឯកជនពាក់ព័ន្ធ នៅពុំទាន់បានទូលំទូលាយ។ | (១) ចូលរួមគាំទ្រ និងសហការផ្សព្វផ្សាយពីក្រសួង ស្ថាប័នរដ្ឋ ឯកជនពាក់ព័ន្ធ។ |
| | (២) ក្រសួង ស្ថាប័នរដ្ឋ ឯកជនពាក់ព័ន្ធនៅពុំទាន់យល់ដឹងបានទូលំទូលាយ អំពីប្រព័ន្ធទូរសព្ទបន្ទាន់ (GDI Hotline)។ | (២) ចូលរួមគាំទ្រនិងសហការផ្សព្វផ្សាយពីក្រសួង ស្ថាប័នរដ្ឋ ឯកជនពាក់ព័ន្ធ។ |
| | (៣) ខ្វះខាតធនធានក្នុងការរៀបចំប្រព័ន្ធកម្រិតស្តង់ដា (ប្រព័ន្ធស្វ័យប្រវត្តិកម្ម និងប្រព័ន្ធកាមេរ៉ា)។ | (៣) គាំទ្រផ្នែកធនធាន សម្រាប់រៀបចំបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ។ |
| ២-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | (១) មកទល់ពេលនេះភាគីថៃមិនទាន់បានផ្តល់សេចក្តីព្រាងវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីការឆ្លងកាត់ព្រំដែននេះមកកម្ពុជា ដើម្បីសិក្សាបន្តនៅឡើយ។ | (១) ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនឹងបន្តជំរុញ និងតាមដានជាមួយភាគីថៃ។ |
| ៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | (១) វិស័យឯកជននៅមិនទាន់មានភាពជាតំណាងគ្រប់គ្រាន់។ ក្រុមហ៊ុននាំចេញ-នាំចូលកសិផលមិនទាន់ត្រូវបានចូលរួមនៅក្នុងក្រុមការងារពីវិស័យឯកជន។ | (១) ក្រុមការងារវិស័យឯកជនប្រមូលក្រុមហ៊ុននាំចេញ-នាំចូលកសិផលឱ្យចូលរួមនៅក្នុងក្រុមការងារវិស័យឯកជន។ |

| ក្រសួង ស្ថាប័ន | បញ្ហាប្រឈម | សំណូមពរ |
| --- | --- | --- |
| ៤-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | (១) ភាពស្មុគស្មាញនៃជំនាញក្នុងអធិការកិច្ចតាមវិស័យ ដែលតម្រូវឱ្យមានបញ្ជីត្រួតពិនិត្យផ្សេងៗគ្នា និងអធិការជំនាញផ្សេងៗគ្នា។ | (១) ពិនិត្យលទ្ធភាពក្នុងការរៀបចំបញ្ជីត្រួតពិនិត្យដែលមានភាពសាមញ្ញមិនតម្រូវឱ្យមានការផ្តល់ព័ត៌មានស្ទួន និងកាត់បន្ថយអធិការនៅក្នុងពេលចុះអធិការកិច្ច។ |
| | (២) ការសហការជាមួយវិស័យឯកជនក្នុងការជំរុញការចូលរៀនរបស់កម្មករនិយោជិតក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈនៅមានកម្រិត។ | (២) ពង្រឹងកិច្ចសហប្រតិបត្តិការរវាងវិស័យឯកជននិងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជា-ជីវៈ។ |
| | (៣) -ការយល់ដឹងពីកាតព្វកិច្ចហ៊ីកហ៊ើនក្នុនជាងរបស់វិស័យឯកជននៅមានកម្រិត។<br>-ការចុះកម្មសិក្សានៅតាមសហគ្រាស គ្រឹះស្ថានមានរយៈពេលខ្លី ដែលវិស័យឯកជនមានភាពស្ទាក់ស្ទើរក្នុងការទទួលសិស្សកម្មសិក្សាដែលបាននិងកំពុងអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ (១,៥ លាននាក់)។ | (៣) បង្កើនការផ្សព្វផ្សាយ និងការពិគ្រោះយោបល់ជាមួយវិស័យឯកជនអំពីការអនុវត្តកាតព្វកិច្ចហ៊ីកហ៊ើនក្នុនជាង ស្របតាមច្បាប់ការងារ។ |
| | (៤) ការផ្សព្វផ្សាយអំពីនិកាសនៃកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជនក្នុងការផ្តល់ទីតាំងបណ្តុះបណ្តាលនិងគាំទ្រការធ្វើទំនើបកម្មខ្សែច្រវាក់ផលិតកម្មនៅមានកម្រិត។ | (៤) ស្នើសុំបង្កើតនិកាសដើម្បីផ្សព្វផ្សាយ និងចូលរួមជជែកពិភាក្សាជាមួយវិស័យឯកជនលើការអនុវត្តកម្មវិធីបំប៉នសមត្ថភាពជំនាញ ឬផ្លាស់ប្តូរជំនាញដល់កម្មករ និយោជិត។ |
| | (៥) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបច្ចុប្បន្នពុំទាន់មានរចនាសម្ព័ន្ធច្បាស់លាស់។ | (៥) ស្នើសុំវិស័យឯកជនគាំទ្រការពន្លឿនការធ្វើស្ថាបនីយកម្មក្រុមប្រឹក្សាអាជ្ញាកណ្តាល។ |
| ៥-រដ្ឋបាលខេត្តព្រះសីហនុ | ក្រុងកោះរ៉ុងខ្វះខាតមធ្យោបាយក្នុងការចុះធ្វើរដ្ឋបាលចំហ។ | (១) ស្នើសុំឧបករណ៍តេស្តរកសារធាតុញៀន។ |
| | | (២) ក្រុងកោះរ៉ុងស្នើសុំទូកល្បឿនលឿនអ្វប័រ។ |

## ខ. យន្តការស្ថាប័ន

ដូចបានរំលេចក្នុងផ្នែកទី IV យន្តការស្ថាប័ននិងយន្តការចាំបាច់មួយចំនួន ដើម្បីគាំទ្រដំណើរការប្រព្រឹត្តទៅនៃវេទិកា ត្រូវបានរៀបចំរួចរាល់។ យ៉ាងណាមិញ យន្តការស្ថាប័នគាំទ្រជាក់លាក់ដែលមានមុខងារពេញលេញនិងសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើជាសេនាធិការដល់គ.ស.រ.ជ. នៅពុំទាន់បានបង្កើតឡើងនៅឡើយ។ ជាក់ស្តែង យោងតាមអនុក្រឹត្យស្តីពីការបង្កើតគ.ស.រ.ជ. បច្ចុប្បន្នមានសមាសភាពអគ្គលេខាធិការរង គ.វ.ក. នៃ ក.អ.ក. ១រូប ជាលេខាធិការ ដោយគ.ស.រ.ជ. ពុំទាន់មានលេខាធិការដ្ឋានធ្វើជាសេនាធិការនិងជំនួយការ សម្រាប់អនុវត្តភារកិច្ចរបស់ខ្លួនឡើយ។ កត្តានេះ នាំឱ្យ ក.អ.ក. មានភាពចាំបាច់ក្នុងការបង្កើតក្រុមការងារដែលមានលក្ខណៈបណ្តោះអាសន្ន (ad hoc) ធ្វើជាជំនួយការលើការងារតាមដាននិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាលើកទី១៩។ ក្រុមការងារខាងលើ ជាកម្លាំងប្រមូលផ្តុំក្នុងចំណោមឧត្តមមន្ត្រី និងមន្ត្រីដែលទទួលបន្ទុកបំពេញការងារស្នូលជូន ក.អ.ក./គ.វ.ក. ទៅតាមតួនាទីនិងភារកិច្ចរៀងខ្លួនៗ និងជូនយន្តការស្ថាប័នផ្សេងៗទៀត ជាហេតុនាំឱ្យការរៀបចំវេទិកា និងការតាមដាននិងវាយតម្លៃ ជួបប្រទះនូវការលំបាកនិងនៅមានកម្រិតនៅឡើយ។

បន្ថែមលើនេះ ការរៀបចំប្រព្រឹត្តទៅនៃយន្តការវេទិកាទាំងមូល នៅមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលធ្វើឱ្យយន្តការវេទិកានេះ ពុំទាន់សម្រេចបាននូវប្រសិទ្ធភាពពេញលេញនៅឡើយ។ មូលហេតុចម្បងៗ បណ្តាលមកពីបញ្ហាប្រឈម ពាក់ព័ន្ធនឹង÷

១)- របបកិច្ចប្រជុំ និងការរាយការណ៍របស់ក្រុមការងារតាមវិស័យពុំទាន់មានភាពច្បាស់លាស់។

២)- នីតិវិធីនៃការបញ្ជូនបញ្ហា និងការផ្តល់ធាតុចូលលើដំណោះស្រាយបញ្ហា ដែលពាក់ព័ន្ធនឹងអន្តរក្រសួង ស្ថាប័ន ទៅតួអង្គពាក់ព័ន្ធ ដែលមានសមត្ថកិច្ចនិងភារកិច្ចដោះស្រាយនៅមានកម្រិត។ និង

៣)- កង្វះការតាមដាននិងផ្តល់សេចក្តីជូនដំណឹងពីវឌ្ឍនភាពនៃការបញ្ជូននិងដោះស្រាយបញ្ហាត្រឡប់ទៅផ្នែកឯកជនដែលបានលើកបញ្ហា។

### គ- ការរៀបចំនិងអនុវត្តប្រព័ន្ធតាមដាននិងវាយតម្លៃ

ការរៀបចំនិងអនុវត្តប្រព័ន្ធតាមដាននិងវាយតម្លៃ ដើម្បីតាមដានវឌ្ឍនភាពនៃវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកា G-PSF លើកទី១៩ ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម÷

១)- គ្រប់ខណ្ឌពេលវេលា និងធនធានមនុស្ស របស់ក.អ.ក. នៅមានកម្រិត ដោយក.អ.ក. មានរយៈពេលខ្លីក្នុងការអភិវឌ្ឍប្រព័ន្ធ និងរៀបចំរបាយការណ៍វឌ្ឍនភាព ហេតុនេះ ការរៀបចំប្រព័ន្ធតាមដាននិងវាយតម្លៃនេះ នៅពុំទាន់មានមុខងារពេញលេញនៅឡើយ ហើយការវិភាគក៏នៅមានកម្រិត។

២)- ប្រព័ន្ធបច្ចុប្បន្នពុំទាន់មានសមត្ថភាពគ្របដណ្តប់ការវាយតម្លៃ ឬបង្ហាញអំពីមតិរបស់វិស័យឯកជនលើប្រសិទ្ធភាពនៃយន្តការវេទិកា G-PSF ព្រមទាំងប្រសិទ្ធភាពនៃការដាក់ចេញនិងអនុវត្តវិធានការដែលបានដាក់ចេញនៅឡើយ។ និង

៣)- ប្រព័ន្ធនេះពុំទាន់ត្រូវបានរៀបចំក្នុងទម្រង់ឌីជីថលរួមមួយលើថ្នាលបច្ចេកវិទ្យាណាមួយ ដែលអាចអនុញ្ញាតឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ អាចបញ្ចូលទិន្នន័យបានដោយខ្លួនឯងនៅឡើយ។ ហេតុនេះការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធត្រូវការចំណាយពេលវេលាច្រើន និងតម្រូវឱ្យមានការផ្ទៀងផ្ទាត់ជាច្រើនលើកច្រើនសារ ដើម្បីកាត់បន្ថយកំហុសឆ្គង និងភាពមិនត្រឹមត្រូវដែលអាចកើតឡើងជាយថាហេតុ។

## ២-អនុសាសន៍

### ក- ការពង្រឹងការអនុវត្តវិធានការ

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការ កិច្ចការមួយចំនួនគួរត្រូវបានអនុវត្ត រួមមាន÷

១)- ក្រសួង ស្ថាប័ន គួរបញ្ចូលវិធានការដែលខ្លួនទទួលបន្ទុក ទៅក្នុងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួន និងបង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍ ដើម្បីទទួលបាននូវហិរញ្ញប្បទាន ឧបករណ៍បច្ចេកទេស និងជំនួយបច្ចេកទេសនានា (រួមបញ្ចូលទាំងការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពស្ថាប័ន) សម្រាប់ជំរុញការអនុវត្តវិធានការ។

២)- ក្រសួង ស្ថាប័ន គួររៀបចំផែនការសកម្មភាពក្នុងការអនុវត្តវិធានការ ដោយធ្វើអាទិភាវូបនីយកម្មលើវិធានការដែលត្រូវអនុវត្ត និងជំរុញការដោះស្រាយបញ្ហាប្រឈមឱ្យបានឆាប់រហ័សនិងមានប្រសិទ្ធផលខ្ពស់ឱ្យអស់ពីលទ្ធភាព តាមរយៈការបង្កើនការសម្របសម្រួល និងការផ្តល់ការលើកទឹកចិត្ត។

៣)- ក្រសួង ស្ថាប័នពាក់ព័ន្ធគួរកំណត់ក្របខ័ណ្ឌពេលវេលាសម្រាប់ការដាក់ចេញ និងអនុវត្តវិធានការ និងសូចនាករឱ្យបានច្បាស់លាស់ អនុលោមតាមសេចក្តីជូនដំណឹងលេខ១២៧២ សជណ.អកទ ស្តីពីលទ្ធផលនៃវេទិកា G-PSF លើកទី១៩។

៤)- ក្រុមការងារតាមវិស័យ គួរខិតខំបញ្ជ្រាបនិងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីលទ្ធផលនៃកិច្ចប្រជុំកម្រិតក្រុមការងារតាមវិស័យ និងលទ្ធផលនៃវេទិកាតាមរយៈពហុប្រព័ន្ធផ្សព្វផ្សាយ និងសិក្ខាសាលានានា។ និង

៥)- ការលើកទឹកចិត្តឱ្យវិស័យឯកជនប្រើប្រាស់យន្តការវេទិកា G-PSFជាច្រកអាទិភាពក្នុងការលើកបញ្ហាប្រឈម ក្តីកង្វល់ និងសំណូមពរនានា។

**ខ-ការធ្វើឱ្យប្រសើរឡើងនូវយន្តការស្ថាប័ន**

តាមរយៈមេរៀន បទពិសោធ និងលទ្ធផលដែលទទួលបានពីរបកគំហើញនៃរបាយការណ៍នេះ កិច្ចការចាំបាច់មួយចំនួនគួរត្រូវបានអនុវត្ត ដើម្បីធានាប្រសិទ្ធភាពនៃយន្តការស្ថាប័នសម្រាប់វេទិការួមមាន÷

១)- ការដំឡើងកម្រិតមុខងារនៃក្រុមការងារតាមដាននិងវាយតម្លៃលើវឌ្ឍនភាព នៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់នៃ ក.អ.ក. ទៅជាលេខាធិការដ្ឋានពេញសមត្ថភាព ជាសេនាធិការឱ្យ គ.ស.រ.ជ. ដើម្បីអនុវត្តភារកិច្ចនានាដែលរាជរដ្ឋាភិបាលបានប្រគល់ជូន និងបំពេញការងារចាំបាច់មួយចំនួនបន្ថែមទៀត តាមការប្រគល់ភារកិច្ចជាបន្តបន្ទាប់ពី គ.ស.រ.ជ. ជាពិសេសលើការងាររៀបចំវេទិកា និងការងារតាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការមុតស្រួចជាកញ្ចប់។

២)- ការរៀបចំនិងដាក់ឱ្យប្រើប្រាស់នូវសៀវភៅណែនាំស្តីពីស្តង់ដានីតិវិធីប្រតិបត្តិ ដែលមានចែងច្បាស់លាស់អំពីរបបនៃកិច្ចប្រជុំ របបនៃការរាយការណ៍លទ្ធផលកិច្ចប្រជុំ នីតិវិធីក្នុងការបញ្ជូនបញ្ហាដែលពុំអាចដោះស្រាយបានឬពាក់ព័ន្ធទៅនឹងក្រុមការងារនៃវិស័យដទៃ ចំណាត់ការចំពោះបញ្ហាដែលពុំមានវិធានការដោះស្រាយ និងតួនាទីភារកិច្ចរបស់តួអង្គពាក់ព័ន្ធ។ និង

៣)- ការបង្កើតលេខាធិការដ្ឋានតាមក្រុមការងារតាមវិស័យនីមួយៗ ដែលមានសមាសភាពចាត់តាំងដោយសហប្រធាននៃក្រុមការងារតាមវិស័យ ដើម្បីទទួលបន្ទុកលើការរៀបចំកិច្ចប្រជុំ ទំនាក់ទំនងនិងសម្របសម្រួលការងារ សម្របសម្រួលលើការសិក្សាស្រាវជ្រាវ និងផ្តល់ធាតុចូលបច្ចេកទេស លើដំណោះស្រាយចំពោះបញ្ហាប្រឈមដែលបានលើកឡើង, តាមដានវឌ្ឍនភាពនៃការបញ្ជូននិងការដោះស្រាយបញ្ហាប្រឈម, រៀបចំរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំឬកំណត់ហេតុកិច្ចប្រជុំ និងរាយការណ៍ជូនតួអង្គពាក់ព័ន្ធ ជាដើម។

## ឥ- ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតាមដាននិងវាយតម្លៃ

ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតាមដាននិងវាយតម្លៃ វិស័យឯកជននិងភាគីរាជរដ្ឋាភិបាល បានលើកឡើងនូវសំណូមពរមួយចំនួន ដូចខាងក្រោម ÷

១)- រៀបចំប្រព័ន្ធតាមដាននិងវាយតម្លៃ ដែលមានលក្ខណៈពេញលេញមួយ ដោយមិនត្រឹមតែអាចប្រើប្រាស់ក្នុងការតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការប៉ុណ្ណោះទេ ថែមទាំងអាចវាយតម្លៃលើផលជះផងដែរ។

២)- បញ្ចូលវិស័យឯកជនទៅក្នុងដំណើរការនៃការតាមដាននិងវាយតម្លៃ ដោយរំលេចពីមតិនិងការវាយតម្លៃរបស់វិស័យឯកជនលើប្រសិទ្ធភាពនៃយន្តការវេទិកា G-PSF ទាំងមូល ព្រមទាំងប្រសិទ្ធភាពនៃការដាក់ចេញនិងអនុវត្តវិធានការ។

៣)- រៀបចំថ្នាលបច្ចេកវិទ្យានិងក្រុមការងារអន្តរក្រសួង ស្ថាប័នកម្រិតបច្ចេកទេស ដើម្បីបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ បន្ទាប់ពីសហប្រធាននៃក្រុមការងារតាមវិស័យឯកភាពគ្នាទៅលើខ្លឹមសារដែលត្រូវបញ្ចូលទៅក្នុងប្រព័ន្ធ។

៤)- រៀបចំជាសៀវភៅណែនាំអំពីរបៀបប្រើប្រាស់និងបញ្ចូលទិន្នន័យទៅក្នុងថ្នាលបច្ចេកវិទ្យា និងសិក្ខាសាលាបណ្តុះបណ្តាល ជូនទៅភាគីពាក់ព័ន្ធ។

៥)- ពង្រីកវិសាលភាពនៃការតាមដាននិងវាយតម្លៃ លើបញ្ហាដែលបានលើកឡើងនៅកម្រិតក្រុមការងារតាមវិស័យដើម្បីបង្កើនទំនុកចិត្តដល់ធុរជននិងវិនិយោគិន។ និង

៦)- បោះពុម្ពផ្សាយនិងផ្សព្វផ្សាយនូវលទ្ធផលនៃការតាមដាននិងវាយតម្លៃ ព្រមទាំងឯកសារនិងព័ត៌មានពាក់ព័ន្ធទាំងអស់ ក្នុងទម្រង់អនឡាញ ដែលអនុញ្ញាតឱ្យតួអង្គពាក់ព័ន្ធនិងសាធារណជនទាំងអស់ អាចចូលទាញយកនិងពិនិត្យបាន។

## VI. សេចក្តីសន្និដ្ឋាននិងទិសដៅការងារបន្ត

របាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកា G-PSF លើកទី១៩ ប្រចាំឆមាសទី១ ឆ្នាំ២០២៤ ត្រូវបានរៀបចំឡើងដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការ ដែលមានចែងក្នុងសេចក្តីជូនដំណឹងលេខ១២៧២ សជណ.អកទ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីលទ្ធផលនៃវេទិកា G-PSF លើកទី១៩ ហើយដែលវេទិកានេះ ត្រូវបានរៀបចំឡើងដោយជោគជ័យកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤ និងជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រថ្មីមួយ សម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការដឹកនាំវេទិកានេះជាលើកទី១ ទន្ទឹមគ្នាពីការបង្ហាញនូវភាពបន្ទាន់និងចាំបាច់នៃរបៀបវារៈសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលនៅក្នុងអាណត្តិថ្មីនេះ ដែលមានបំណងរៀបចំការធ្វើដំណើររួមគ្នារវាងរាជរដ្ឋាភិបាល-ផ្នែកឯកជន ឱ្យកាន់តែមានភាពស៊ីចង្វាក់គ្នានិងមានភាពសុខដុម។ ក្នុងការតិតតួររៀបចំរបាយការណ៍វឌ្ឍនភាពនេះ មានក្រុមវិធានការចំនួន១១ ដែលមាននៅក្នុងសេចក្តីជូនដំណឹង ត្រូវបានយកមកធ្វើការពិនិត្យ វិភាគ និងធ្វើការបែងចែកជាវិធានការចំនួន១៨៨។ វិធីសាស្ត្របែបបរិមាណវិស័យត្រូវបានប្រើប្រាស់ ដែលការតាមដានវឌ្ឍនភាពត្រូវបានកំណត់ជាពាក្យម្រិត គឺសម្រេចបានពេញលេញ កំពុងត្រូវបានអនុវត្ត និងមិនទាន់ត្រូវបានអនុវត្ត តាមរយៈការប្រើប្រាស់ប្រព័ន្ធតាមដានការអនុវត្តវិធានការវេទិកា G-PSF លើកទី១៩ (G-PSF Tracking System)។

បើក្រឡេកមើលពីលទ្ធផលនៃការតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការទាំង១៨៨ សង្កេតឃើញថា វិធានការជាងពាក់កណ្តាល ត្រូវបានសម្រេចពេញលេញត្រឹមរយៈពេល៦ខែ ដើមឆ្នាំ២០២៤ ដែលតួលេខនេះបង្ហាញថា ការអនុវត្តវិធានការមានវឌ្ឍនភាពល្អប្រសើរគួរឱ្យកត់សម្គាល់។ ជាមួយគ្នានេះ វិធានការទាំងអស់សុទ្ធតែត្រូវបានចាប់ផ្តើមអនុវត្ត ដោយក្នុងនោះមានវិធានការយ៉ាងតិចមួយ ត្រូវបានសម្រេចពេញលេញដោយក្រសួង ស្ថាប័នភាគច្រើន។ ទោះជាយ៉ាងណា វិធានការជិតពាក់កណ្តាលទៀត កំពុងត្រូវបានអនុវត្តនៅឡើយ ដែលទាមទារឱ្យក្រសួង ស្ថាប័ន ពន្លឿនបញ្ចប់ការអនុវត្តវិធានការទាំងនោះ ជាពិសេសវិធានការដែលពុំមានលក្ខណៈជាចរន្ត។

ឈរលើលទ្ធផលនៃការតាមដាននិងវាស់វែងវឌ្ឍនភាពខាងលើ បញ្ហាប្រឈមនិងអនុសាសន៍ជាក់លាក់មួយចំនួនត្រូវបានរៀបចំនិងបញ្ចូលក្នុងរបាយការណ៍នេះ។ ក្នុងន័យនេះ របាយការណ៍តាមដានវឌ្ឍនភាពនេះ គឺជាឯកសារមូលដ្ឋានសម្រាប់ជូនរាជរដ្ឋាភិបាលពិនិត្យ ពិចារណាក្នុងការតម្រង់ទិស និងពន្លឿនការអនុវត្តវិធានការដែលនៅសេសសល់ ព្រមទាំងដាក់ចេញវិធានការបន្ថែមដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមដែលបានលើកឡើង។ របាយការណ៍នេះ ក៏ផ្តល់ព័ត៌មានជូនវិស័យឯកជនពីវឌ្ឍនភាព និងគណនេយ្យភាពរបស់ក្រសួង ស្ថាប័នក្នុងការអនុវត្តវិធានការក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីឱ្យវិស័យឯកជនមានព័ត៌មានគ្រប់ជ្រុងជ្រោយពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនិងវិនិយោគ សំដៅជំរុញឱ្យវិស័យឯកជន បន្តបណ្តាក់ទុនវិនិយោគនិងពង្រីកការវិនិយោគបន្ថែមទៀតនៅកម្ពុជា។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបានលើកឡើង និងតាមរយៈអនុសាសន៍ដូចបានរំលេចខាងលើ ក្នុងរយៈពេលខ្លីខាងមុខ គ.ស.រ.ជ. នឹងអនុវត្តការងារមួយចំនួន ដូចជា (១) បង្កើតលេខាធិការដ្ឋានមួយចំណុះឱ្យ ក.អ.ក./គ.វ.ក. ជាសេនាធិការនៃគ.ស.រ.ជ. (២) រៀបចំនិងដាក់ឱ្យប្រើប្រាស់នូវសៀវភៅណែនាំ ស្តីពីស្តង់ដានីតិវិធីប្រតិបត្តិនៃការរៀបចំនិងប្រព្រឹត្តទៅនៃយន្តការវេទិកា G-PSF (៣) ផ្សព្វផ្សាយលទ្ធផលនៃរបាយការណ៍នេះ (៤) បន្តសហការជាមួយ CAPRED ដើម្បីរៀបចំប្រព័ន្ធតាមដាននិងវាយតម្លៃមួយដែលពេញលេញ និង (៥) បញ្ចូលមតិយោបល់និងការវាយតម្លៃផ្នែកឯកជនលើប្រសិទ្ធភាពយន្តការនិងការអនុវត្តវិធានការ។

ក្នុងរយៈពេលវែង គ.ស.រ.ជ. នឹង (១) រៀបចំថ្នាលបច្ចេកវិទ្យា ដើម្បីក្រសួង ស្ថាប័នរាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងរៀបចំជាសៀវភៅណែនាំ និងសិក្ខាសាលាបណ្តុះបណ្តាល ដល់ភាគីពាក់ព័ន្ធស្តីពីការបញ្ចូលទិន្នន័យ (២) ពង្រីកវិសាលភាពនៃការតាមដាននិងវាយតម្លៃ លើបញ្ហាដែលបានលើកឡើងតាមក្រុមការងារតាមវិស័យ និង (៣) សហការជាមួយវិស័យឯកជនបង្កើតគេហទំព័រមួយសម្រាប់យន្តការវេទិកា G-PSF ដើម្បីផ្សព្វផ្សាយពីយន្តការនេះ និងផ្តល់ភាពងាយស្រួលដល់វិស័យឯកជននិងអង្គពាក់ព័ន្ធក្នុងការស្វែងរកព័ត៌មាន។

# បញ្ជីពាក្យកាត់

## បញ្ជីពាក្យកាត់សំខាន់ៗជាភាសាខ្មែរ

| | |
|---|---|
| ក.ក.ប. | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ក.ដ.ន.ស. | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ក.ទ.ច. | ក្រសួងទេសចរណ៍ |
| ក.ម.ផ. | ក្រសួងមហាផ្ទៃ |
| ក.រ.ថ. | ក្រសួងរ៉ែនិងថាមពល |
| ក.ស.ក. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ក.ស.ក.ដ. | ក្រសួងសាធារណការនិងដឹកជញ្ជូន |
| ក.ស.ហ.វ. | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ក.អ.ក. | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ក.ឧ.វ.ប.ន. | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| គ.វ.ក. | គណៈកម្មាធិការវិនិយោគកម្ពុជា |
| គ.អ.វ | គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជន |
| គ.ស.ហ. | គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| គ.ស.វ.ជ. | គណៈកម្មាធិការសម្របសម្រួលការងារសម្រាប់យន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន |
| ធ.ក. | ធនាគារជាតិនៃកម្ពុជា |
| រ.ខ.ព. | រដ្ឋបាលខេត្តព្រះសីហនុ |
| អ.គ.រ. | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា |
| អ.ព.ដ. | អគ្គនាយកដ្ឋានពន្ធដារ |

## បញ្ជីពាក្យកាត់សំខាន់ៗជាភាសាបរទេស

| | | |
|---|---|---|
| CAPRED | Cambodia Australia Partnership for Resilient Economic Development | កម្មវិធីភាពជាដៃគូកម្ពុជាអូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ |
| G-PSF | Government-Private Sector Forum | វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន |
| IDP | Cambodia Industrial Development Policy | គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |

## បរិសិដ្ឋ

**បរិសិដ្ឋទី១:** បញ្ជីឯកសារកំណែទម្រង់បទប្បញ្ញត្តិ ការដាក់ចេញគោលនយោបាយ និងឯកសារពាក់ព័ន្ធផ្សេងៗ របស់ក្រសួង ស្ថាប័ន ឆ្លើយតបទៅនឹងវិធានការ ដែលបានដាក់ចេញដោយវេទិកា G-PSF លើកទី១៩

| ល.រ | កំណែទម្រង់បទប្បញ្ញត្តិ ការដាក់ចេញគោលនយោបាយ និងឯកសារពាក់ព័ន្ធផ្សេងៗ |
|---|---|
| **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | |
| ១ | ប្រកាសលេខ០៥៤/២៤ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងាររៀបចំក្រុមអធិការកិច្ចអន្តរក្រសួង របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២ | ប្រកាសអន្តរក្រសួងលេខ៣៤៦/២២ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួងក្នុងវិស័យកម្មន្តសាល របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៣ | ប្រកាសអន្តរក្រសួងលេខ០៦៤/២១ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួងក្នុងវិស័យកសិកម្ម របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៤ | ប្រកាសអន្តរក្រសួងលេខ០៦៥/២១ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួងក្នុងវិស័យឧស្សាហកម្មទេសចរណ៍ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៥ | ប្រកាសអន្តរក្រសួងលេខ០៦៣/២៤ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួងក្នុងវិស័យសំណង់ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៦ | ប្រកាសលេខ៧១៩ ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | |
|---|---|
| ៧ | សេចក្តីជូនដំណឹងលេខ០១៧/២៤ ក.ប/ស.ជ.ណ.ខ.ល ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ ស្តីពីការបន្ថែមម៉ោងធ្វើការ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៨ | អនុក្រឹត្យលេខ៣២៩ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការអនុវត្តកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៩ | សេចក្តីសម្រេចលេខ ០៨៧/២៣ ក.ប/សសរ.គគស ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១០ | ប្រកាសលេខ៣៨២/២៣ ក.ប/ប្រ.ក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងាររៀបចំយន្តការវាយតម្លៃសហគ្រាសម្ហូយ ជាសហគមន៍សុខសាន្តមួយ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១១ | ប្រកាសលេខ៣៩៤/២៣ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១២ | ប្រកាសលេខ០៩៧/២៤ ក.ប/ប្រ.ក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ ស្តីពីលក្ខណៈវិនិច្ឆ័យផ្តល់ពានរង្វាន់សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ ប្រចាំ ឆ្នាំ២០២៥ សម្រាប់វិស័យវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១៣ | សេចក្តីសម្រេចលេខ០៥៦/២៤ ក.ប/សសរ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃនិងជ្រើសរើសសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | |
| ១ | លិខិតលេខ៥៦៤សជណ.ដប ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីករណីរបាយការណ៍ស្តីពីលទ្ធផលនៃការដោះស្រាយបាតុភាពលក់ទិញដីឡូត៍និងផ្ទះក្នុងបុរី VIP ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងខេត្តព្រះសីហនុ របស់ទីស្តីការគណៈរដ្ឋមន្ត្រី |

| | |
|---|---|
| ២ | សេចក្តីជូនដំណឹង ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់អគាររោងចក្រ និងឃ្លាំង របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ៣ | លិខិតចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ស្តីពីសំណើសុំគោលការណ៍លើកលែងការពិន័យអន្តរការណ៍ ចំពោះម្ចាស់សំណង់ដែលមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ សម្រាប់សំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតសាងសង់ ឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន |
| ៤ | សេចក្តីសម្រេចលេខ០៧ សសរ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាលកម្ពុជា |
| ៥ | សេចក្តីជូនដំណឹង ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការអនុវត្តកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ៦ | សេចក្តីសម្រេចលេខ០១៦ សសរ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងផ្តល់លិខិតអនុញ្ញាតនិងវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចំពោះសំណង់អគារនៅខេត្តព្រះសីហនុ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ៧ | សេចក្តីជូនដំណឹងលេខ០០៧ ដនស/អសណ/សជណ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការលើកលែងការបង់ថ្លៃសេវាសាធារណៈ ចំពោះគម្រោងវិនិយោគក្នុងខេត្តព្រះសីហនុ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ៨ | លិខិតលេខ២៨២ សជណ.ដប ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ ស្តីពីករណីស្នើសុំគោលការណ៍អនុវត្តលក្ខខណ្ឌដោយឡែកផ្នែកនគរូបនីយកម្មនិងសំណង់ ដើម្បីចូលរួមអនុវត្តកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុឱ្យមានប្រសិទ្ធភាព របស់ទីស្តីការគណៈរដ្ឋមន្ត្រី |
| **ក្រសួងទេសចរណ៍** | |
| ១ | អនុក្រឹត្យលេខ២៥អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សានិងស្រាវ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា របស់រាជរដ្ឋាភិបាល |

| | |
|---|---|
| ២ | សេចក្តីសម្រេចលេខ១៨៦សសរ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងាររៀបចំយុទ្ធនាការ «ទស្សនាសៀមរាប ឆ្នាំ២០២៤» «ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា ចិន ២០២៤» និង «ឆ្នាំទេសចរណ៍កម្ពុជា ឥណ្ឌា លើកទី១ ២០២៤» របស់ក្រសួងទេសចរណ៍ |
| ៣ | ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៤-២០២៦របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នា២០២៣ |
| ៤ | សេចក្តីជូនដំណឹងលេខ៥០៣ សជណ.អកឱ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការលើកលែងការពិន័យអន្តរការណ៍ជាប្រាក់ចំពោះការហួសសុពលភាពអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ របស់ក្រសួងទេសចរណ៍ |
| ៥ | លិខិតលេខ១៥១ សជណ.ពន ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ស្តីពីករណីគោរពស្នើសុំគោលការណ៍អនុញ្ញាតនិងសូមគោរពអញ្ជើញ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត មេត្តាចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងកម្មវិធី បើកជាផ្លូវការពិធីបុណ្យទន្លេលើកទី៨ នៅខេត្តសៀមរាប ចុងសប្តាហ៍ទី២ឬសប្តាហ៍ទី៣ នៃខែមីនា ឆ្នាំ២០២៤ ក្រោមប្រធានបទទន្លេដើម្បីសន្តិភាពនិងការអភិវឌ្ឍ របស់ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៦ | លិខិតលេខ៥២៥ សជណ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤ ស្តីពីករណីគោរពស្នើសុំការអនុញ្ញាតជាគោលការណ៍ដ៏ខ្ពង់ខ្ពស់ រៀបចំព្រឹត្តិការណ៍ពិព័រណ៍វប្បធម៌ទេសចរណ៍និងព្រឹត្តិការណ៍ "When Shaolin Meets Bokator At Angkor" នៅបរិវេណខាងជើងប្រាសាទបាយ័ន នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៧ | បច្ចុប្បន្នភាពស្តង់ដាទីក្រុងស្អាត |
| ៨ | អនុក្រឹត្យលេខ៥១អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ របស់រាជរដ្ឋាភិបាល |
| **ក្រសួងមហាផ្ទៃ** | |
| ១ | សេចក្តីសម្រេចលេខ៤៦៨៦ សសរ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការផ្អាកសកម្មភាពស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបផលិតផលក្លែងក្លាយ ស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ |

| | |
|---|---|
| ២ | លិខិតលេខ២៦៤០ សជណ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ ស្តីពីការពង្រឹងការគ្រប់គ្រងនិងការត្រួតពិនិត្យការចេញ ចូលឆ្លងកាត់ព្រំដែន |
| ៣ | លិខិតលេខ២១៦៨ លស ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីសុំជូនដំណឹងទៅភាគីថៃអំពីការងារពាក់ព័ន្ធនឹងបណ្ណព្រំដែន |
| ៤ | លិខិតលេខ៣៣៦៧ សជណ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការពង្រីកវិសាលភាពធ្វើដំណើរសម្រាប់ប្រជាពលរដ្ឋថៃរស់នៅខេត្តជាប់ព្រំដែនជាមួយប្រទេសកម្ពុជា អាចប្រើប្រាស់បណ្ណព្រំដែនធ្វើដំណើរមកដល់ខេត្តសៀមរាបបានក្នុងគោលដៅទេសចរណ៍ |
| ៥ | លិខិតលេខ៣៨៤៤ សជណ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីសំណើចាត់សមាសភាពចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការដាក់ឱ្យអនុវត្តសាកល្បងការផ្តល់សេវាបណ្ណព្រំដែនកម្ពុជា ថៃនៅរដ្ឋបាលក្រុង ស្រុកនៃខេត្តជាប់ព្រំដែនជាមួយថៃ |
| ៦ | លិខិតលេខ០២៤ លស ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤ ស្តីពីសំណើសុំគោលការណ៍អនុញ្ញាតសិក្សារៀបចំធ្វើវិសោធនកម្មកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការឆ្លងកាត់ព្រំដែន |
| ៧ | សេចក្តីសម្រេចលេខ៣៥ សសរ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម |
| ៨ | សេចក្តីសម្រេចលេខ៩៣ សសរ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាពនិងសុវត្ថិភាពសង្គម |
| ៩ | លិខិតលេខ១១៥៣០ កបទ-សអ/ ច្បក៤ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីជំហររបស់ភាគីថៃលើការអនុញ្ញាតរបស់កម្ពុជាឱ្យពលរដ្ឋថៃប្រើប្រាស់បណ្ណព្រំដែនចូលមកកាន់ខេត្តសៀមរាបក្នុងគោលដៅទេសចរណ៍ |
| ១០ | លិខិតលេខ២៣៩២ (ភាសាអង់គ្លេស) ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការប្រើប្រាស់បណ្ណព្រំដែន ចូលមកកាន់ខេត្តសៀមរាប ក្នុងគោលដៅទេសចរណ៍ |
| **ក្រសួងរ៉ែនិងថាមពល** | |
| ១ | សារាចរលេខ០៣១០ រថ.អធរ. សរច ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ ស្តីពីវិធានការចំពោះការដឹកជញ្ជូនរ៉ែសំណង់គ្រប់ប្រភេទ របស់ក្រសួងរ៉ែនិងថាមពល |

| | |
|---|---|
| ២ | សេចក្តីជូនដំណឹងលេខ០០០៥ រថ.នក.សជណ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការនាំចេញផលិតផលរ៉ែឬបុគ្គលមានបំណងស្នើសុំបញ្ជាក់សំណាករ៉ែរបស់ក្រសួងរ៉ែនិងថាមពល |
| ៣ | សេចក្តីណែនាំលេខ០០០៦ រថ.នក.សណន ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីនីតិវិធីនៃកិច្ចដំណើរការក្នុងការអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ និងសំណាករ៉ែតាមប្រព័ន្ធបញ្ជរតែមួយជាតិ |
| ៤ | ប្រកាសលេខ០១២៦ រថ.បគអថ.ប្រក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការកំណត់ទំហំប្រព័ន្ធ និងទំហំកូតានៃថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា របស់ក្រសួងរ៉ែនិងថាមពល |
| ៥ | អនុក្រឹត្យលេខ២៩៩ អនក្រ.បក ស្តីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញថ្មធម្មជាតិ |
| ៦ | របាយការណ៍ស្តីពីកិច្ចប្រជុំពិនិត្យវឌ្ឍនភាពការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ នៃការដោះស្រាយបញ្ហាប្រឈមរបស់ផ្នែកឯកជន នៃក្រុមការងារ «ញ» ផ្នែកថាមពលនិងធនធានរ៉ែ |
| **អាជ្ញាធរអគ្គិសនីកម្ពុជា** | |
| ១ | លិខិតលេខ០៤០.សរ.២៤ អអក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ ស្តីពីបទប្បញ្ញត្តិស្តីពីការដំឡើងនិងការប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា របស់អាជ្ញាធរអគ្គិសនីកម្ពុជា |
| ២ | លិខិតលេខ០៤១.សរ.២៤ អអក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ ស្តីពីនីតិវិធីសម្រាប់ការចេញ កែសម្រួល ព្យួរ ដកហូត ឬបដិសេធអាជ្ញាបណ្ណផលិតកម្មសម្រាប់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា របស់អាជ្ញាធរអគ្គិសនីកម្ពុជា |

| | |
|---|---|
| **អគ្គិសនីកម្ពុជា** | |
| ១ | សេចក្តីសម្រេចលេខ០៩៤.សរ.២៣អអក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការបញ្ចុះថ្លៃអគ្គិសនីចំពោះបរិមាណថាមពលប្រើលើសរបស់អ្នកប្រើប្រាស់អគ្គិសនីប្រភេទឧស្សាហកម្មនិងកសិកម្ម ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដែលភ្ជាប់ពីបណ្តាញតង់ស្យុងមធ្យមនិងបណ្តាញតង់ស្យុងខ្ពស់របស់បណ្តាញជាតិ ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៣ |
| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | |
| ១ | សេចក្តីសម្រេចលេខ៣៩៥ សសរ.កសក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងារសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **ក្រសួងសាធារណការនិងដឹកជញ្ជូន** | |
| ១ | កំណត់ហេតុស្តីពីកិច្ចប្រជុំអន្តរក្រសួងស្តីពីការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ រវាងក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៤ |
| ២ | សេចក្តីណែនាំលេខ០០២ សក.សណន ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការអនុវត្តជាបណ្តោះអាសន្នសម្រាប់រថយន្តសណ្តោងសីមីរ៉ឺម៉ក ដែលមានភ្លៅ៦ (ប្រាំមួយ) អាចដឹកជញ្ជូនរហូតដល់៤៥តោន របស់ក្រសួងសាធារណការនិងដឹកជញ្ជូន |
| ៣ | លិខិតលេខ១៧៧សជណ.កបច ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីករណីសំណើសុំគោលការណ៍ពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់ក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីផ្លូវថ្នល់ឆ្នាំ២០១៤ និងអនុក្រឹត្យលេខ១៤១ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ |

| | |
|---|---|
| **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | |
| ១ | អនុក្រឹត្យលេខ២២៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញថ្មធម្មជាតិ |
| ២ | សារាចរលេខ០៣១០ រថ.អធរ.សរច ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ ស្ដីពីវិធានការចំពោះការដឹកជញ្ជូនរ៉ែសំណង់គ្រប់ប្រភេទ |
| ៣ | សេចក្ដីជូនដំណឹងលេខ០០០៥ រថ.នក.សជណ និងលេខ០០០៦ រថ.នក.សជណ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការដាក់ឱ្យអនុវត្តសេចក្ដីណែនាំស្ដីពីនីតិវិធីនៃកិច្ចដំណើរការក្នុងការអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែនិងសំណាករ៉ែ ក្នុងទម្រង់អេឡិចត្រូនិកនៃប្រព័ន្ធបញ្ជរតែមួយជាតិ |
| ៤ | សេចក្ដីណែនាំលេខ០០៦ សហវ.សណន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការចូលរួមប្រើប្រាស់ផលិតផលថ្មអារក្នុងស្រុកឱ្យអស់លទ្ធភាពក្នុងគ្រប់គម្រោងហេដ្ឋារចនាសម្ព័ន្ធនិងការដ្ឋានសំណង់នានា ដែលប្រើប្រាស់ថវិការដ្ឋ |
| **ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** | |
| ១ | លិខិតលេខ១១៥៣០ កបទ-សអ/ ច្បក៤ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិគោរពជូនសម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជំហររបស់ភាគីថៃលើការអនុញ្ញាតរបស់កម្ពុជា ឱ្យពលរដ្ឋថៃប្រើប្រាស់បណ្ណព្រំដែនចូលមកកាន់ខេត្តសៀមរាបក្នុងគោលដៅទេសចរណ៍ |
| ២ | កំណត់ទូតរបស់ស្ថានទូតថៃនៅទីក្រុងភ្នំពេញលេខ០៨០០៧/១៥១៣ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការអនុវត្តរបស់ភាគីកម្ពុជាពុំស្របនឹងកិច្ចព្រមព្រៀងឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ |
| ៣ | កំណត់ទូតរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការលេខ២៣៩២ MFA-IC/LC4 ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការអនុញ្ញាតឱ្យពលរដ្ឋថៃដែលប្រើប្រាស់បណ្ណព្រំដែន អាចធ្វើដំណើរចូលទៅកាន់ខេត្តសៀមរាប ក្នុងគោលដៅទេសចរណ៍ |
| ៤ | កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្ដីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ ចុះហត្ថលេខាធ្វើនៅបាងកក នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៥ |

| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |
|---|---|
| ១ | សេចក្តីសម្រេចលេខ២៤២ សសរ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតបន្ថែមក្រុមការងារតាមវិស័យ សម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន |
| ២ | លិខិតលេខ១៥៨/២៤ ក.អ.ក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ស្នើសុំក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន១៦ ផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការដែលអង្គវេទិកាលើកទី១៩ បានប្រគល់ភារកិច្ចជូន |
| ៣ | លិខិតលេខ១៥៩/២៤ ក.អ.ក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ស្នើសុំក្រសួងមហាផ្ទៃកំណត់ក្រសួង ស្ថាប័ន ដែលត្រូវចូលរួមជាសមាជិកក្រុមការងារផ្នែករដ្ឋបាលដែនដី សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ «ត» |
| ៤ | លិខិតលេខ១៥៩/២៤ ក.អ.ក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ស្នើសុំក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍កំណត់ក្រសួង ស្ថាប័ន ដែលត្រូវចូលរួមជាសមាជិកក្រុមការងារផ្នែកសេដ្ឋកិច្ច សង្គមឌីជីថល និងទូរគមនាគមន៍ «ណ» |
| ៥ | លិខិតលេខ១៥៩/២៤ ក.អ.ក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ស្នើសុំសភាពាណិជ្ជកម្មកម្ពុជាចាត់តាំងសមាសភាពតំណាងផ្នែកឯកជន ចូលរួមក្នុងក្រុមការងារផ្នែកសេដ្ឋកិច្ច សង្គមឌីជីថល និងទូរគមនាគមន៍ «ណ» និងក្រុមការងារផ្នែករដ្ឋបាលដែនដី សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ «ត» |
| ៦ | លិខិតលេខ៣៨២/២៤ ក.អ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្នើសុំក្រសួង ស្ថាប័នពាក់ព័ន្ធចាត់តំណាងចូលរួមជាសមាជិកក្នុងក្រុមការងារ «ណ» តាមការកំណត់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| ៧ | លិខិតលេខ៥៣៩/២៤ ក.អ.ក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤ ស្នើសុំក្រសួង ស្ថាប័នពាក់ព័ន្ធចាត់តំណាងចូលរួមជាសមាជិកក្នុងក្រុមការងារ «ត» តាមការកំណត់របស់ក្រសួងមហាផ្ទៃ |
| ៨ | សេចក្តីសម្រេចលេខ៥៧៦/២៤ ក.អ.ក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងារតាមដាននិងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល ផ្នែកឯកជន របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |

| | |
|---|---|
| ៩ | លិខិតលេខ៧៦៥/២៤ គ.វ.ក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤ ស្តីពីការបែងចែកភារកិច្ចរបស់ក្រុមការងារតាមដាននិងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ១០ | លិខិតលេខ១០១០/២៤ ក.អ.ក ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៤ គោរពស្នើសុំសម្តេចបវរធិបតីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាជ័ខ្ពង់ខ្ពស់លើសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមការងារ «ណ» និង «ត» ផ្នែករាជរដ្ឋាភិបាល និងសេចក្តីព្រាងសម្រេចស្តីពីការតែងតាំងសមាសភាពផ្នែកឯកជនទាំងអស់ឡើងវិញ តាមសំណើរបស់សភាពាណិជ្ជកម្មកម្ពុជា របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ១១ | សេចក្តីសម្រេចលេខ៩៦ សសរ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការតែងតាំងសមាសភាពក្រុមការងារតាមវិស័យ សម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន |
| ១២ | សេចក្តីសម្រេចលេខ៩៧ សសរ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការទទួលស្គាល់ជាផ្លូវការនូវសមាសភាពក្រុមការងារទាំង១៦ផ្នែកឯកជននៃវេទិការាជរដ្ឋាភិបាល ផ្នែកឯកជន |
| **ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** | |
| ១ | ប្រកាសអន្តរក្រសួងលេខ៨៣៦ សហវ.ប្រក.អទច ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ២ | ប្រកាសអន្តរក្រសួងលេខ៨៣៧ សហវ.ប្រក.អទច ស្តីពីការផាកពិន័យដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ៣ | ប្រកាសអន្តរក្រសួងលេខ៨៣៨ សហវ.ប្រក.អទច ស្តីពីការបែងចែកចំណូលពីសេវាសាធារណៈ និងចំណូលពីការពិន័យរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ៤ | សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត គ្រប់គ្រង និងអភិវឌ្ឍន៍បណ្តុំសហគ្រាសធុនតូច និងមធ្យម |
| ៥ | សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនិងបែបបទស្នើសុំបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសហគ្រាសធុនមីក្រូ (សិប្បកម្ម) របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |

| | |
|---|---|
| **ធនាគារជាតិនៃកម្ពុជា** | |
| ១ | សារាចរណែនាំលេខធ៧.០២៣.០០១.សារាចរ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការរៀបចំឥណទានឡើងវិញចំពោះវិស័យទេសចរណ៍ខេត្តសៀមរាប របស់ធនាគារជាតិនៃកម្ពុជា |
| ២ | លិខិតលេខធ៧.០២៣.២៦២១.ធ.ត ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ជូនដំណឹងលើសំណើសុំអនុគ្រោះលើកលែងការអនុវត្តអនុបាតទ្រនាប់ដើមទុន ខនសឺវេសិន (Capital Conservation Buffer) បន្ថយការអនុវត្តប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេសមកត្រឹម៧% និងការអនុញ្ញាតឱ្យមានការរៀបចំឥណទានឡើងវិញលើវិស័យដែលរងផលប៉ះពាល់ របស់ធនាគារជាតិនៃកម្ពុជា |
| **រដ្ឋបាលខេត្តព្រះសីហនុ** | |
| ១ | វិធានការអនុវត្តចំនួន១២ចំណុច ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ដើម្បីថែរក្សាសន្តិសុខ សុវត្ថិភាព ឈានទៅបង្ក្រាបបទល្មើសព្រហ្មទណ្ឌនានា និងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា ដែលកើតមានក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ |
| **អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា** | |
| ១ | ប្រកាសលេខ៩៥៨ សហវ.ប្រក.អគរ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ២ | ប្រកាសលេខ៩២៤ សហវ.ប្រក.អគរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការកែសម្រួលគោលការណ៍ និងនីតិវិធីនៃការកំណត់មុខសញ្ញាទំនិញនាំចេញ-នាំចូល និងទំនិញឆ្លងកាត់ផ្ទុកក្នុងកុងតឺន័រដែលត្រូវឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កែន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៣ | ប្រកាសលេខ៧៨៨ សហវ.ប្រក.អគរ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ ស្តីពីនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

| | |
|---|---|
| ៤ | សេចក្តីណែនាំលេខ៤៣៥៣/២៣ អគរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីនីតិវិធីលម្អិត និងភារកិច្ចទទួលខុសត្រូវនៃកិច្ចដំណើរការការរាយការណ៍អំពីទំនិញ និងកិច្ចដំណើរការប្រតិវេទន៍គយ តាមមធ្យោបាយអេឡិចត្រូនិក របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា |
| ៥ | លិខិតលេខ៣៥៥១/២៣ អគរ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ជូនដំណឹងស្តីពីការដាក់ឱ្យអនុវត្តសាកល្បងមុខងារប្រតិវេទន៍គយសង្ខេបក្នុងប្រព័ន្ធអាស៊ីគូដា នៅសាខាគយ និងរដ្ឋាករប្រៃសណីយ៍ និងការដាក់ឱ្យអនុវត្តប្រព័ន្ធអាស៊ីហាប់សម្រាប់ការគ្រប់គ្រងកញ្ចប់បញ្ញើប្រៃសណីយ៍ នៅសាខាគយ និងរដ្ឋាករប្រៃសណីយ៍ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា |
| ៦ | សេចក្តីជូនដំណឹងលេខ០៨១៥/២៤ អគរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តជំហានដំបូងនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ នៅសាខាគយ និងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា |
| ៧ | សេចក្តីជូនដំណឹងលេខ១១០៧/២៤ អគរ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់នៅសាខាគយ និងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា |
| ៨ | ប្រកាសលេខ១០០២ សហវ.ប្រក.អគរ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការនីតិវិធីនៃការគ្រប់គ្រងបញ្ញើប្រៃសណីយ៍ បញ្ញើឆាប់រហ័ស និងទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៩ | លិខិតលេខ៣៨៨៦/២៣ អគរ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ជូនដំណឹងស្តីពីការដាក់ឱ្យអនុវត្តសាកល្បងនូវការធ្វើស្វ័យប្រវត្តិកម្មពេញលេញលើនីតិវិធីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ សំអាងដើមកំណើតទំនិញ និងការតភ្ជាប់រវាងប្រព័ន្ធប្រតិវេទន៍តម្លៃគិតពន្ធគយ(CVDS) និងប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (ASYCUDA) របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា |
| ១០ | លិខិតលេខ០៥៧១/២៤ អគរ ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៤ ជូនដំណឹងស្តីពីការលើកលែងការតម្រូវឱ្យបោះត្រានិងចុះហត្ថលេខាបញ្ជាក់ពីក្រុមហ៊ុនឬម្ចាស់ទំនិញលើកឯកសារ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា |

| | |
|---|---|
| ១១ | ប្រកាសលេខ៦៩០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែកក្កដាឆ្នាំ២០១៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃច្រកចេញចូលតែមួយក្នុងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ១២ | ប្រកាសលេខ២០៩ សហវ.ប្រក.អគរ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ស្ដីពីកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ១៣ | សេចក្ដីណែនាំលេខ២៧៧៥/២៣ អគរ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ស្ដីពីបែបបទនិងនីតិវិធីនៃការផ្ដល់និងការបន្តសុពលភាពវិញ្ញាបនបត្រប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត |
| ១៤ | សេចក្ដីណែនាំលេខ៤០១៥/២៣ អគរ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការអនុវត្តប្រយោជន៍របស់ប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត |
| ១៥ | លិខិតលេខ១៦៣៧/២៤ អគរ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ ជូនដំណឹងស្ដីពីការធ្វើបច្ចុប្បន្នភាពបញ្ជីក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមាត់ច្រកក្នុងការនាំចូលសាច់បង្កក របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា |
| ១៦ | អនុក្រឹត្យលេខ៣៧០ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ |
| ១៧ | សេចក្ដីណែនាំលេខ២៣៤០ កសក ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤ ស្ដីពីនីតិវិធីនៃកិច្ចដំណើរការស្នើសុំអាជ្ញាបណ្ណលិខិតអនុញ្ញាតនិងវិញ្ញាបនបត្រផលិតផលកសិកម្មក្នុងទម្រង់អេឡិចត្រូនិកតាមប្រព័ន្ធបញ្ជរតែមួយជាតិ |
| ១៨ | អនុក្រឹត្យលេខ៣៤០ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ |
| **អគ្គនាយកដ្ឋានពន្ធដារ** | |
| ១ | ប្រកាសលេខ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្ដីពីការប្រមូលពន្ធលើអចលនទ្រព្យ |
| ២ | ប្រកាសលេខ៣១២ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការនាំចូលនិងការផ្គត់ផ្គង់ទំនិញមួយចំនួន |
| ៣ | ប្រកាសលេខ៤៩៥ សហវ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ |

| | |
|---|---|
| ៤ | ប្រកាសលេខ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ |
| ៥ | ប្រកាសលេខ៥០៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា |
| ៦ | ប្រកាសលេខ១៧១ សហវ.ប្រក.អពជ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ស្តីពីការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ |
| ៧ | អនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ស្តីពីកម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែនិងកម្រិតប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ |
| ៨ | ប្រកាសលេខ៥៤៣ សហវ.ប្រក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីពន្ធលើប្រាក់បៀវត្ស |
| ៩ | ប្រកាសលេខ១៧០ សហវ.ប្រក.អពជ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តពន្ធដារចំពោះវិស័យកសិកម្ម |
| ១០ | សេចក្តីណែនាំលេខ៤៤៦១១ អពជ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីឯកសារភស្តុតាងចំណាយសម្រាប់សហគ្រាសដែលទទួលការផ្គត់ផ្គង់ពីកសិករមិនស្ថិតក្នុងរបបស្វ័យប្រកាស |
| ១១ | សេចក្តីណែនាំលេខ១៣៨០៤ អពជ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ស្តីពីការលើកលែងពន្ធអប្បបរមាដល់សហគ្រាសជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ |
| ១២ | ប្រកាសលេខ១២០ សហវ.ប្រក.អពជ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ |
| ១៣ | ប្រកាសលេខ០៧១ សហវ.ប្រក.អពជ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត |
| ១៤ | សៀវភៅណែនាំ ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ |

| | |
|---|---|
| ១៥ | សៀវភៅណែនាំ ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ |
| ១៦ | សេចក្តីព្រាងសៀវភៅណែនាំស្តីពីពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធលើដីធ្លីមិនបានប្រើប្រាស់ សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ |
| ១៧ | សេចក្តីព្រាងសៀវភៅណែនាំស្តីពីពន្ធលើអចលនទ្រព្យ និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធលើអចលនទ្រព្យ សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ |
| ១៨ | សេចក្តីព្រាងសៀវភៅណែនាំស្តីពីពន្ធប្រថាប់ត្រា និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធប្រថាប់ត្រា សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ |
| ១៩ | សេចក្តីព្រាងសៀវភៅណែនាំស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូន និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធលើមធ្យោបាយដឹកជញ្ជូន សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ |
| ២០ | សេចក្តីព្រាងសៀវភៅណែនាំស្តីពីពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ |
| ២១ | សេចក្តីព្រាងសៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការដាក់លិខិតប្រកាសសារពើពន្ធនិងការបង់ប្រាក់ពន្ធ សម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសនិងមន្ត្រីពន្ធដារ |
| ២២ | សេចក្តីជូនដំណឹងលេខ៤៣២៧៩ អពដ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការអនុវត្តកាលបរិច្ឆេទនៃលិខិតស្នាមឬលិខិតជូនដំណឹងផ្សេងៗរបស់រដ្ឋបាលសារពើពន្ធ |
| ២៣ | ប្រកាសលេខ១១៩ សហវ.ប្រក.អពដ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍ |

បណ្ដុំឯកសារកំណែទម្រង់បទប្បញ្ញត្តិ ការដាក់ចេញគោលនយោបាយ និងឯកសារពាក់ព័ន្ធផ្សេងៗ របស់ក្រសួង ស្ថាប័ន÷

## ឧបសម្ព័ន្ធទី២: បញ្ជីវឌ្ឍនភាពនៃការអនុវត្តវិធានការ តាមក្រុមវិធានការ

| ល.រ | ចំណាត់ការកែទម្រង់មុតស្រួចជាគន្លឹះដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| **១-ការកែសម្រួលបរិយាកាសធុរកិច្ចនិងការវិនិយោគ** | | | |
| | **១.១. ការបំពេញកាតព្វកិច្ចគណនេយ្យ និងសវនកម្ម** | | |
| ១ | ១.១.១- ផ្តល់ការអនុគ្រោះដល់សហគ្រាសមិនរងសវនកម្មឯករាជ្យ ដែលមិនទាន់បានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមកនិយ័តករគណនេយ្យនិងសវនកម្ម រហូតដល់ដំណាច់ខែកុម្ភៈ ឆ្នាំ២០២៤។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ២ | ១.១.២- ប្រគល់ភារកិច្ចជូននិយ័តករគណនេយ្យនិងសវនកម្ម ផ្តល់ភាពទន់ភ្លន់ក្នុងការអនុវត្តនូវពិន័យអន្តរការណ៍និងការពិនិត្យដោះស្រាយការតវ៉ានានាពីវិស័យឯកជន។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| | ១.១.៣- ប្រគល់ភារកិច្ចជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដូចខាងក្រោម÷ | | |
| ៣ | ១.១.៣.ក- ដឹកនាំធ្វើវិសោធនកម្មអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ៤ | ១.១.៣.ក.១- ដឹកនាំធ្វើវិសោធនកម្មប្រកាសស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ៥ | ១.១.៣.ខ- ជំរុញការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធ ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេសស្តង់ដាគណនេយ្យជូនដល់តំណាង និងគណនេយ្យកររបស់សហគ្រាសសាធារណជន និងមន្ត្រីសាធារណៈពាក់ព័ន្ធ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ៦ | ១.១.៣.គ- ជំរុញការរៀបចំសទ្ទានុក្រមវាក្យសព្ទគណនេយ្យនិងសវនកម្ម ព្រមទាំងការបកប្រែស្តង់ដាគណនេយ្យនិងសវនកម្មជាភាសាខ្មែរ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាគញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ៧ | ១.១.៣.ឃ- ពិនិត្យលទ្ធភាព ក្នុងការរៀបចំស្តង់ដាគណនេយ្យសាមញ្ញ សម្រាប់សហគ្រាសជាអ្នកជាប់ពន្ធតូចនិងមធ្យម (Cambodian Simplified Accounting Standard) សម្រាប់រយៈពេលអន្តរកាលមួយ មុននឹងឈានទៅរកការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ៨ | **១.២- ការលើកកម្ពស់តម្លាភាពនៃការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបផលិតផលក្លែងក្លាយ**<br>ប្រគល់ភារកិច្ចជូនឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្តអនុវត្តសេចក្តីសម្រេចលេខ ៤៦៨៦ សសរ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការផ្ទាកជាបណ្តោះអាសន្ននូវការស្រាវជ្រាវ ការស៊ើបអង្កេត និងការបង្ក្រាបផលិតផលក្លែងក្លាយរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដើម្បីកែសម្រួលតួនាទី និងភារកិច្ច សំដៅលុបបំបាត់ចំណុចអវិជ្ជមានលើប្រសិទ្ធភាពការងារ។ | ក្រសួងមហាផ្ទៃ | បានសម្រេចពេញលេញ |
| | **១.៣- ការបន្តជំរុញការរៀបចំការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន**<br>ប្រគល់ភារកិច្ចជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំសម្របសម្រួល ដូចខាងក្រោម÷ | | |
| ៩ | ១.៣.១- អភិវឌ្ឍមុខងារធ្វើបច្ចុប្បន្នកម្មព័ត៌មានក្រុមហ៊ុន សហគ្រាសទាំងចាស់និងថ្មី លើប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន សម្រេចឱ្យបានពេញលេញមុនខែវិច្ឆិកា ឆ្នាំ២០២៤។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១០ | ១.៣.២- បញ្ចប់ដំណើរការនៃការដាក់បញ្ចូលសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន ដែលបានប្រកាសចូលរួមក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានរួចហើយ ក្នុងដំណាក់កាលទី៣ កាលពីខែមិថុនា ឆ្នាំ២០២៣ កន្លងទៅ ដែលរួមមានក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ និងធនាគារជាតិនៃកម្ពុជា។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| | ១.៣.៣-បញ្ចូលសេវាសាធារណៈ ឬប្រព័ន្ធរបស់ក្រសួង ស្ថាប័នចំនួន ៣ បន្ថែមទៀត ដែលទើបស្នើដាក់បញ្ចូលមកក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មានក្រោយការ ប្រកាសដំណាក់កាលទី៣ រួមមាន ÷ | | |
| ១១ | ១.៣.៣.ក- សេវាផ្តល់ការពិនិត្យព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិករបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | បានសម្រេចពេញលេញ |
| ១២ | ១.៣.៣.ខ- សេវាផ្តល់បណ្ណសារព័ត៌មាន (ជារូបវន្តបុគ្គល) របស់ក្រសួងព័ត៌មាន | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | បានសម្រេចពេញលេញ |
| ១៣ | ១.៣.៣.គ- ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិលរបស់ក្រសួងមុខងារសាធារណៈ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | បានសម្រេចពេញលេញ |
| ១៤ | ១.៣.៤- ដាក់បញ្ចូលបន្ថែមទៀតនូវសេវាសាធារណៈគន្លឹះរបស់ក្រសួង-ស្ថាប័ន ការធ្វើធុរកិច្ច ក៏ដូចជាសេវាសាធារណៈណាដែលប្រជាពលរដ្ឋត្រូវការចាំបាច់បំផុត ឬញឹកញាប់បំផុត មកក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ក្នុងក្របខ័ណ្ឌនៃការផ្លាស់ប្តូរទិន្នន័យរួមរបស់រាជរដ្ឋាភិបាល តាមរយៈថ្នាលCamDX ឱ្យសម្រេចបានមុនដំណាច់ឆ្នាំ២០២៤។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | បានសម្រេចពេញលេញ |
| ១៥ | **១.៤- ការគាំទ្រដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម**<br>ប្រគល់ភារកិច្ចជូនឯកឧត្តម **ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បន្តសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យឡើងវិញនូវកម្រងសេវាសាធារណៈទាំងអស់របស់ក្រសួង ដោយពន្យារសុពលភាព និងកាត់បន្ថយរយៈពេលផ្តល់ និងថ្លៃសេវា នៃលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណផ្សេងៗ ក្នុងគោលដៅបន្តគាំទ្រ ដល់ការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ជាពិសេសសហគ្រាសកម្មន្តសាល។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | បានសម្រេចពេញលេញ |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| | **១.៥- ការលើកកម្ពស់តម្លាភាពនិងប្រសិទ្ធភាពនៃការរៀបចំលិខិតបទដ្ឋានគតិយុត្ត** | | |
| ១៦ | ១.៥- ប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ធ្វើការពិគ្រោះយោបល់ជាមួយវិស័យឯកជនពាក់ព័ន្ធសំខាន់ៗ សម្រាប់រាល់ការតាក់តែងលិខិតបទដ្ឋានគតិយុត្ត ដែលមានការពាក់ព័ន្ធកិច្ចប្រតិបត្តិការ របស់សហគ្រាសអាជីវកម្មនៃវិស័យឯកជន | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងត្រូវបានអនុវត្ត |
| ១៧ | ១.៥.១-ការដាក់ឱ្យអនុវត្ត ត្រូវមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងត្រូវទុកពេលអន្តរកាល ៦ខែយ៉ាងតិច មុននឹងចាប់ផ្តើមអនុវត្ត។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងត្រូវបានអនុវត្ត |
| ១៨ | **១.៦. ការពិនិត្យលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណឡើងវិញ**<br>ប្រគល់ភារកិច្ចជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្របសម្រួល និងដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ធ្វើការពិនិត្យឡើងវិញនូវលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណទាំងអស់ ក្នុងវិស័យនីមួយៗ ដោយចាប់ផ្តើមពីវិស័យទេសចរណ៍ និងវិស័យសហគ្រាសធុនមីក្រូ តូច និងមធ្យម ដើម្បីលុបចេញឬផ្គួបបញ្ចូលគ្នា នូវលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណដែលត្រួតស៊ីគ្នា ព្រមទាំងកែសម្រួលនីតិវិធីនិងថ្លៃសេវានៃលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណនីមួយៗ ឱ្យមានភាពច្បាស់លាស់ ពោលគឺធ្វើយ៉ាងណាធានាថាគ្មាននីតិវិធីមួយណា ដែលបង្កការលំបាក និងដែលមិនចាំបាច់ដល់ប្រជាពលរដ្ឋឡើយ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |

| ល.រ | ចំណុចការកែទម្រង់មុខតម្រូវជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| **២-ការសម្រួលបន្ទុកលើអនុលោមភាព** | | | |
| | **២-ការសម្រួលបន្ទុកលើអនុលោមភាព**<br>ប្រគល់ភារកិច្ចជូនឯកឧត្តម **ឋោង ស្ងួរ** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចខាងក្រោម÷ | | |
| ១៩ | ២.១- បន្តដឹកនាំពង្រឹងយន្តការអធិការកិច្ចអន្តរក្រសួង តាមការសម្រេចរបស់វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៨ នាខែមីនា ឆ្នាំ២០១៩ កន្លងទៅ។ គ្រប់ក្រសួង ស្ថាប័ន ដែលស្ថិតក្នុងយន្តការអធិការកិច្ចអន្តរក្រសួង រួមទាំងការធ្វើអធិការកិច្ចហត្ថពលកម្មបរទេស ត្រូវប្រកាន់ខ្ជាប់នូវស្មារតីបុរេសកម្មជួយដល់វិស័យឯកជន ឱ្យចេះវាយតម្លៃកម្រិតអនុលោមភាពរបស់ខ្លួន មុនពេលចុះធ្វើអធិការកិច្ចរួមគ្នា ដូចដែលក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននិងកំពុងអនុវត្ត «របបស្វ័យប្រកាសអធិការកិច្ចការងារ» លើប្រព័ន្ធអនឡាញ ដែលអនុញ្ញាតឱ្យវិស័យឯកជនអាចបំពេញព័ត៌មាន និងដឹងភ្លាមៗអំពីចំណុចមិនអនុលោមភាពរបស់ខ្លួន និងមានរយៈពេលត្រឹម៤៥ថ្ងៃ ដើម្បីពិនិត្យឡើងវិញ និងបំពេញបន្ថែមឯកសារ ឬកែលម្អចំណុចខ្វះខាតណាមួយ ឱ្យបានត្រឹមត្រូវឡើងវិញ។ ពោលគឺអាចកែប្រែចំណុច ដែលមិនអនុលោមភាពទៅជាអនុលោមភាពវិញដោយខ្លួនឯងមុនពេលហួសសុពលភាពក្នុងការកែតម្រូវ។ គ្រប់ក្រសួង ស្ថាប័ន ត្រូវធានាថា១ឆ្នាំ គឺរួមគ្នាចុះអធិការកិច្ចតែ១ដងគត់លើគោលដៅតែមួយ លើកលែងតែមានបណ្តឹងពីបងប្អូនកម្មករនិយោជិតផ្ទាល់ ឬមានឧបទ្ទវហេតុណាមួយកើតឡើង។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | កំពុងត្រូវបានអនុវត្ត |
| ២០ | ២.១.១- គ្រប់ក្រសួង ស្ថាប័ន ដែលស្ថិតនៅក្នុងយន្តការអធិការកិច្ចអន្តរក្រសួង ត្រូវមានយន្តការទទួលពាក្យបណ្តឹងពីវិស័យឯកជនដើម្បីទប់ស្កាត់ការឆ្លៀតចុះអធិការកិច្ច ដោយខ្សែរបស់ក្រុមណាមួយ។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | បានសម្រេចពេញលេញ |
| ២១ | ២.២- ជំរុញការអភិវឌ្ឍជំនាញនិងផលិតភាពរបស់កម្មករ និយោជិត ដោយផ្តល់លទ្ធភាពដល់វិស័យឯកជន អាចចូលរួមសហការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់កម្មករនិយោជិត។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | កំពុងត្រូវបានអនុវត្ត |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ២២ | ២.២.១- អនុវត្តកាតព្វកិច្ចហ៊ីកហ៊ិនកូនជាង ស្របតាមច្បាប់ស្តីពីការងារ ដូចជាបង្កើតឱ្យមានកម្មវិធីបណ្តុះបណ្តាលវេនយប់ ឬចុងសប្តាហ៍ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | កំពុងត្រូវបានអនុវត្ត |
| ២៣ | ២.២.២- អនុញ្ញាតឱ្យក្រុមហ៊ុនប្រើប្រាស់អគាររបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីបំប៉នសមត្ថភាពជំនាញ បង្កើនជំនាញ ឬផ្លាស់ប្តូរជំនាញដល់កម្មករនិយោជិតរបស់ខ្លួន សំដៅជំរុញកំណើនផលិតភាពការងារ។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | កំពុងត្រូវបានអនុវត្ត |
| ២៤ | ២.២.៣- គាំទ្រដល់ការធ្វើទំនើបកម្មខ្សែច្រវាក់ផលិតកម្ម ឬការផ្តល់សេវាកម្មរបស់រោងចក្រសហគ្រាស។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | កំពុងត្រូវបានអនុវត្ត |
| ២៥ | ២.៣- ពង្រឹងយន្តការផ្សះផ្សានិងដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាយន្តការត្រីភាគី ពង្រឹងលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល និងសមត្ថភាពមន្ត្រីផ្សះផ្សាវិវាទការងារនៅថ្នាក់ក្រសួងនិងមន្ទីរ។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | កំពុងត្រូវបានអនុវត្ត |
| ២៦ | ២.៣.១- បង្កើនការអប់រំផ្សព្វផ្សាយអំពីច្បាប់ សិទ្ធិកាតព្វកិច្ច និងរបមន្តគណនាអត្ថប្រយោជន៍នានា ដើម្បីកាត់បន្ថយការយល់ច្រឡំ និងនាំឱ្យមានវិវាទការងារ។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | កំពុងត្រូវបានអនុវត្ត |
| **៣-ការសម្រួលដល់ធុរកិច្ចក្រោមដែនសមត្ថកិច្ចពន្ធដារ** | | | |
| | **៣.១- ការបន្តគោលការណ៍មិនយកពន្ធ**<br>ប្រគល់ភារកិច្ចជូនឯកឧត្តម **គង់ ចិមុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្តអនុវត្តគោលការណ៍ លើកលែងពន្ធ ដោយមិនយកពន្ធលើ ÷ | | |

៣

| ល.រ | ទិសដៅការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ២៧ | ៣.១.ក- ដីកសិកម្ម ដីស្រែជាលក្ខណៈគ្រួសារ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ២៨ | ៣.១.ខ- ពន្ធនាំចូលសម្ភារៈកសិកម្ម | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ២៩ | ៣.១.គ- កសិផលកសិកម្ម | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៣០ | ៣.១.ឃ- ពន្ធអចលនទ្រព្យតម្លៃទាបជាង១០០ ០០០ ០០០ (មួយរយលាន) រៀល | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៣១ | ៣.១.ង- ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិលើអចលនទ្រព្យពីឪពុកម្តាយមកកូន យាយតាមកចៅ ប្រពន្ធនិងប្តី សម្រាប់អំណោយ តែ១លើក និងមរតក | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៣២ | ៣.១.ច- អាករលើតម្លៃបន្ថែម លើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ រហូតដល់ចុងឆ្នាំ២០២៨ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៣៣ | ៣.១.ឆ- ពន្ធលើប្រាក់បៀវត្សអប្បបរមារបស់មន្ត្រីរាជការគ្រប់ប្រភេទ និងប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិត។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| | **៣.២- ការលុបការបង់ភាស៊ីនិងការបង់ថ្លៃផ្សេងៗទៀត** | | |
| ៣៤ | ៣.២- ប្រគល់ភារកិច្ចជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្តអនុវត្តនូវការលុបការបង់ភាស៊ីនិងការបង់ថ្លៃផ្សេងៗទៀត ចំពោះការលក់ដូររបស់ប្រជាពលរដ្ឋ តាមកញ្ច្រែងកញ្ជើ ល្អី នៅតាមទីផ្សារនានា នៅទូទាំងប្រទេស | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ៣៥ | ៣.២.១- ព្រមជាមួយនឹងគោលនយោបាយនៃការអនុញ្ញាតឱ្យអាជីវករលក់ដូរតាមផ្សាររដ្ឋ និងទីតាំងផ្សាររដ្ឋមានសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល លើតូប រាន ស្តង់លក់ដូរ និងមានសិទ្ធិផ្ទេរសិទ្ធិទាំងនេះឱ្យកូនចៅ ឬអ្នកដទៃបាន។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |

| ល.រ | វិធានការកែលម្អចំនុចស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| | **៣.៣- ការអនុគ្រោះពន្ធបន្ថែម**<br>ប្រគល់ភារកិច្ចជូនឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចខាងក្រោម÷ | | |
| ៣៦ | ៣.៣.១- បន្តការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់លំនៅឋានគ្រប់ប្រភេទ ដែលមានលក្ខណៈជាបុរី ដែលមានថ្លៃក្រោមឬស្មើ៧ម៉ឺនដុល្លារអាម៉េរិករហូតដល់ដំណាច់ឆ្នាំ២០២៤។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៣៧ | ៣.៣.២-លើកលែងពន្ធប្រថាប់ត្រាបន្ថែមទៀតលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់លំនៅឋានគ្រប់ប្រភេទ ដែលមានលក្ខណៈជាបុរី និងមានថ្លៃលើស៧ម៉ឺនដុល្លារអាម៉េរិក ដោយអនុញ្ញាតឱ្យដកទំហំទឹកប្រាក់៧ម៉ឺនដុល្លារអាម៉េរិកចេញពីមូលដ្ឋានគិតពន្ធប្រថាប់ត្រា សម្រាប់ការទិញលំនៅឋានក្នុងគម្រោងអភិវឌ្ឍន៍លំនៅឋានជាបុរី ដែលមានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ និងបានចុះបញ្ជីត្រឹមត្រូវ រហូតដល់ដំណាច់ឆ្នាំ២០២៤។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៣៨ | ៣.៣.៣- បន្តពន្យារពេលការអនុវត្តពន្ធលើចំណេញមូលធន ទាំង៦ប្រភេទ រួមមាន ពន្ធលើចំណេញអចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា និងរូបិយវត្ថុបរទេស រហូតដល់ដំណាច់ឆ្នាំ២០២៤។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៣៩ | ៣.៣.៤- លើកលែងទណ្ឌកម្មរដ្ឋបាល លើពន្ធលើអចលនទ្រព្យនិង/ឬពន្ធលើដីធ្លីមិនប្រើប្រាស់ ដោយម្ចាស់អចលនទ្រព្យអាចបង់តែប្រាក់ពន្ធ ដោយមិនចាំបាច់បង់ពន្ធបន្ថែម និងការប្រាក់រហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៤។ ការលើកលែងនេះ ពុំមានអនុភាពប្រតិសកម្មចំពោះប្រាក់ពន្ធ រួមទាំងទណ្ឌកម្មរដ្ឋបាល (ពន្ធបន្ថែម និងការប្រាក់) ដែលបានបង់រួចហើយនោះទេ។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៤០ | ៣.៣.៥- លើកលែងការកំណត់ពន្ធឡើងវិញ ដែលរួមមានប្រាក់ពន្ធ រួមទាំងទណ្ឌកម្មរដ្ឋបាល(ពន្ធបន្ថែម និងការប្រាក់) ចាប់ពីឆ្នាំដាក់ឱ្យអនុវត្តពន្ធរហូតដល់ឆ្នាំ២០២៣ ចំពោះអចលនទ្រព្យដែលបានចុះបញ្ជី និងប្រកាសបង់ពន្ធលើ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
| --- | --- | --- | --- |
| | អចលនទ្រព្យកន្លងមកខុសតម្លៃដីឬសំណង់ ទំហំដីឬសំណង់ ប្រភេទសំណង់ ឬ/និងអាយុកាលសំណង់។ ចាប់ពីឆ្នាំ ២០២៤ តទៅ ត្រូវអនុវត្តតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ | | |
| ៤១ | ៣.៣.៦- អនុញ្ញាតឱ្យចុះបញ្ជីនិងបង់ប្រាក់ពន្ធ ចាប់ពីឆ្នាំកាន់កាប់ឬទទួលប្រយោជន៍ចុងក្រោយ ចំពោះអចលនទ្រព្យ (មានបណ្ណកម្មសិទ្ធិឬគ្មានបណ្ណកម្មសិទ្ធិ) ដែលពុំធ្លាប់បានចុះបញ្ជី និងប្រកាសបង់ពន្ធអចលនទ្រព្យកន្លងមក។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៤២ | **៣.៤- ពន្ធលើដីធ្លីមិនបានប្រើប្រាស់**<br>ប្រគល់ភារកិច្ចជូនឯកឧត្តម **គន់ និមុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើការកែសម្រួលលិខិតបទដ្ឋានគតិយុត្ត ដើម្បីបន្ធូរបន្ថយលក្ខខណ្ឌ សម្រាប់ទទួលបានការលើកលែងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ឱ្យមានភាពច្បាស់លាស់ដោយផ្អែកលើគោលការណ៍ ដូចតទៅ÷ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៤៣ | ៣.៤.១- ដីដែលជាកម្មវត្ថុនៃពន្ធលើដីធ្លីមិនបានប្រើប្រាស់ សំដៅដល់ដីដែលនៅក្រៅតំបន់ជាប់ពន្ធលើអចលនទ្រព្យ។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៤៤ | ៣.៤.២- ដីដែលជាកម្មវត្ថុនៃពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញ៥ហិកតា ក្នុងមួយកន្លែង | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| | ៣.៤.៣- ចំពោះដីដែលលើសពី៥ហិកតា គឺអាចរួចពន្ធលើដីធ្លីមិនបានប្រើប្រាស់ស្របតាមលក្ខខណ្ឌណាមួយ ដូចខាងក្រោម÷ | | |
| ៤៥ | ៣.៤.៣.ក- ដីកសិកម្មកំពុងបង្កបង្កើនផល ដោយមានការបញ្ជាក់ពីគណៈកម្មការ ឬអនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៤៦ | ៣.៤.៣.ខ- ដីកំពុងបម្រើសកម្មភាពសេដ្ឋកិច្ចរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៤៧ | ៣.៤.៣.គ- ដីមានសំណង់ឬគ្មានសំណង់ស្ថិតក្រោមកិច្ចសន្យាជួល | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ៤៨ | ៣.៤.៣.ឃ- ដីដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាលឬស្ថាប័នរាជរដ្ឋាភិបាល | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៤៩ | ៣.៤.៣.ង- ដីសម្បទានសេដ្ឋកិច្ចដែលផ្តល់ពីរដ្ឋ ដីធ្លីរបស់សហគមន៍ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៥០ | ៣.៤.៣.ច- ដីជាកម្មសិទ្ធិរបស់រដ្ឋដែលបានផ្តល់ទៅឱ្យនីតិបុគ្គលឬរូបវន្តបុគ្គលណាមួយ សម្រាប់ប្រើប្រាស់ជាសកម្មភាពសេដ្ឋកិច្ចផ្សេងៗតាមកិច្ចសន្យាឬកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៥១ | ៣.៤.៣.ឆ- ដីដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែល បម្រើផ្ទាល់ដល់សកម្មភាពកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៥២ | ៣.៤.៣.ជ- ស្របតាមការស្នើសុំដោយក្រុមការងារផ្នែកអប់រំ (ក្រុម «ដ») គឺដីដែលត្រូវបានចុះបញ្ជីជាទ្រព្យសម្បត្តិ របស់សហគ្រាស ក្នុងវិស័យអប់រំសិក្សាធិការនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់គោលដៅបម្រើការងារក្នុងវិស័យដូចបានរៀបរាប់ខាងដើម។ ក្នុងករណីដែលដីនេះត្រូវបានលក់ឬមិនបានបម្រើតាមគោលដៅខាងលើ ត្រូវបំពេញកាតព្វកិច្ចពន្ធដារតាមច្បាប់ជាធរមាន។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៥៣ | ៣.៤.៤- ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ស្របតាមគោលការណ៍ខាងលើនេះ ត្រូវចាប់ផ្តើមអនុវត្តចាប់ពីដើមឆ្នាំ២០២៥។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| | **៣.៥- ការសម្រួលនិងពង្រីកវិសាលភាពនៃការអនុគ្រោះពន្ធក្នុងវិស័យកសិកម្ម**<br>ប្រគល់ភារកិច្ចជូនឯកឧត្តម **គន់ ចិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷ | | |
| ៥៤ | ៣.៥.១- បន្តការលើកទឹកចិត្តផ្នែកពន្ធដារចំនួន ២ឆ្នាំ បន្ថែមទៀត ស្របតាមប្រកាសលេខ២៥២ សហវ.ប្រក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសផលិតផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញ ស្រូវ អង្ករ ពោត សណ្តែក ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី និងជ័រកៅស៊ូ។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៥៥ | ៣.៥.១.១-ការបន្តការលើកទឹកចិត្តនឹងត្រូវបានពិនិត្យជាក់ស្តែងអំពីភាពចាំបាច់នៃការបន្តឬមិនបន្តនៅក្នុងរយៈពេល២ឆ្នាំម្តង។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ៥៦ | ៣.៥.២- បន្ថែមផលិតផលកសិកម្មចំនួន ៥មុខ ដែលកំពុងមានសក្តានុពល គឺ «មៀនប៉ៃលិន ស្វាយ វារីវប្បកម្ម ការចិញ្ចឹមសត្វ» និង «ផលិតផលដូងប្រេងនៅក្នុងស្រុក ដែលជាវត្ថុធាតុដើមផលិតចំណីសត្វ» ដោយអនុវត្តយន្តការលើកទឹកចិត្ត ដូចគ្នានឹងប្រកាសលេខ២៥២ សហវ.ប្រក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសផលិតផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញ ស្រូវ អង្ករ ពោត សណ្តែក ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី និង ជ័រកៅស៊ូ ដោយភ្ជាប់លក្ខខណ្ឌតម្រូវឱ្យមានការផ្តល់បញ្ជីឈ្មោះអ្នកផ្គត់ផ្គង់ទំនិញឬសេវាកម្មឱ្យបានច្បាស់លាស់ទៅ អគ្គនាយកដ្ឋានពន្ធដារ សម្រាប់ផ្ទៀងផ្ទាត់។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៥៧ | ៣.៥.៣- បន្តលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ចំពោះសហគ្រាសដាំដុះ ផលិត និងផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញ ផលិតផលកសិកម្ម រួមមានស្រូវ អង្ករ ពោត សណ្តែក ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី និងជ័រកៅស៊ូ ដោយបន្ថែម មៀនប៉ៃលិន ស្វាយ វារីវប្បកម្ម ការចិញ្ចឹមសត្វ និងផលិតផលដូងប្រេង នៅក្នុងស្រុក ដែលជាវត្ថុធាតុដើមផលិត ចំណីសត្វក្នុងស្រុក សម្រាប់រយៈពេល២ឆ្នាំ គឺពីឆ្នាំ២០២៤ដល់ឆ្នាំ២០២៥។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៥៨ | ៣.៥.៤- ផ្តល់ការសម្រួលដល់សហគ្រាស ក្នុងវិស័យកសិកម្ម ដោយបន្ធូរបន្ថយការអនុវត្តវិធានវិក្កយបត្រ ចំពោះប្រតិបត្តិការ ជាមួយកសិករ ដោយកំណត់ត្រឹមតែលក្ខខណ្ឌតម្រូវឱ្យមានឯកសារបញ្ជាក់ប្រភព នៃការផ្គត់ផ្គង់ច្បាស់លាស់ ជាអាទិ៍ អត្តសញ្ញាណនិងអាសយដ្ឋានរបស់អ្នកផ្គត់ផ្គង់មុខទំនិញឬសេវា និងព័ត៌មានជាមូលដ្ឋានមួយចំនួនទៀតពាក់ព័ន្ធ នឹងការផ្គត់ផ្គង់។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| | **៣.៦- ការផ្តល់ការលើកទឹកចិត្តផ្សេងទៀត**<br>ប្រគល់ភារកិច្ចជូនឯកឧត្តម **គន់ ចិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷ | | |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ៥៩ | ៣.៦.១- ផ្តល់ការលើកលែងពន្ធអប្បបរមា ដល់សហគ្រាសជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់(គ.ល.គ. "QIP") សម្រាប់ឆ្នាំដំបូង ដែលមិនទាន់មានរបាយការណ៍សវនកម្មឯករាជ្យ ដោយកំណត់លក្ខខណ្ឌតម្រូវឱ្យសហគ្រាសផ្តល់របាយការណ៍សវនកម្មឯករាជ្យមកអគ្គនាយកដ្ឋានពន្ធដារ យ៉ាងយូរត្រឹមដំណាច់ខែមិថុនា នៃឆ្នាំបន្ទាប់។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៦០ | ៣.៦.២- ផ្តល់ការអនុគ្រោះព្យួរទុកជាបណ្តោះអាសន្ននូវការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែ រហូតដល់ដំណាច់ឆ្នាំ២០២៥ សម្រាប់សហគ្រាសជាគ.ល.គ. រួមមានសហគ្រាសផលិតស្លាកយីហោសម្រាប់សម្លៀកបំពាក់ (Garment Logo) ផលិតផលស្រោមដៃ (Glove) ស្រោមជើង (Sock) កន្សែង (Towel) ស្រោមខ្នើយ (Pillow Case) ស្រោមភួយ (Duvet Cover) កម្រាលពូក (Bed Sheet) និងកម្រាលតុ (Table Cloth) ដូចសហគ្រាសក្នុងវិស័យវាយនភណ្ឌដែរ។ ដើម្បីទទួលបានការលើកទឹកចិត្តនេះ សហគ្រាសត្រូវផ្សារភ្ជាប់ជាមួយនឹងអនុលោមភាពសារពើពន្ធ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងប្រការ៤ នៃប្រកាសលេខ០០២ សហវ.ប្រក.អពជ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៦១ | ៣.៦.៣- កែសម្រួលប្រកាសលេខ២១៧ សហវ.ប្រក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ ស្តីពីការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត ដើម្បីការលើកលែងទណ្ឌកម្មរដ្ឋបាលចំពោះការកែតម្រូវលិខិតប្រកាសដោយស្ម័គ្រចិត្ត ដោយទុកពេលរហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៤។ ដោយឡែក ការស្នើសុំកែតម្រូវលិខិតប្រកាសក្រោយកាលបរិច្ឆេទនេះ នឹងត្រូវទទួលរងទណ្ឌកម្ម ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ទន្ទឹមនេះ ការអនុញ្ញាតនេះនឹងមិនត្រូវបានអនុវត្តចំពោះការកែតម្រូវលើលទ្ធផលដែលត្រូវបានរកឃើញក្នុងអំឡុងពេលសវនកម្មពន្ធដារឡើយ។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| | **៣.៧- ការកែទម្រង់រដ្ឋបាលសារពើពន្ធ (SOP)**<br>ប្រគល់ភារកិច្ចជូនឯកឧត្តម **គន់ ចិមុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷<br>៣.៧.១- បង្កើតស្តង់ដារួមឱ្យច្បាស់លាស់ ប្រកបដោយតម្លាភាព សម្រាប់ការអនុវត្ត រវាងមន្ត្រីពន្ធដារនិងមន្ត្រីពន្ធដារ និងមន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ តាមរយៈការរៀបចំសៀវភៅណែនាំស្តីពីស្តង់ដានីតិវិធីប្រតិបត្តិ (SOP) ពាក់ព័ន្ធនឹង÷ | | |
| ៦២ | ៣.៧.១.ក- សវនកម្មពន្ធដារ និងបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៦៣ | ៣.៧.១.ខ- ការអង្កេតសហគ្រាស និងបែបបទនិងនីតិវិធីនៃការធ្វើអង្កេតសហគ្រាស | អគ្គនាយកដ្ឋានពន្ធដារ | កំពុងត្រូវបានអនុវត្ត |
| ៦៤ | ៣.៧.១.គ- ការអង្កេតអចលនទ្រព្យ និងបែបបទនិងនីតិវិធីនៃការធ្វើអង្កេតអចលនទ្រព្យ | អគ្គនាយកដ្ឋានពន្ធដារ | កំពុងត្រូវបានអនុវត្ត |
| ៦៥ | ៣.៧.១.ឃ- ពន្ធលើដីធ្លីមិនប្រើប្រាស់ និងបែបបទនិងនីតិវិធី សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ | អគ្គនាយកដ្ឋានពន្ធដារ | កំពុងត្រូវបានអនុវត្ត |
| ៦៦ | ៣.៧.១.ង- ពន្ធលើអចលនទ្រព្យ និងបែបបទនិងនីតិវិធី សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ | អគ្គនាយកដ្ឋានពន្ធដារ | កំពុងត្រូវបានអនុវត្ត |
| ៦៧ | ៣.៧.១.ច- ពន្ធប្រថាប់ត្រា និងបែបបទនិងនីតិវិធី សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ | អគ្គនាយកដ្ឋានពន្ធដារ | កំពុងត្រូវបានអនុវត្ត |
| ៦៨ | ៣.៧.១.ឆ- ពន្ធលើមធ្យោបាយដឹកជញ្ជូន និងបែបបទនិងនីតិវិធី សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ | អគ្គនាយកដ្ឋានពន្ធដារ | កំពុងត្រូវបានអនុវត្ត |
| ៦៩ | ៣.៧.១.ជ- ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និងបែបបទនិងនីតិវិធី សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ | អគ្គនាយកដ្ឋានពន្ធដារ | កំពុងត្រូវបានអនុវត្ត |
| ៧០ | ៣.៧.១.ឈ- ពន្ធតាមរបបស្វ័យប្រកាស និងបែបបទនិងនីតិវិធី សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ | អគ្គនាយកដ្ឋានពន្ធដារ | កំពុងត្រូវបានអនុវត្ត |
| | ៣.៧.២- ផ្តល់អាទិភាពដល់ការរៀបចំSOP ពាក់ព័ន្ធនឹងការធ្វើសវនកម្ម ឱ្យបានឆាប់បំផុត ដោយត្រូវមានការបញ្ជាក់ឱ្យបានច្បាស់ពី÷ | | |

| ល.រ | វិធានការកែលម្អចំណុចស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ៧១ | ៣.៧.២.ក- ប្រភេទ បែបបទ និងនីតិវិធី នៃការធ្វើសវនកម្មពន្ធដារនិងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៧២ | ៣.៧.២.ខ- មុខងារនិងភារកិច្ចរបស់អង្គភាពពាក់ព័ន្ធ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៧៣ | ៣.៧.២.គ- សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធនិងរដ្ឋបាលសារពើពន្ធ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៧៤ | ៣.៧.២.ឃ- ក្រមសីលធម៌ វិន័យ និងវិជ្ជាជីវៈរបស់មន្ត្រីសវនករពន្ធដារ និងមន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយត្រូវមានការធ្វើបច្ចុប្បន្នភាព និងពង្រឹងការអនុវត្តការងាររបស់គណៈកម្មការគ្រប់គ្រងការអនុវត្តការងារសវនកម្មពន្ធដារ និងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៧៥ | ៣.៧.២.ង- យន្តការទទួលពាក្យបណ្តឹង | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៧៦ | ៣.៧.២.ច- យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៧៧ | ៣.៧.៣- ក្នុងករណីមិនឯកភាពទៅនឹងការអនុវត្តរបស់មន្ត្រីពន្ធដារ ដែលមិនស្របតាមSOP ដែលបាននិងកំពុងរៀបចំ អ្នកជាប់ពន្ធអាចធ្វើការតវ៉ាទៅអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ដើម្បីដោះស្រាយ។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ៧៨ | ៣.៧.៤- សម្រាប់សហគ្រាសដែលបានចុះបញ្ជីត្រឹមត្រូវការអនុវត្តកាលបរិច្ឆេទ នៃការជូនដំណឹងជាផ្លូវការផ្សេងៗ (សម្រាប់គោលដៅដាក់ពិន័យលើសកម្មភាពយឺតយ៉ាវណាមួយ) ត្រូវគិតចាប់ពីកាលបរិច្ឆេទបានទទួលលិខិត ជាជាងកាលបរិច្ឆេទនៃការចេញលិខិត។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |

| ល.រ | ចំណាត់ការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| **៤-កិច្ចសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចគយ** | | | |
| | ប្រគល់ភារកិច្ចជូនឯកឧត្តម **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចខាងក្រោម÷ | | |
| ៧៩ | ៤.១- លើកលែងការបង់កម្រៃបែបបទគយ (Customs Processing Fee) ចំពោះទំនិញនាំចេញ-នាំចូលដែលមានតម្លៃក្រោម ១.០០០ដុល្លារអាម៉េរិក | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៨០ | ៤.១.១- កាត់បន្ថយកម្រៃប្រតិវេទន៍គយពី ១៥.០០០រៀល មក ៨.០០០ រៀល ក្នុងមួយប្រតិវេទន៍ចំពោះទំនិញនាំចេញ នាំចូលដែលមានតម្លៃក្រោម ១.០០០ ដុល្លារអាម៉េរិក។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៨១ | ៤.២- លើកលែងការបង់កម្រៃស្កែនចំពោះកុងតឺន័រ ដែលមិនបានឆ្លងកាត់ម៉ាស៊ីនស្កែន។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៨២ | ៤.៣- បន្តធ្វើការងារជាមួយវិស័យឯកជនក្នុងការកាត់បន្ថយថ្លៃសេវាឡូជីស្ទីក តាមរយៈការពិនិត្យឡើងវិញនូវថ្លៃសេវានានា និងការកាត់បន្ថយ ឬការធ្វើសាមញ្ញនីយកម្មនីតិវិធីគយ។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | កំពុងត្រូវបានអនុវត្ត |
| ៨៣ | ៤.៣.១- បន្តធ្វើការងារជាមួយវិស័យឯកជន ក្នុងការកាត់បន្ថយថ្លៃសេវាឡូជីស្ទីក តាមរយៈការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | កំពុងត្រូវបានអនុវត្ត |
| ៨៤ | ៤.៤- ដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ នេះតទៅ នូវវិធាននិងនីតិវិធីសម្រាប់ការរាយការណ៍អំពីទំនិញ (Cargo Declaration) និងការបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-Arival Processing) តាមប្រព័ន្ធអេឡិចត្រូ- | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |

| ល.រ | ចំណាត់ការកែទម្រង់មុតស្រួចដាក់ញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| | និក ស្របតាមប្រកាសលេខ៧៨៨ សហវ.ប្រក.អគរ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ ស្តីពីនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់។ នីតិវិធីនេះនឹងអនុញ្ញាតឱ្យធុរជនអាចបញ្ជូនព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក មុនពេលទំនិញមកដល់ការិយាល័យគយ ដើម្បីអាចយកទំនិញចេញបានលឿនពេលទំនិញមកដល់ ដោយមិនចាំបាច់រង់ចាំយូរ។ | | |
| ៨៥ | ៤.៥- បែងចែកប្រភេទទំនិញ ដើម្បីពន្លឿនបែបបទគយ តាមរយៈការដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤នេះតទៅ នូវវិធាននិងនីតិវិធីសម្រាប់ការបំពេញបែបបទគយ ចំពោះបញ្ញើប្រៃសណីយ៍ បញ្ញើរហ័ស និងទំនិញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| | ៤.៦- ដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ នេះតទៅ នូវ÷ | | |
| ៨៦ | ៤.៦.១- ការធ្វើស្វ័យប្រវត្តិកម្មពេញលេញលើនីតិវិធីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និងសំអាងដើមកំណើតទំនិញក្នុងប្រព័ន្ធប្រតិវេទន៍តម្លៃគិតពន្ធគយ (CVDS) | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៨៧ | ៤.៦.២- ការតភ្ជាប់ប្រព័ន្ធ ដើម្បីបញ្ជូនដោយស្វ័យប្រវត្តនូវទិន្នន័យប្រតិវេទន៍តម្លៃគិតពន្ធគយ ការបញ្ជាក់តម្លៃគិតពន្ធគយ និងការផ្តល់អត្រាពន្ធអនុគ្រោះពីប្រព័ន្ធ CVDS ទៅប្រព័ន្ធ ASYCUDA1 | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៨៨ | ៤.៦.៣- ការបោះពុម្ពលិខិតបញ្ជាក់ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និងលិខិតបញ្ជាក់ការផ្ទៀងផ្ទាត់សំអាងដើមកំណើតទំនិញទម្រង់ក្រដាសអាចធ្វើឡើងក្នុងករណីមានការស្នើសុំរបស់ម្ចាស់ទំនិញ ឬតំណាង។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| | ៤.៧- ត្រូវរៀបចំដាក់អនុវត្តនូវផែនការសកម្មភាពជាក់លាក់ ឆ្លើយតបទៅនឹងការលើកឡើងអំពីថ្លៃចំណាយខ្ពស់ ការប្រើប្រាស់ឯកសារក្នុងទម្រង់រឹង (Hard Copy) ច្រើន និងការជួបគ្នាផ្ទាល់ជាមួយមន្ត្រីច្រើនកន្លែង សំដៅ ÷ | | |

| ល.រ | ចំណាត់ការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ៨៩ | ៤.៧.១- កាត់បន្ថយថ្លៃចំណាយលើការបំពេញបែបបទបញ្ចេញទំនិញពីគយនិងកែសម្រួលថ្លៃសេវាឱ្យបានសមរម្យ ឡើងវិញ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៩០ | ៤.៧.២- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ឯកសារភ្ជាប់ក្នុងទម្រង់អេឡិចត្រូនិក ជាឯកសារផ្លូវការ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៩១ | ៤.៧.៣- កែសម្រួលនីតិវិធីប្រតិវេទន៍គយក្នុងប្រព័ន្ធ ASYCUDA និងប្រព័ន្ធ E-Customs ដោយជំរុញការប្រើប្រាស់ឯកសារទម្រង់អេឡិចត្រូនិក និងកាត់បន្ថយឯកសារជាក្រដាស។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៩២ | ៤.៧.៤- ពង្រឹងយន្តការច្រកចេញ ចូលតែមួយនៅការិយាល័យគយ ដោយកាត់បន្ថយនីតិវិធី និងការជួបគ្នាផ្ទាល់ជាមួយមន្ត្រី។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៩៣ | ៤.៨- ជំរុញនិងបញ្ចប់ការរៀបចំដំណាក់កាលទី៣ នៃ ប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window) ដើម្បីបញ្ចូលអាជ្ញាបណ្ណ លិខិតអនុញ្ញាតវិញ្ញាបនបត្រ និងឯកសារផ្សេងៗ (LPCOs) របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ សំដៅជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឱ្យបានជាអតិបរមា ក្នុងការស្នើសុំឯកសារនាំចេញ នាំចូល។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៩៤ | ៤.៩- សម្រួលឱ្យបានជាអតិបរិមា នូវការត្រួតពិនិត្យទំនិញសម្រាប់ការនាំចេញ តាមរយៈការត្រួតពិនិត្យដែលផ្អែកលើហានិភ័យ រួមទាំងការប្រើប្រាស់ម៉ាស៊ីនស្កែន ដោយកាត់បន្ថយការត្រួតពិនិត្យឱ្យនៅក្រោម១០%។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៩៥ | ៤.៩.១- លើកលែងការបង់កម្រៃស្កែនចំពោះកុងតឺន័រដែលមិនបានឆ្លងកាត់ម៉ាស៊ីនស្កែន។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |

| ល.រ | ទិដ្ឋភាពការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ៩៦ | ៤.១០- បន្តជំរុញការបណ្តុះបណ្តាលជើងសារគយ។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៩៧ | ៤.១០.១- បន្តជំរុញការផ្តល់អាជ្ញាបណ្ណជើងសារគយ។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៩៨ | ៤.១១- ត្រូវអនុញ្ញាតឱ្យមានការផ្តល់សេវាធ្វើការបន្ថែមម៉ោងរបស់មន្ត្រីគយនៅពេលយប់នៅតាមផៃស្ងួត ដើម្បីពន្លឿនការនាំចេញ។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ៩៩ | ៤.១១.១- ត្រូវរៀបចំការកំណត់ប្រាក់ម៉ោងឱ្យបានសមរម្យ សម្រាប់ការធ្វើការបន្ថែមម៉ោងរបស់មន្ត្រីគយនៅពេលយប់។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ១០០ | ៤.១២- បន្តជំរុញការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ច បានទទួលការអនុញ្ញាត (Authorized Economic Operator-AEO)។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ១០១ | ៤.១២.១- បន្តជំរុញការកែលម្អប្រព្រឹត្តកម្មលើកទឹកចិត្តសម្រាប់ធុរជនល្អបំផុត (Best Traders)។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ១០២ | ៤.១៣- ពង្រឹងការគ្រប់គ្រងលើការនាំចូលសាច់ជ្រូកបង្កក មាន់ ស៊ុត និងត្រីខុសច្បាប់ ដែលមានថ្លៃថោកនិងគុណភាពទាប ដែលធ្វើឱ្យអ្នកចិញ្ចឹមក្នុងស្រុកមិនអាចប្រកួតប្រជែងបានដោយស្មើភាព ព្រមទាំងប៉ះពាល់ដល់សុខភាពរបស់ប្រជាជនកម្ពុជាទូទាំងប្រទេស តាមរយៈវិធានការដូចខាងក្រោម÷ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | កំពុងត្រូវបានអនុវត្ត |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ១០៣ | ៤.១៣.១- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ពង្រឹងឱ្យបានហ្មត់ចត់បំផុតនូវការហាមនាំចូលម្ហូបឬចំណីអាហារណា ដែលខូចគុណភាពឬគុណភាពទាប ដែលប៉ះពាល់ដល់សុខភាព មិនថាឡើយតែសាច់ជ្រូកបង្កក មាន់ ស៊ុត និងត្រី ខុសច្បាប់ មកកាន់ព្រះរាជាណាចក្រកម្ពុជា។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | កំពុងត្រូវបានអនុវត្ត |
| ១០៤ | ៤.១៣.២- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ កំណត់ច្រកទ្វារព្រំដែន ដែលអនុញ្ញាតឱ្យមានការនាំចូលសាច់ជ្រូកបង្កក មាន់ ស៊ុត និងត្រី ដើម្បីបង្កភាពងាយស្រួលក្នុងការគ្រប់គ្រង និងត្រួតពិនិត្យការនាំចូលខុសច្បាប់ក្នុងរូបភាពផ្សេងៗ។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ១០៥ | ៤.១៣.៣- ធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៧ អនក្រ.បក ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ ដើម្បីតម្រូវឱ្យមានការស្នើសុំលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះការនាំចូលសាច់ជ្រូកបង្កក មាន់ ស៊ុត និងត្រី សំដៅធានាការពិនិត្យគុណភាព និងការពារសុខភាពរបស់ប្រជាជន ស្របតាមការកំណត់នៃលិខិតបទដ្ឋានគតិយុត្តជាធរមាន។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ១០៦ | ៤.១៣.៤- ជំរុញកិច្ចសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រើប្រាស់ប្រព័ន្ធបញ្ជរតែមួយជាតិ(National Single Window) សម្រាប់សម្រួលដល់ការស្នើសុំលិខិតអនុញ្ញាតឱ្យបានលឿន។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |
| ១០៧ | ៤.១៤- ធ្វើវិសោធនកម្មអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ ដោយសហការជាមួយវិស័យឯកជន ដើម្បីកំណត់ថ្លៃមធ្យមភាគនិងរូបមន្តមូលដ្ឋានគិតពន្ធជ័រកៅស៊ូនាំចេញរបស់កម្ពុជា ដើម្បីឱ្យកាន់តែមានភាពប្រាកដនិយម។ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | បានសម្រេចពេញលេញ |

| ល.រ | ទិដ្ឋភាពការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| **៥-ការលើកកម្ពស់ការដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ** | | | |
| ១០៨ | ៥- ប្រគល់ភារកិច្ចជូនឯកឧត្តម **ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងសិក្សាពីបច្ចេកទេសឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់ប្រភេទរថយន្តនិងប្រភេទផ្លូវ ដែលអាចប្រើប្រាស់បានសម្រាប់ការដំឡើងកម្រិតទម្ងន់រថយន្តដឹកទំនិញពី៤០ តោន ទៅដល់៤៥ តោន។ | ក្រសួងសាធារណៈការនិងដឹកជញ្ជូន | កំពុងត្រូវបានអនុវត្ត |
| **៦-ការស្តារនិងការលើកស្ទួយការអភិវឌ្ឍវិស័យទេសចរណ៍** | | | |
| | ៦.១- ដាក់ចេញនូវកម្មវិធីពិសេសមួយ គឺ «**ទស្សនាសៀមរាប ឆ្នាំ២០២៤**» សំដៅជំរុញឱ្យវិស័យទេសចរណ៍នៅក្នុងខេត្តសៀមរាប មានសន្ទុះងើបឡើងវិញ តាមរយៈវិធានការដូចខាងក្រោម÷ | | |
| ១០៩ | ៦.១.១- ប្រគល់ភារកិច្ចជូនឯកឧត្តម **សុខ សូកេន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រៀបចំឡើងវិញនិងដាក់ឱ្យដំណើរការក្រុមប្រឹក្សាទេសចរណ៍ ដោយមានការចូលរួមពីស្ថាប័នរដ្ឋនិងវិស័យឯកជនពាក់ព័ន្ធឱ្យបានឆាប់បំផុត។ | ក្រសួងទេសចរណ៍ | បានសម្រេចពេញលេញ |
| ១១០ | ៦.១.២- ប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាទេសចរណ៍ ក្រោមការដឹកនាំរបស់ក្រសួងទេសចរណ៍ រៀបចំនិងដាក់ចេញនូវផែនការសកម្មភាពជាក់លាក់ ដើម្បីអនុវត្តកម្មវិធីពិសេស «ទស្សនាសៀមរាប ឆ្នាំ២០២៤» ឱ្យបានរួចរាល់នៅមុនដំណាច់ឆ្នាំ២០២៣ ដែលផែនការសកម្មភាពនេះ គឺជាការគិតគូរដោះស្រាយបញ្ហាប្រឈម ជាខ្សែច្រវាក់តម្លៃទាំងមូល សម្រាប់វិស័យទេសចរណ៍នៃខេត្តសៀមរាប ដែលមានជាអាទិ៍ការផ្សព្វផ្សាយ ការតភ្ជាប់ជើងហោះហើររវាងតំបន់ទេសចរណ៍សំខាន់ៗ ការកែសម្រួល និងការផ្តល់សេវានៅពេលមកដល់ ពេលស្នាក់នៅ និងពេលត្រឡប់ទៅវិញ តម្រូវការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជារួម ក៏ដូចជាការកែលម្អបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធនិងសោភ័ណភាពពីព្រលានយន្តហោះថ្មីមកកាន់ក្រុងសៀមរាប ថ្លៃសំបុត្រចូលទស្សនារមណីយដ្ឋាននានា និងថ្លៃប្រតិបត្តិការក្នុងវិស័យអាកាសចរណ៍ ។ល។ | ក្រសួងទេសចរណ៍ | បានសម្រេចពេញលេញ |

| **ល.រ** | **វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩** | **ក្រសួង ស្ថាប័នទទួលបន្ទុក** | **វឌ្ឍនភាព** |
|---|---|---|---|
| ១១១ | ៦.១.២.១- និយាយជារួម ផែនការនេះ ត្រូវតែមានភាពទាក់ទាញនិងកាតាលីករជំរុញវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប ឱ្យមានសន្ទុះឡើងវិញនៅឆ្នាំ២០២៤ នេះ។ ផែនការសកម្មភាពនេះ ក៏ត្រូវមានការបែងចែកការទទួលខុសត្រូវច្បាស់លាស់រវាងវិស័យរដ្ឋនិងវិស័យឯកជន គិតគូរពីតម្រូវការថវិកា និងការតាមដាននិងវាយតម្លៃ។ល។ ក្នុងស្មារតី **«រួមគិត រួមធ្វើ និងរួមទទួលខុសត្រូវ»**។ | ក្រសួងទេសចរណ៍ | បានសម្រេចពេញលេញ |
| ១១២ | ៦.១.៣- ប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាទេសចរណ៍ ក្រោមការដឹកនាំរបស់ក្រសួងទេសចរណ៍ សហការជាមួយនឹងយន្តការ និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយនូវបញ្ហាដែលវិស័យឯកជនជួបប្រទះ ក្នុងអាជីវកម្មប្រចាំថ្ងៃផងដែរ ដូចជា ការគ្រប់គ្រងនិងការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ ការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញទេសចរណ៍ បញ្ហាអនាម័យនិងការគ្រប់គ្រងសំរាម ការពង្រឹងសន្តិសុខនិងសុវត្ថិភាពនៅតាមគោលដៅទេសចរណ៍សំខាន់ៗ ការបំពាក់កាមេរ៉ាសុវត្ថិភាពតាមគោលដៅសំខាន់ៗ ការកំណត់ថ្លៃសម្រាប់ភ្ញៀវបរទេសនិងភ្ញៀវក្នុងស្រុក ការជំរុញឱ្យមានការបិទស្ទីកគ័រថ្លៃ (Price Stickers) ការបង្កើតផែនទីទេសចរណ៍ ការដាក់បញ្ចូលទីតាំងទេសចរណ៍ថ្មីៗ និងការផ្សព្វផ្សាយនៅលើប្រព័ន្ធអ៊ីនធឺណិត ការកែលម្អនិងការកសាងហេដ្ឋារចនាសម្ព័ន្ធ ការកាត់បន្ថយកម្រៃជើងសារ (Commissions) នៃកញ្ចប់ធ្វើដំណើរមកកម្ពុជា ការផ្សព្វផ្សាយ និងការកែច្នៃប្រកបដោយភាពច្នៃប្រឌិត។ល។ | ក្រសួងទេសចរណ៍ | កំពុងត្រូវបានអនុវត្ត |
| | **៦.២- ជំរុញអនុវត្តកម្មវិធីពិសេស «ទស្សនាសៀមរាប ឆ្នាំ២០២៤» តាមរយៈវិធានការមួយចំនួនទៀតដូចខាងក្រោម÷** | | |
| | **ទី១- បញ្ហាបដិសណ្ឋារកិច្ចតាមច្រកទ្វារព្រំដែន**<br>៦.២.១- ប្រគល់ភារកិច្ចជូន ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម **សុខ ចិន្ដា សោភា** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ពន្លឿនរៀបចំការងារចំនួន៣ ដូចខាងក្រោម ដោយសាកល្បងមុនគេនៅព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាប ឱ្យបានរួចរាល់ មុនដំណាច់ឆ្នាំ២០២៣ ហើយនឹងពង្រីកការអនុវត្តនៅតាមព្រលានយន្តហោះ និងមាត់ច្រក | | |

| ល.រ | វិធានការកែលម្អចំណុចស្រួចស្រាវដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| | អន្តរជាតិផ្សេងៗទៀត÷ | | |
| ១១៣ | ៦.២.១.ក- រៀបចំសម្របសម្រួលកែលម្អការបំពេញបែបបទពេលមកដល់ (**e-arrival card**) ពីពាទម្រង់ (អន្តោប្រវេសន៍ គយ ចត្តាឡីស័ក) មកនៅតែ១ទម្រង់ ពោលគឺក្នុងទម្រង់អេឡិចត្រូនិក ដែលនឹងត្រូវចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ តទៅ។ | ក្រសួងមហាផ្ទៃ | បានសម្រេចពេញលេញ |
| ១១៤ | ៦.២.១.ខ- រៀបចំជាប្រព័ន្ធ **Hotline** ដើម្បីទទួលពាក្យបណ្តឹងផ្សេងៗភ្លាមៗ ទាក់ទងនឹងការផ្តល់សេវារបស់មន្ត្រីអន្តោប្រវេសន៍ នៅតាមគោលដៅសំខាន់ៗ។ | ក្រសួងមហាផ្ទៃ | កំពុងត្រូវបានអនុវត្ត |
| ១១៥ | ៦.២.១.គ- បង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ ដោយបំពាក់ប្រព័ន្ធស្វ័យប្រវត្តិកម្ម និងប្រព័ន្ធកាមេរ៉ានៅតាមគោលដៅសំខាន់ៗ ដើម្បីត្រួតពិនិត្យការងារប្រចាំថ្ងៃរបស់មន្ត្រីប៉ូលីសអន្តោប្រវេសន៍។ | ក្រសួងមហាផ្ទៃ | កំពុងត្រូវបានអនុវត្ត |
| ១១៦ | **ទី២- ការពង្រីកវិសាលភាពបណ្ណព្រំដែន**<br>៦.២.២- ប្រគល់ភារកិច្ចជូនឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម **សុខ ចិន្តាសោភា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សហការរៀបចំនិងជំរុញការងារការចរចាកែសម្រួលកិច្ចព្រមព្រៀងឆ្លងព្រំដែន ដោយពង្រីកវិសាលភាពបណ្ណព្រំដែននេះឱ្យបានឆាប់។ | ក្រសួងមហាផ្ទៃ និង ក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ | កំពុងត្រូវបានអនុវត្ត |
| ១១៧ | **ទី៣- ការផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិករទេសចរណ៍នៅក្នុងខេត្តសៀមរាប**<br>៦.២.៣- ប្រគល់ភារកិច្ចជូនលោកជំទាវ **ជា សិរី** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រៀបចំឥណទានឡើងវិញចំពោះវិស័យទេសចរណ៍នៅខេត្តសៀមរាប ជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ដោយមិនចាំបាច់ធ្វើចំណាត់ថ្នាក់ឥណទានរយៈពេល១២ខែ | ធនាគារជាតិនៃកម្ពុជា | បានសម្រេចពេញលេញ |
| ១១៨ | ៦.២.៤- ប្រគល់ភារកិច្ចជូនធនាគារសហគ្រាសធុនតូចនិងមធ្យមកម្ពុជា រៀបចំជាកម្មវិធីផ្តល់កម្ចីដោយផ្ទាល់ជាមួយនឹងទឹកប្រាក់បឋមចំនួន៥០លានដុល្លារអាមេរិកដល់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប ជាមួយនឹងអត្រាការប្រាក់ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| | សមរម្យនិងលក្ខខណ្ឌអនុគ្រោះផ្សេងទៀត ដើម្បីអនុញ្ញាតឱ្យប្រតិបត្តិករទេសចរណ៍អាចទទួលបាននូវហិរញ្ញប្បទានក្នុងចំនួនទឹកប្រាក់សមស្របតាមប្រភេទអាជីវកម្ម។ | | |
| | **ទី៤- ការលើកទឹកចិត្តផ្នែកពន្ធដារ**<br>ប្រគល់ភារកិច្ចជូនឯកឧត្តម **គង់ ចិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷ | | |
| ១១៩ | ៦.២.៥.ក- លើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ លើកលែងតែអាករលើតម្លៃបន្ថែម និងអាករលើការស្នាក់នៅ ចំពោះសណ្ឋាគារ ផ្ទះសំណាក់ ក្រុមហ៊ុន ភ្នាក់ងារទេសចរណ៍ និងភោជនីយដ្ឋានដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្មនៅខេត្តសៀមរាប ពីខែតុលា ឆ្នាំ២០២៣ រហូតដល់ចប់ឆមាសទី១ ឆ្នាំ២០២៤។ អាជីវកម្មទាំងនេះ នៅតែមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធអាករនិងប្រើប្រាស់ប្រព័ន្ធអនឡាញសម្រាប់ការគ្រប់គ្រងអាករលើតម្លៃបន្ថែម (E-VAT) ជារៀងរាល់ខែក្នុងអំឡុងពេលនេះ។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ១២០ | ៦.២.៥.ខ- លើកលែងពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំ២០២៣ ចំពោះសណ្ឋាគារផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្មនៅខេត្តសៀមរាប។ អាជីវកម្មទាំងនេះ នៅតែមានកាតព្វកិច្ចដាក់លិខិតប្រកាស ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២៣ យ៉ាងយឺតបំផុតឱ្យបាន មុនដំណាច់ខែមីនា ឆ្នាំ២០២៤។ ចំពោះប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលបានបង់រួច នឹងត្រូវអនុញ្ញាតជាឥណទាន សម្រាប់កាត់កងជាមួយពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២៤។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ១២១ | ៦.២.៥.គ- លើកលែងបំណុលពន្ធទាំងអស់ដែលមានការិយបរិច្ឆេទមុនឆ្នាំ២០២៣ ដែលក្នុងនោះ រួមមានប្រាក់ពន្ធ ពន្ធបន្ថែមការប្រាក់ ពន្ធបន្ថែម២៥% និងការប្រាក់រត់បន្ត ចំពោះសហគ្រាសដែលស្ថិតក្នុងវិស័យទេសចរណ៍ រួមមាន | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |

| ល.រ | វិធានការកែទម្រង់ចុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| | សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីពន្ធដារ និងមានសកម្មភាពអាជីវកម្មស្ថិតក្នុងខេត្តសៀមរាប។ | | |
| ១២២ | ៦.២.៥.ឃ- មិនចុះធ្វើសវនកម្មលើអាជីវកម្មក្នុងវិស័យទេសចរណ៍ រួមមានសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ នៅក្នុងការិយបរិច្ឆេទឆ្នាំ២០២០ ដល់២០២២ សម្រាប់រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកំពត។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ១២៣ | ៦.២.៥.ង- មិនចុះធ្វើសវនកម្មលើអាជីវកម្មក្នុងវិស័យទេសចរណ៍ រួមមានសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍នៅខេត្តសៀមរាប ក្នុងការិយបរិច្ឆេទឆ្នាំ២០២០ ដល់២០២៣។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |
| ១២៤ | **ទី៥- លើកលែងការពិន័យអន្តរការណ៍ជាប្រាក់ ចំពោះការហួសសុពលភាពអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍**<br>៦.២.៦- ផ្តល់ការអនុគ្រោះលើកលែងការពិន័យអន្តរការណ៍ជាប្រាក់ ចំពោះការហួសសុពលភាពអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ ដោយទុកឱសានវាទអនុវត្តរហូតដល់ដំណាច់ខែមីនា ឆ្នាំ២០២៤។ | ក្រសួងទេសចរណ៍ | បានសម្រេចពេញលេញ |
| ១២៥ | **ទី៦- ការតភ្ជាប់ជើងហោះហើរដោយត្រង់ពីគោលដៅទេសចរណ៍ល្បីមកសៀមរាប**<br>៦.២.៧- ប្រគល់ភារកិច្ចជូនឯកឧត្តម **សុខ សូកេន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ធ្វើការពិភាក្សា នៅក្រោមយន្តការក្រុមប្រឹក្សាទេសចរណ៍ និងដាក់ចេញជាវិធានការ ដើម្បីជំរុញការតភ្ជាប់ការហោះហើរដោយត្រង់ រវាងគោលដៅទេសចរណ៍ល្បីៗនៅក្នុងបណ្តាប្រទេសជិតខាងមកខេត្តសៀមរាប ដូចជាការហោះហើរដោយត្រង់រវាងភូកេតសៀមរាប បាលីសៀមរាប ដាណាំងសៀមរាប ឬសេប៊ូសៀមរាប។ | ក្រសួងទេសចរណ៍ | កំពុងត្រូវបានអនុវត្ត |

| ល.រ | វិធានការកែទម្រង់ចំណុចស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| | **៦.៣- បន្តដោះស្រាយបញ្ហាប្រឈមក្នុងវិស័យទេសចរណ៍ផ្សេងទៀត តាមរយៈវិធានការដូចខាងក្រោម÷** | | |
| ១២៦ | **ទី១- បញ្ហាទិដ្ឋាការ**<br>៦.៣.១- ប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ខិតខំប្រឹងប្រែងកែលម្អនិងសម្រួលនីតិវិធី និងធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈនានា ដើម្បីឱ្យទេសចរណ៍ដែលមកកម្ពុជា មានភាពកក់ក្ដៅ និងរីករាយទាំងពេលមុនមកដល់ ពេលមកដល់ ពេលស្នាក់នៅ និងពេលត្រឡប់ទៅវិញ។ | ក្រសួងទេសចរណ៍ | កំពុងត្រូវបានអនុវត្ត |
| ១២៧ | **ទី២- បញ្ហាកិត្តិនាមរបស់កម្ពុជា**<br>៦.៣.២- ប្រគល់ភារកិច្ចជូនឯកឧត្ដម **សុខ សូកេន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ជំរុញការអនុវត្តវិធានការដែលបានស្នើឡើង ក៏ដូចជាសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលថ្មីៗនេះ ដើម្បីកែលម្អកិត្តិនាមរបស់ប្រទេសកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់។ | ក្រសួងទេសចរណ៍ | កំពុងត្រូវបានអនុវត្ត |
| ១២៨ | ៦.៣.៣-ប្រគល់ភារកិច្ចជូនឯកឧត្ដម **គួច ចំរើន** អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ «បង្កើនការខិតខំពង្រឹងសន្តិសុខ សណ្ដាប់ធ្នាប់ឱ្យបានហ្មត់ចត់» | រដ្ឋបាលខេត្តព្រះសីហនុ | កំពុងត្រូវបានអនុវត្ត |
| | **ទី៣- បញ្ហាប្រឈមនិងសំណូមពរ ដែលត្រូវការដំណោះស្រាយក្នុងរយៈពេលមធ្យម**<br>៦.៣.៤- ប្រគល់ភារកិច្ចជូនឯកឧត្ដម **សុខ សូកេន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ធ្វើការសិក្សាលទ្ធភាពអនុវត្តលើសំណើសុំពាក់ព័ន្ធនឹង÷ | | |
| ១២៩ | ៦.៣.៤.១- ការបង្កើតខ្សែក្រវាត់បៃតងនៅតាមតំបន់ទេសចរណ៍សំខាន់ៗ ដើម្បីជំរុញការផ្គត់ផ្គង់បន្លែសាច់របស់ប្រជាកសិករដល់មូលដ្ឋានអាជីវកម្មទេសចរណ៍។ | ក្រសួងទេសចរណ៍ | កំពុងត្រូវបានអនុវត្ត |
| ១៣០ | ៦.៣.៤.២- ការអភិវឌ្ឍភ្នំគូលែនជាគោលដៅទេសចរណ៍ធម្មជាតិ | ក្រសួងទេសចរណ៍ | កំពុងត្រូវបានអនុវត្ត |

| ល.រ | ទិដ្ឋភាពការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| **៧-ការអភិវឌ្ឍវិស័យកសិកម្មនិងកសិឧស្សាហកម្ម** | | | |
| | ប្រគល់ភារកិច្ចជូនឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចខាងក្រោម÷<br>៧.១- អនុវត្តប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវខ្ពស់នូវកម្មវិធីអាទិភាពទាំង៣ ដូចខាងក្រោម÷ | | |
| ១៣១ | ៧.១.១- ការដាក់ចេញនូវយន្តការសម្របសម្រួលនិងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្មរកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗក្នុងកម្រិតសមរម្យ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | បានសម្រេចពេញលេញ |
| ១៣២ | ៧.១.២- ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ សង្កាត់ ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស ដើម្បីជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម និងជួយដល់គ្រួសារកសិករ ក្នុងការលើកស្ទួយផលិតផលកសិកម្មរបស់ខ្លួន | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | កំពុងត្រូវបានអនុវត្ត |
| ១៣៣ | ៧.១.៣- ការរៀបចំសហគមន៍កសិកម្ម។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | បានសម្រេចពេញលេញ |
| ១៣៤ | ៧.២- ជំរុញការផលិតគ្រាប់ពូជសុទ្ធនិងគុណភាពល្អ ទាំងស្រូវនិងបន្លែ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | បានសម្រេចពេញលេញ |
| ១៣៥ | ៧.២.១- ជំរុញឱ្យមានការវិនិយោគពីវិស័យឯកជនក្នុងការស្រាវជ្រាវអភិវឌ្ឍនិងផលិតគ្រាប់ពូជ សម្រាប់ផ្គត់ផ្គង់ដល់កសិករឱ្យបានទូលំទូលាយ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | កំពុងត្រូវបានអនុវត្ត |
| ១៣៦ | ៧.៣- ពន្លឿនការរៀបចំច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីបង្កើនទំនុកចិត្តរវាងកសិករនិងក្រុមហ៊ុនប្រមូលទិញ។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | កំពុងត្រូវបានអនុវត្ត |

| ល.រ | វិធានការកែលម្អចំណុចស្របជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ១៣៧ | ៧.៤- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធអនុវត្តវិធានការ ដែលមានក្នុងលិខិតរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ១១០៣៣ សហវ.ល.ស.គសហ ស្តីពីរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំពិភាក្សាពីស្ថានភាពនៃការនាំចេញអង្ករនិងស្វាយចន្ទីកម្ពុជា។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | កំពុងត្រូវបានអនុវត្ត |
| **៨-វិស័យធនាគារនិងហិរញ្ញវត្ថុ** | | | |
| | ប្រគល់ភារកិច្ចជូនលោកជំទាវ **ជា សិរី** អគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជាដូចខាងក្រោម÷ | | |
| ១៣៨ | ៨.១- អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បន្តអនុវត្តអនុបាតទ្រនាប់ដើមទុនខនស៊ីវេសិនត្រឹមកម្រិត១,២៥% រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ | ធនាគារជាតិនៃកម្ពុជា | បានសម្រេចពេញលេញ |
| ១៣៩ | ៨.២- អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បន្តអនុវត្តអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយបណ្ណត្រឹមកម្រិត៧% រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ | ធនាគារជាតិនៃកម្ពុជា | បានសម្រេចពេញលេញ |
| ១៤០ | ៨.៣- អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រៀបចំឥណទានឡើងវិញ ចំពោះវិស័យទេសចរណ៍នៅខេត្តសៀមរាបជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ដោយមិនចាំបាច់ធ្វើសំវិធានធនរយៈពេល១២ខែ។ | ធនាគារជាតិនៃកម្ពុជា | បានសម្រេចពេញលេញ |
| ១៤១ | ៨.៤- លើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រៀបចំឥណទានឡើងវិញ ចំពោះវិស័យអចលនទ្រព្យជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ដោយត្រូវអនុវត្តម៉ឺងម៉ាត់តាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានត្រូវធ្វើការសិក្សានិងវិភាគច្បាស់លាស់អំពីស្ថានភាពរបស់អតិថិជននិងផលប៉ះពាល់ នៃឥណទានរបស់អតិថិជននោះ ចំពោះប្រព័ន្ធទាំងមូល ព្រមទាំងអាចស្នើសុំការពិភាក្សាជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីពិចារណាអំពីវិធានការអនុគ្រោះ តាមករណីជាក់ស្តែងបន្ថែមទៀត។ | ធនាគារជាតិនៃកម្ពុជា | បានសម្រេចពេញលេញ |

| ល.រ | ទិដ្ឋភាពការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| **៩-វិស័យរ៉ែនិងថាមពល** | | | |
| | **៩.១- ការធ្វើអាជីវកម្មនិងការនាំចេញថ្មអារ**<br>ប្រគល់ភារកិច្ចជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងឯកឧត្តម **កែវ រតនៈ** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ដូចខាងក្រោម÷ | | |
| ១៤២ | ៩.១.១- សហការជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ អនុវត្តតាមខ្លឹមសារប្រកាសអន្តរក្រសួងលេខ៦១៤ សហវ.ប្រក ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីនីតិវិធីនិងបែបបទ សម្រាប់ការស្នើសុំនាំចេញផលិតផលរ៉ែ ដែលរាល់ការនាំចេញ ផលិតផលរ៉ែ ត្រូវតែមានវិញ្ញាបនបត្របញ្ជាក់ការនាំចេញ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល | បានសម្រេចពេញលេញ |
| ១៤៣ | ៩.១.១.១- ប៉ុន្តែ មិនអនុវត្តប្រការ៨ នៃប្រកាសអន្តរក្រសួងនេះ ដែលតម្រូវឱ្យមន្ត្រីក្រសួងរ៉ែនិងថាមពល ធ្វើការត្រួតពិនិត្យ ផលិតផលរ៉ែមុនពេលនាំចេញម្តងៗនោះទេ ដោយទុកភារកិច្ចនេះជូនសមត្ថកិច្ចគយនៅតាមច្រកនាំចេញធ្វើការ ត្រួតពិនិត្យតែម្តង។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល | បានសម្រេចពេញលេញ |
| ១៤៤ | ៩.១.១.២- មន្ត្រីគយត្រូវអនុវត្តការត្រួតពិនិត្យទំនិញនាំចេញ ក្នុងកម្រិតមិនលើសពី៥% នៃបរិមាណទំនិញនាំចេញមួយលើកៗ ដោយពន្លឿនការត្រួតពិនិត្យនេះឱ្យបានឆាប់បំផុតតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ករណីរកឃើញបទល្មើស ឬភាពមិនប្រក្រតី មន្ត្រីគយអាចពង្រីកវិសាលភាពនៃការត្រួតពិនិត្យ ជាយថាហេតុ ស្របតាមគោលការណ៍ គ្រប់គ្រងហានិភ័យនិងតាមបទប្បញ្ញត្តិនានាជាធរមាន។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល | បានសម្រេចពេញលេញ |
| ១៤៥ | ៩.១.១.៣- ចំពោះទំនិញនាំចេញ៩៥% ដែលមិនជាប់កាតព្វកិច្ចត្រួតពិនិត្យត្រូវពន្លឿន ដើម្បីឱ្យចេញបានឆាប់បំផុត។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល | បានសម្រេចពេញលេញ |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ១៤៦ | ៩.១.១.៤- ត្រូវចាត់វិធានការមុតស្រួចក្នុងការទប់ស្កាត់ការនាំចេញផលិតផលរ៉ែដោយខុសច្បាប់។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល | បានសម្រេចពេញលេញ |
| ១៤៧ | ៩.១.២- បន្តអនុវត្តតម្លៃមូលដ្ឋានគិតអាករនាំចេញតាមច្បាប់ស្តីពីគយនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដែលស្របតាម គោលការណ៍នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ស្តីពីតម្លៃគិតពន្ធគយ គឺជាតម្លៃទិញលក់ពិត។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល | បានសម្រេចពេញលេញ |
| | ៩.១.៣- កែសម្រួលបញ្ចុះអត្រាអាករនាំចេញលើមុខទំនិញថ្ម ផ្អែកតាមរចនាសម្ព័ន្ធតារាងពន្ធគយជាធរមាន ដូចខាងក្រោម÷ | | |
| ១៤៨ | ៩.១.៣.ក- បញ្ចុះអត្រាអាករនាំចេញពី៣០% មក១០% ចំពោះថ្មអារមិនទាន់កែច្នៃក្នុងជំពូក២៥ ដែលមានទម្រង់ជាដុំ(Block) | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល | បានសម្រេចពេញលេញ |
| ១៤៩ | ៩.១.៣.ខ- បញ្ចុះអត្រាអាករនាំចេញពី៣០% មក៥% ចំពោះថ្មអារមិនទាន់កែច្នៃក្នុងជំពូក២៥ ដែលមានទម្រង់ជាបន្ទះ (Slab) | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល | បានសម្រេចពេញលេញ |
| ១៥០ | ៩.១.៣.គ- បញ្ចុះអត្រាអាករនាំចេញពី២០% មក០% ចំពោះថ្មកែច្នៃរួចគ្រប់ប្រភេទក្នុងជំពូក៦៨។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល | បានសម្រេចពេញលេញ |
| ១៥១ | ៩.១.៤- ជំរុញការធ្វើសាមញ្ញកម្មនីតិវិធីនៃការចេញវិញ្ញាបនបត្របញ្ជាក់ការនាំចេញ លិខិតអនុញ្ញាតគយនាំចេញ និងនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយឱ្យកាន់តែឆាប់រហ័សនិងមានប្រសិទ្ធភាព ដោយមិនត្រូវឱ្យលើស៣ថ្ងៃ នៃថ្ងៃធ្វើការ រាប់ចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំត្រឹមត្រូវនិងគ្រប់គ្រាន់។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល | បានសម្រេចពេញលេញ |
| ១៥២ | ៩.១.៥. ដាក់ចេញយន្តការអន្តរក្រសួង ដើម្បីសិក្សា និងដាក់ឱ្យអនុវត្តមូលនិធិស្តារការដ្ឋានរ៉ែ និងស្តារបរិស្ថានឡើងវិញ មូលនិធិថែទាំផ្លូវ និងអភិវឌ្ឍសហគមន៍ ដោយលើកអនុសាសន៍ អនុវត្តការងារនេះនៅរយៈពេល ៦ខែក្រោយ។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងរ៉ែ និងថាមពល | កំពុងត្រូវបានអនុវត្ត |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ១៥៣ | ៩.១.៦. ត្រូវបង្កើត Hotline សម្រាប់ទទួល និងដោះស្រាយសំណូមពររបស់ធុរជនវិស័យអាជីវកម្មថ្មអារ។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងរ៉ែ និងថាមពល | បានសម្រេចពេញលេញ |
| ១៥៤ | ៩.១.៧. ដឹកនាំក្រុមការងារទារបំណុលអន្តរក្រសួង តាមដានការអនុវត្តជាប្រចាំ និងរៀបចំជាកិច្ចប្រជុំរៀងរាល់ ២ខែម្តង ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយខាងលើ ផ្ទៀងផ្ទាត់ការបង់ចំណូល និងពិនិត្យមើលបញ្ហាប្រឈមនានា ដែលនៅសេសសល់ ឬកើតមានឡើងថ្មីជាយថាហេតុ។ ក្រោយរយៈពេល ៦ខែ នៃការអនុវត្តសាកល្បងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល ត្រូវសហការដឹកនាំកិច្ចប្រជុំអន្តរក្រសួង រវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងការពិគ្រោះយោបល់ ជាមួយតួអង្គពាក់ព័ន្ធដទៃទៀត ដើម្បីពិនិត្យ និងវាយតម្លៃឡើងវិញអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានានៅក្នុងការអនុវត្តសាកល្បងកន្លងទៅ។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងរ៉ែ និងថាមពល | កំពុងត្រូវបានអនុវត្ត |
| | **៩.២. វិស័យថាមពល** | | |
| ១៥៥ | ៩.២.១. ប្រគល់ភារកិច្ចជូនឯកឧត្តម **ត្រាំង ចលសា** អគ្គនាយកអគ្គិសនីកម្ពុជា ពិនិត្យលទ្ធភាពផ្តល់ថ្លៃអនុគ្រោះជូនអតិថិជនឧស្សាហកម្ម និងកសិកម្ម ចំពោះបរិមាណថាមពល ប្រើលើសជាការលើកទឹកចិត្តដល់អ្នកវិនិយោគ ឱ្យបង្កើនការផលិត និងបង្កើនការងារបន្ថែម។ | ក្រសួងរ៉ែ និងថាមពល | បានសម្រេចពេញលេញ |
| ១៥៦ | ៩.២.២. ប្រគល់ភារកិច្ចជូនឯកឧត្តម **យ៉េម ទិសិដ្ឋ** ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ពន្លឿនការរៀបចំបទប្បញ្ញត្តិស្តីពីការដំឡើង និងការប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា ដើម្បីដាក់អនុវត្តនៅដើមឆ្នាំ២០២៤ ខាងមុខ ដែលបទប្បញ្ញត្តិនេះគ្របដណ្តប់ទៅលើការគ្រប់គ្រងក្រុមហ៊ុនផ្តល់សេវាដំឡើង និងអ្នកប្រើប្រាស់ដែលមានដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ព្រមទាំងធ្វើការកំណត់បញ្ជីថ្លៃលក់អគ្គិសនីថ្មី សម្រាប់អ្នកប្រើប្រាស់ដែលមានដំឡើង | ក្រសួងរ៉ែ និងថាមពល | បានសម្រេចពេញលេញ |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| | ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ និងមិនតម្រូវឱ្យមានការបង់ថ្លៃអានុភាព (Capacity Charge) ទៀតទេ គឺបង់តែថ្លៃថាមពលប្រើប្រាស់ (Energy Charge) តាមគោលការណ៍សមធម៌ថ្លៃ។ | | |
| **១០-វិស័យសំណង់និងអចលនទ្រព្យ** | | | |
| | ១០.១- ប្រគល់ភារកិច្ចជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្តអនុវត្តវិធានការជាកញ្ចប់ចំនួន**៨ចំណុច** ដែលបានដាក់ចេញ ដោយរាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា រួមមាន÷ | | |
| ១៥៧ | ១០.១.១- បន្តពន្យារពេលការអនុវត្តការបង់ពន្ធជាកញ្ចប់តាមដំណាក់កាល រហូតដល់ដំណាច់ឆ្នាំ២០២៤ សម្រាប់ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋានជាបុរីដែលបាន និងកំពុងប្រតិបត្តិការគម្រោងអភិវឌ្ឍន៍លំនៅឋាន និងដែលមានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ ផ្តល់ដោយនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ។ ដោយឡែក ក្រុមហ៊ុនដែលបាន និងកំពុងប្រតិបត្តិការគម្រោងអភិវឌ្ឍន៍លំនៅឋានជាបុរីដែលគ្មានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ ត្រូវរួសរាន់ចុះបញ្ជីគម្រោងរបស់ខ្លួន ដើម្បីទទួលបានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ ស្របតាមនីតិវិធីជាធរមាន ពីនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០២៣ ដើម្បីទទួលបានការបន្តការបង់ពន្ធជាកញ្ចប់រហូតដល់ដំណាច់ឆ្នាំ២០២៤។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៥៨ | ១០.១.២- បង្កើនរយៈពេលនៃការបង់ពន្ធជាកញ្ចប់តាមដំណាក់កាល ពី១២ខែ ដល់១៨ខែ សម្រាប់ក្រុមហ៊ុនអ្នកអភិវឌ្ឍន៍លំនៅឋានជាបុរី ដែលបង់ពន្ធតិចជាង១លានដុល្លារអាមេរិក | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៥៩ | ១០.១.២.១- បង្កើនរយៈពេលនៃការបង់ពន្ធជាកញ្ចប់ពី២៤ខែ ដល់៣៦ខែ សម្រាប់ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋានជាបុរី ដែលបង់ពន្ធលើសពី១លានដុល្លារអាមេរិក។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ១៦០ | ១០.១.៣- ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋានជាបុរីថ្មី ឬក្រុមហ៊ុនដែលមានគម្រោងអភិវឌ្ឍន៍លំនៅឋានជាបុរី ដែលមិនទាន់អភិវឌ្ឍ ត្រូវបង់ពន្ធស្របតាមនីតិវិធីជាធរមាន (របបពិត) និងត្រូវកាន់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៦១ | ១០.១.៤- បន្តពន្យារពេលការអនុវត្តពន្ធលើចំណេញមូលធន សម្រាប់តែវិស័យអចលនទ្រព្យ រហូតដល់ដំណាច់ឆ្នាំ២០២៤។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៦២ | ១០.១.៥- បន្តការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លំនៅឋានគ្រប់ប្រភេទ ដែលមានលក្ខណៈជាបុរី និងដែលមានថ្លៃក្រោមឬស្មើ៧ម៉ឺនដុល្លារអាម៉េរិករហូតដល់ដំណាច់ឆ្នាំ២០២៤។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៦៣ | ១០.១.៦- សហការជាមួយធនាគារជាតិនៃកម្ពុជា លើកទឹកចិត្តនិងស្នើឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធ្វើការរៀបចំឥណទានឡើងវិញតាមលទ្ធភាពជាក់ស្តែងរបស់គ្រឹះស្ថាន ដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងការព្រមព្រៀងរវាងគ្រឹះស្ថាន និងក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋានជាបុរី ដោយអនុលោមតាមប្រកាសលេខធ៧.០១៧.៣៨៤ ប្រក ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាននិងសំវិធានធនលើអ៊ីមភើរមិន។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៦៤ | ១០.១.៧- លើកលែងការផាកពិន័យផ្សេងៗចំពោះគម្រោងអភិវឌ្ឍន៍លំនៅឋានជាបុរី ប៉ុន្តែក្រុមហ៊ុនអភិវឌ្ឍន៍ចាំបាច់ត្រូវបំពេញកាតព្វកិច្ច ស្របតាមប្រកាសលេខ០៨៩ សហវ.ប្រក ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៦៥ | ១០.១.៨- ពន្យារពេលអនុវត្តរហូតដល់ដំណាច់ឆ្នាំ២០២៣ លើសេចក្តីប្រកាសលេខ៥៦៣ សហវ. ប្រក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៦៦ | ១០.២- ពង្រឹងប្រសិទ្ធភាព ក្រុមការងារអន្តរក្រសួង ស្ថាប័ន ដើម្បីដោះស្រាយបញ្ហាវិវាទផ្សេងៗ ក្នុងវិស័យអចលនទ្រព្យ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | បានសម្រេចពេញលេញ |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ១៦៧ | ១០.២.១- ពង្រឹងប្រសិទ្ធភាពក្រុមការងារអន្តរក្រសួង ស្ថាប័ន កម្រិតគោលនយោបាយនិងម៉ាក្រូសេដ្ឋកិច្ច សម្រាប់វាយតម្លៃស្ថានភាពវិស័យសំណង់និងអចលនទ្រព្យ ដើម្បីបន្តដោះស្រាយបញ្ហាបន្ទាន់ ដោយសិក្សាវិភាគនិងដាក់ចេញនូវគោលនយោបាយ សំដៅធានាការអភិវឌ្ឍប្រកបដោយចីរភាព នៃវិស័យសំណង់និងអចលនទ្រព្យ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៦៨ | ១០.៣- ប្រគល់ភារកិច្ចជូនឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងពន្ធប្រថាប់ត្រាបន្ថែមទៀតលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់លំនៅឋានគ្រប់ប្រភេទ ដែលមានលក្ខណៈជាបុរីនិងមានថ្លៃលើស៧ម៉ឺនដុល្លារអាម៉េរិក ដោយអនុញ្ញាតឱ្យដកទំហំទឹកប្រាក់ ៧ម៉ឺនដុល្លារអាម៉េរិក ចេញពីមូលដ្ឋានគិតពន្ធប្រថាប់ត្រា សម្រាប់ការទិញលំនៅឋានក្នុងគម្រោងអភិវឌ្ឍន៍លំនៅឋានជាបុរី ដែលមានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ និងបានចុះបញ្ជីត្រឹមត្រូវ រហូតដល់ដំណាច់ឆ្នាំ២០២៤។ តាមរយៈវិធានការនេះ អ្នកទិញលំនៅឋានគ្រប់ប្រភេទ នឹងទទួលបាននូវការលើកទឹកចិត្ត ពោលគឺសម្រាប់អ្នកមានធនធានតិចដែលទិញផ្ទះក្នុងថ្លៃចាប់ពី ៧ម៉ឺនដុល្លារអាម៉េរិកចុះ នឹងត្រូវបានរួចពន្ធប្រថាប់ត្រា ហើយសម្រាប់អ្នកដែលទិញលំនៅឋានមានថ្លៃលើស៧ម៉ឺនដុល្លារអាម៉េរិក ក៏នឹងទទួលបាននូវការលើកទឹកចិត្តតាមរយៈការដកទឹកប្រាក់៧ម៉ឺនដុល្លារអាម៉េរិក ចេញពីមូលដ្ឋានគិតពន្ធផងដែរ។ ឧទាហរណ៍ ប្រសិនបើលំនៅឋានដែលជាកម្មវត្ថុនៃការទិញមានថ្លៃ១០ម៉ឺនដុល្លារអាម៉េរិក នោះមូលដ្ឋានសម្រាប់គិតពន្ធប្រថាប់ត្រា នឹងនៅសល់ត្រឹមតែ៣ម៉ឺនដុល្លារអាមេរិកប៉ុណ្ណោះ (ពោលគឺ១០ម៉ឺនដុល្លារ - ៧ម៉ឺនដុល្លារ = ៣ម៉ឺនដុល្លារ)។ | អគ្គនាយកដ្ឋានពន្ធដារ | បានសម្រេចពេញលេញ |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
| --- | --- | --- | --- |
| ១៦៩ | ១០.៤- ប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័ន ពាក់ព័ន្ធជំរុញការអនុវត្តផ្តល់សិទ្ធិឱ្យជនបរទេស អាចទិញនិងកាន់កាប់អចលនទ្រព្យតាមរយៈយន្តការចំនួន៤ គឺ(១) យន្តការតាមរយៈតំណាងជាជនជាតិខ្មែរ (២) យន្តការតាមរយៈក្រុមហ៊ុនបរធនបាល(៣) យន្តការវិនិយោគតំបន់ទេសចរណ៍ពិសិដ្ឋ និង(៤) យន្តការសិទ្ធិជួលរយៈពេលវែង ដោយត្រូវពិនិត្យឡើងវិញ និងកំណត់ឱ្យបានជាក់លាក់នូវលក្ខខណ្ឌនិងយន្តការ ដែលមានស្រាប់ពាក់ព័ន្ធនឹង÷ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | កំពុងត្រូវបានអនុវត្ត |
| ១៧០ | ១០.៤.១- ការរៀបចំតំបន់លំនៅឋានជាបុរីឬលំនៅឋានផ្សេងៗ និងតំបន់សេដ្ឋកិច្ចពិសេស ដែលជនបរទេសអាចជួលរយៈពេលវែង ឬកាន់កាប់កម្មសិទ្ធិគឺត្រូវមានចម្ងាយពីព្រំដែនទាំង៣យ៉ាងតិច៣០គីឡូម៉ែត្រ។ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | កំពុងត្រូវបានអនុវត្ត |
| ១៧១ | ១០.៤.២- ការកំណត់លក្ខណៈវិនិច្ឆ័យជាក់លាក់ ក្នុងការផ្តល់ទិដ្ឋាការសម្រាប់ជនបរទេសទទួលសិទ្ធិអនុវត្តតាមយន្តការទាំង ៤ ខាងលើ ដែលនឹងត្រូវស្នើឡើងដោយក្រសួងមហាផ្ទៃ។ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | កំពុងត្រូវបានអនុវត្ត |
| ១៧២ | ១០.៤.៣- ប្រភពហិរញ្ញប្បទាន ដែលត្រូវបានយកមកប្រើប្រាស់ក្នុងការទិញអចលនទ្រព្យចៀសវាងការលាងលុយកខ្វក់។ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | កំពុងត្រូវបានអនុវត្ត |
| ១៧៣ | ១០.៤.៤- ទិដ្ឋភាពបទដ្ឋានគតិយុត្តនានា សម្រាប់អនុវត្តនិងគ្រប់គ្រងយន្តការទាំង៤ខាងលើ។ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | កំពុងត្រូវបានអនុវត្ត |
| ១៧៤ | ១០.៥- ប្រគល់ភារកិច្ចជូនឯកឧត្តម **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជំរុញការរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយនូវលក្ខខណ្ឌ យន្តការ នីតិវិធី និងបទដ្ឋានគតិយុត្ត សម្រាប់ការអនុវត្តយន្តការទាំងនេះ រួមបញ្ចូលផងដែរ នូវយន្តការសម្រួលនិងលើកទឹកចិត្ត ការផ្តល់ទិដ្ឋាការ យន្តការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងយន្តការតាមដាននិងវាយតម្លៃ ។ល។ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | កំពុងត្រូវបានអនុវត្ត |

| ល.រ | ទិដ្ឋភាពការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| **១១-បញ្ហាផ្សេងៗ** | | | |
| ១៧៥ | ១១.២- ប្រគល់ភារកិច្ចជូនឯកឧត្តម **ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រីនិងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមដាននិងវាយតម្លៃលើវឌ្ឍនភាព នៃការអនុវត្តវិធានការខាងលើ និងរាយការណ៍មករាជរដ្ឋាភិបាលជាប់ជាប្រចាំ រៀងរាល់៦ខែម្តង។ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | កំពុងត្រូវបានអនុវត្ត |
| | ១១.៣- ប្រគល់ភារកិច្ចជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំ «**កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីកំណើនសេដ្ឋកិច្ចនៅក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់**» សម្រាប់រយៈពេល៤ឆ្នាំ ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ ដែលត្រូវរួមបញ្ចូលផងដែរ នូវការគិតគូរ ដោះស្រាយបញ្ហាធំៗមួយចំនួន ដែលវិស័យឯកជនបានលើកឡើងមានជាអាទិ៍÷ | | |
| ១៧៦ | ១១.៣.ក- ការអភិវឌ្ឍធនធានមនុស្សនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៧៧ | ១១.៣.ខ- ការជំរុញការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៧៨ | ១១.៣.គ- ការបង្កើនភាពទាក់ទាញសម្រាប់ការវិនិយោគផ្ទាល់ពីបរទេស | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៧៩ | ១១.៣.ឃ- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៨០ | ១១.៣.ង- ការអនុវត្តផែនការមេអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៨១ | ១១.៣.ច- ការជំរុញការអភិវឌ្ឍវិស័យកសិកម្មនិងវិស័យទេសចរណ៍ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៨២ | ១១.៣.ឆ- ការជំរុញការអភិវឌ្ឍឧស្សាហកម្មថ្មីៗ ដូចជាវិស័យយានយន្តនិងអេឡិចត្រូនិកកម្ពុជា ជាដើម | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |

| ល.រ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព |
|---|---|---|---|
| ១៨៣ | ១១.៣.ជ- កិច្ចសម្រួលពាណិជ្ជកម្ម ជាពិសេសការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីកាត់បន្ថយឱ្យអស់នូវការប្រើប្រាស់ឯកសារនាំចេញ-នាំចូលក្នុងទម្រង់រឹងឱ្យបានក្នុងរយៈពេល៤ឆ្នាំ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៨៤ | ១១.៣.ឈ- ការអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវដែកដែលមានបច្ចុប្បន្នឱ្យមានប្រសិទ្ធភាពនិងថ្លៃសមរម្យ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៨៥ | ១១.៣.ញ- ការជំរុញការកែសម្រួលឱ្យកាន់តែមានភាពប្រកួតប្រជែងបន្ថែមទៀតនូវបរិយាកាសធុរកិច្ចនិងការវិនិយោគជាដើម | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត |
| ១៨៦ | ១១.៤- ប្រគល់ភារកិច្ចជូនឯកឧត្តម **ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពន្លឿនការរៀបចំសមាសភាពក្រុមការងារសេដ្ឋកិច្ចនិងសង្គមឱ្យជីវពលនិងទូរគមនាគមន៍ (ក្រុម« ណ») ឱ្យបានឆាប់ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | បានសម្រេចពេញលេញ |
| ១៨៧ | ១១.៤.១- តាមដានការរៀបចំកិច្ចប្រជុំនៃក្រុមការងារទាំង១៦ ដើម្បីស្តាប់និងដោះស្រាយនូវបញ្ហាប្រឈមជូនវិស័យឯកជន | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | កំពុងត្រូវបានអនុវត្ត |
| ១៨៨ | ១១.៦- ប្រគល់ភារកិច្ចជូនឯកឧត្តម **ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រៀបចំវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ឱ្យបានយ៉ាងហោច២លើក នៅក្នុងអាណត្តិនីមួយៗរបស់រាជរដ្ឋាភិបាល។ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | កំពុងត្រូវបានអនុវត្ត |

# ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា


- អាសយដ្ឋាន : វិមានរដ្ឋាភិបាល តីរវិថីព្រះស៊ីសុវត្ថិ វត្តភ្នំ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- លេខទូរសព្ទ : (+៨៥៥) ០៩៩ ៧៩៩ ៥៧៩ / (+៨៥៥) ០៩៨ ៧៩៩ ៥៧៩
- គេហទំព័រ : www.cdc.gov.kh